# របាយការណ៍
# លទ្ធផលការងារវប្បធម៌ និងវិចិត្រសិល្បៈប្រចាំឆមាសទី១ ឆ្នាំ២០១៦

꧁꧂

ក្នុងរយៈពេលឆមាសទី១នៃឆ្នាំ២០១៦កន្លងមកនេះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដែលមានថ្នាក់ដឹកនាំ និងគ្រប់អង្គភាពថ្នាក់កណ្តាល និងថ្នាក់រាជធានី -ខេត្ត បានខិតខំប្រឹងប្រែងធ្វើការងារយ៉ាងមោះមុតជាប្រចាំ គឺធ្វើយ៉ាងណាឲ្យសម្រេចបានជាដំណាក់កាលៗ ទៅតាមផែនការសកម្មភាព និងការងារវប្បធម៌ និងវិចិត្រសិល្បៈឆ្នាំ២០១៦ដែលក្រសួងបានរៀបចំឡើងដោយអនុលោមតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិក្នុងវិស័យវប្បធម៌២០១៤ -២០១៨ និង គោលនយោបាយជាតិស្តីពីវិស័យវប្បធម៌។ ក្នុងការអនុវត្តផែនការសកម្មភាពនិងការងារវប្បធម៌និងវិចិត្រសិល្បៈខាងលើ ក្រសួងមានរចនាសម្ព័ន្ធដែលជាយន្តការធ្វើការងារ ហើយដែលសម្រេចបាននូវលទ្ធផលសម្រាប់ត្រីមាសកន្លងមកនេះដូចជម្រាបជូនខាងក្រោម ៖

## ១. រចនាសម្ព័ន្ធក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ៖

ដើម្បីអនុវត្តនូវការងាររបស់ខ្លួន ក្រសួងមានរចនាសម្ព័ន្ធដែលជាយន្តការធ្វើការងារដូចខាងក្រោម ៖

- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដឹកនាំដោយរដ្ឋមន្ត្រីចំនួន១រូប រដ្ឋលេខាធិការចំនួន៧រូប និងអនុរដ្ឋលេខាធិការចំនួន៨រូប
- ថ្នាក់រដ្ឋបាលកណ្តាលមាន ៖
    - អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មាននាយកដ្ឋានចំណុះចំនួន៩
    - អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ មាននាយកដ្ឋានចំណុះចំនួន៥
    - អគ្គនាយកដ្ឋានបេតិកភណ្ឌ មាននាយកដ្ឋានចំណុះចំនួន៤
    - សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ថ្នាក់ស្មើអគ្គនាយកដ្ឋាន មានមហាវិទ្យាល័យចំណុះចំនួន៥ និងមជ្ឈមណ្ឌលស្រាវជ្រាវវប្បធម៌ វិទ្យាសាស្ត្រចំនួន១
    - សាលាមធ្យមវិចិត្រសិល្បៈ ថ្នាក់ស្មើនាយកដ្ឋាន មានសាលាជំនាញចំនួន៥
    - នាយកដ្ឋានសវនកម្មផ្ទៃក្នុង
    - អធិការដ្ឋាន ថ្នាក់ស្មើនាយកដ្ឋាន
- ថ្នាក់រាជធានី-ខេត្ត ៖ ក្រសួងមានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី -ខេត្តចំនួន២៥ និងការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈក្រុង ស្រុក ខណ្ឌចំនួន១៦៦ការិយាល័យ

ចំណែកមន្ត្រីរាជការវិញ សរុបមានមានចំនួន **២.៣២០**នាក់ ស្រីចំនួន**៨៩៨**នាក់ ៖

- o ថ្នាក់រដ្ឋបាលកណ្តាលចំនួន**១.៣៦០**នាក់ ស្រីចំនួន**៥៤០**នាក់
- o ថ្នាក់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី-ខេត្តចំនួន**៩៦០**នាក់ ស្រីចំនួន**៣៥៨**នាក់។

## ២. សកម្មភាព និងលទ្ធផលការងារ ៖

### ២.១. សកម្មភាពថ្នាក់ដឹកនាំ ៖

ថ្នាក់ដឹកនាំក្រសួងបានទទួលជួបពិភាក្សាការងារជាមួយតំណាងស្ថានទូត ភ្ញៀវជាតិ និង អន្តរជាតិ អង្គការសមាគម បានចូលរួមប្រជុំ សិក្ខាសាលា អមដំណើរ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ទៅក្រៅប្រទេស និងបានចូលរួមជាកិត្តិយសក្នុងសកម្មភាពព្រឹត្តិការណ៍ ជាតិ និងអន្តរជាតិនានាសរុបមានចំនួន១០៨លើក។

### ២.២ . ការរៀបចំព្រឹត្តិការណ៍សំខាន់ៗ ៖

- កាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦ នាទីស្តីការក្រសួងមានរៀបចំបើកសន្និបាតបូកសរុបលទ្ធផលការងារវប្បធម៌ និងវិចិត្រសិល្បៈឆ្នាំ២០១៥ និងលើកទិសដៅការងារឆ្នាំ២០១៦ ក្រោមអធិបតីភាព លោកជំទាវរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងព្រឹកថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ នាសាលសន្និសីទចតុម្មុខ ក្រសួងបានរៀបចំពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារវប្បធម៌ និងវិចិត្រ សិល្បៈឆ្នាំ២០១៥ និងលើកទិសដៅការងារឆ្នាំ២០១៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម វ៉ា គឹមហុង ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម បណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** ដែលជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដោយមានការអញ្ជើញចូលរួមជាកិត្តិយសពីថ្នាក់ដឹកនាំជាន់ខ្ពស់ បណ្តាក្រសួង-ស្ថាប័ន ភ្ញៀវជាតិ-អន្តរជាតិ ថ្នាក់ដឹកនាំ-មន្ត្រីរាជការក្រសួងវប្បធម៌ និងវិចិត្រ សិល្បៈ សិល្បករ-សិល្បការិនីសរុប ចំនួន៦៧០នាក់
- កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០១៦ នាសារមន្ទីរជាតិភ្នំពេញ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានរៀបចំ**ពិធីតភ្ជាប់ព្រះសិរ្សជាមួយដងខ្លួនព្រះហារិហារៈ**និងពិធីប្រគល់ជាផ្លូវការនូវវិញ្ញាបនប័ត្រ ទទួលស្គាល់ "**ល្បែងទាញព្រ័ត្រ**" ចុះក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ នៃអង្គការយូណេស្កូ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
- កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦ នាសាលសន្និសីទចតុម្មុខ មានរៀបចំពិធីបើកមហោស្រព សិល្បៈយុវជនទូទាំងប្រទេស ឆ្នាំទី២ អបអរសាទរទិវាវប្បធម៌ជាតិ ០៣មីនា លើកទី១៨ ឆ្នាំ២០១៦ ក្រោមអធិបតីភាព លោកជំទាវរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដោយមានការអញ្ជើញ ចូលរួមជាកិត្តិយសពីថ្នាក់ដឹកនាំក្រសួង ភ្ញៀវជាតិ -អន្តរជាតិ មន្ត្រីរាជការ សិល្បករ សិល្បការិនី ប្រមាណ៧០០នាក់
- នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១ ៦ នា សាលសន្និសីទចតុម្មុខ មានប្រារព្ធទិវាវប្បធម៌ជាតិ ៣មីនា លើកទី១៨ ឆ្នាំ២០១ ៦ ក្រោមប្រធានបទ "**យុវជនដើម្បីវប្បធម៌ជាតិ**" និងពិធីបិទមហោស្រព សិល្បៈយុវជនទូទាំងប្រទេស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ**

**ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់បណ្តាក្រសួង-ស្ថាប័ន ភ្ញៀវជាតិ -អន្តរជាតិ មន្ត្រីរាជការ សិល្បករ សិល្បការិនី ចំនួន ៧៥០នាក់

- នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ នាសាលសន្និសីទចតុមុខ មានប្រារព្ធពិធីអបអរសាទរ ខួបលើកទី ១០៥ ទិវានារីអន្តរជាតិ ០៨ មីនា ឆ្នាំ២០១ ៦ ក្រោមប្រធានបទ "វិនិយោគសមភាពយេនឌ័រ ដើម្បីកិច្ចអភិវឌ្ឍប្រកបដោយចីរភាព" ក្រោមអធិបតីភាព លោកជំទាវ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដែលមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំក្រសួង ភ្ញៀវជាតិ អន្តរជាតិ មន្ត្រីរាជការ សិល្បករ សិល្បការិនី ចំនួន៦៨០នាក់
- នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ នាសារមន្ទីរជាតិកម្ពុជា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានរៀបចំ **ពិធីប្រគល់-ទទួលព្រះសិរ្សនៃព្រះបដិមាព្រះព្រហ្មចំនួនពីរ** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម ហោ ណាំហុង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការ អន្តរជាតិ
- នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ ឯកឧត្តម ថៃ នរៈសត្យា រដ្ឋលេខាធិការ តំណាងដ៏ខ្ពង់ខ្ពស់ លោកជំទាវ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានដឹកនាំគណៈប្រតិភូក្រសួងចុះសួរសុខទុក្ខ និងនាំយកអំណោយជូនដល់កងកម្លាំងនគរបាលវរៈសេនាតូចលេខ ៧៩៥ និង៩០៥ ដែលកំពុងឈរជើងការពារព្រំដែននៅតំបន់ប្រាសាទព្រះវិហារ និង ខេត្តឧត្តរមានជ័យ។

## ២.៣. សកម្មភាព និងលទ្ធផលការងារតាមអង្គភាព ៖

### *២.៣.១ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ៖*

***<u>នាយកដ្ឋានរដ្ឋបាលទូទៅ៖</u>***

- បានទទួលលិខិតចូលពីគ្រប់ស្ថាប័នចំនួន៣.៣១៨ច្បាប់ និងបញ្ជូនលិខិតចេញទៅគ្រប់ស្ថាប័នចំនួន១.៩០៥ច្បាប់។ ទន្ទឹមនេះក៏បានតាក់តែងលិខិតរដ្ឋបាលនិងលិខិតផ្សេងៗទៀតបានចំនួន១៥០ច្បាប់តាមបញ្ជារបស់ថ្នាក់ដឹកនាំ
- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាលដោយបានរៀបចំ កម្លាំងសន្តិសុខ និងនគរបាលយាមកាមប្រចាំការពេលថ្ងៃ និងយប់បានល្អប្រសើរក្នុងការថែរក្សាសុវត្ថិភាពនៅទីស្តីការក្រសួង
- បានធ្វើការបែងចែកសៀវភៅរាជកិច្ចជូនថ្នាក់ដឹកនាំតាមគោលការណ៍ប្រចាំខែ
- ការិយាល័យព័ត៌មានវិទ្យាបានបន្តដំណើរការជាធម្មតាតាមផែនការកំណត់

***<u>នាយកដ្ឋានបុគ្គលិក ៖</u>***

- បានបញ្ចូលប្រាក់បំណាច់មុខងារជូនមន្ត្រីរាជការចំនួន០៦នាក់ទីប្រឹក្សា និងជំនួយការចំនួន៣នាក់ មន្ត្រីសិក្សាក្រៅប្រទេសចំនួន០១នាក់ និងមន្ត្រីតែងតាំងថ្មីចំនួន២២នាក់ ក្នុងតារាងទូទាត់បៀវត្ស
- បានបញ្ចូលឈ្មោះមន្ត្រីថ្មីក្របខណ្ឌឆ្នាំ២០១៥ ចំនួន៤៥នាក់ មន្ត្រីផ្ទេរចូលចំនួន០១នាក់ បញ្ចូលឈ្មោះកូនរបស់មន្ត្រី និងបញ្ចូលសហព័ន្ធរបស់មន្ត្រីចំនួន០៤នាក់ក្នុងតារាងទូទាត់បៀវត្ស
- បានបញ្ចូលប្រាក់ឧបត្ថម្ភដល់និវត្តន៍ជនចំនួន០១នាក់

- បានចុះធ្វើការផ្សព្វផ្សាយអំពីការធ្វើកំណែទម្រង់រដ្ឋបាល ច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តបន្ទាយមានជ័យ រតនគិរី ប៉ៃលិន ក្រចេះ បាត់ដំបង មណ្ឌលគីរី ពោធិ៍សាត់ កែប កំពង់ឆ្នាំង និងកំពត
- បានធ្វើការផ្សព្វផ្សាយអនុក្រឹត្យលេខ៥៦ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យាដល់អង្គភាពថ្នាក់រដ្ឋបាលទាំងអស់
- បានធ្វើសំណើសុំនិយ័តក្របខ័ណ្ឌសម្រាប់ជ្រើសរើសក្របខ័ណ្ឌថ្មីឆ្នាំ២០១៦ ទៅក្រសួងមុខងារសាធារណៈ
- បាននឹងកំពុងរៀបចំការងារប្រឡងជ្រើសរើសសិស្ស និស្សិត ឲ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងវប្បធម៌ និងវិចិត្រសិល្បៈឆ្នាំ២០១៦
- បានធ្វើសំណើសុំតម្លើងឋានន្តរស័ក្ត ថ្នាក់ ជូនមន្ត្រីរាជការចំនួន១ .៦៦៣នាក់ ក្នុងនោះក្របខ័ណ្ឌរដ្ឋបាលចំនួន៧៧៣នាក់ និងក្របខ័ណ្ឌបច្ចេកទេសចំនួន៨៩០នាក់ ទៅក្រសួងមុខងារសាធារណៈ
- បានធ្វើការផ្សព្វផ្សាយការងារធ្វើពិពណ៌នាមុខតំណែងជូនដល់អង្គភាពថ្នាក់រដ្ឋបាលកណ្តាល និងតាមបណ្តាមន្ទីររាជធានី-ខេត្តមួយចំនួន
- បានធ្វើសេចក្តីជូនដំណឹងស្តីពីការសុំផ្តល់មេដាយជូនមន្ត្រីរាជការថ្នាក់កណ្តាល និងថ្នាក់រាជធានី-ខេត្ត សម្រាប់ឆ្នាំ២០១៦
- បានធ្វើប្រកាសជូនមន្ត្រីរាជការដែលស្ថិតក្នុងភាពទំនេរគ្មានបៀវត្សឱ្យចូលបម្រើការងារវិញចំនួ ន៨នាក់
- បានធ្វើប្រកាសជូនមន្ត្រីរាជការឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ចំនួន១នាក់ នៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តតាកែវ
- បានធ្វើប្រកាសដាក់មន្ត្រីរាជការស្ថិតក្នុងភាពទំនេរគ្មានបៀវត្សបន្ត ចំនួន១៨នាក់
- បានធ្វើប្រកាសស្តីពីការតម្លើងថ្នាក់តាមសញ្ញាបត្រជូនមន្ត្រីរាជការក្របខណ្ឌបច្ចេកទេសចំនួន០៥នាក់
- បានធ្វើសំណើសុំតាំងស៊ប់ជូនមន្ត្រីកម្មសិក្សាឆ្នាំ២០១៤ ចំនួន៧៥នាក់ ទៅក្រសួងមុខងារសាធារណៈ
- បានធ្វើប្រកាសតាំងស៊ប់ជូនមន្ត្រីកម្មសិក្សាឆ្នាំ២០១៤ ចំនួន០៨នាក់ ក្នុងក្របខ័ណ្ឌ "គ"
- បានធ្វើប្រកាសឱ្យមន្ត្រីកម្មសិក្សាចំនួន០២នាក់ បន្តកម្មសិក្សាលើកទីពីរ ក្នុងនោះថ្នាក់រដ្ឋបាលកណ្តាល០១នាក់ និងមន្ទីរវប្បធម៌ខេត្តកំពង់ធំ០១នាក់
- បានធ្វើការបែងចែកមន្ត្រីជាប់កិច្ចសន្យាទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ចំនួន៨០៧នាក់ សម្រាប់ប្រើប្រាស់ក្នុងឆ្នាំ២០១៦
- បានកាត់ឈ្មោះមន្ត្រីដែលលាឈប់ចំនួន ០១នាក់ ចេញពីតារាងទូទាត់ប្រាក់បៀវត្ស
- បានផ្តាច់ប្រាក់មន្ត្រីដល់អាយុចូលនិវត្តន៍ចំនួន០៩នាក់ ទទួលមរណៈភាពចំនួន០១នាក់ មន្ត្រីផ្ទេរចេញចំនួន០១នាក់ ស្ថិតក្នុងភាពទំនេរគ្មានបៀវត្សចំនួន០១នាក់ ចេញពីតារាងទូទាត់ប្រាក់បៀវត្ស
- បាននិងកំពុងបន្តការពិនិត្យ និងរៀបចំក្នុងការដំឡើងថ្នាក់ជូនដល់មន្ត្រីរាជការទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ការដំឡើងថ្នាក់ ឋានន្តរស័ក្តិក្នុងឆ្នាំ២០១៦
- បានធ្វើប្រកាសជូនមន្ត្រីរាជការឱ្យចូលនិវត្តន៍ ចំនួន៣៨នាក់ ក្នុងនោះ ៖
    - ថ្នាក់កណ្តាលចំនួន១២នាក់
    - ថ្នាក់រាជធានី-ខេត្តចំនួន២៦នាក់
- បាននឹងកំពុងដាក់ឆ្លងសុំគោលការណ៍អនុញ្ញាតជូនគ្រូបង្រៀនជាវបបម៉ោងបន្ថែមចំនួន៣៣២នាក់ សម្រាប់ឆ្នាំ២០១៥-២០១៦ របស់សាលាមធ្យមវិចិត្រសិល្បៈ

- បានធ្វើប្រកាសស្តីពីការបង្កើតគណៈកម្មការទទួលបន្ទុករួម និងគណៈកម្មការមេប្រយោគសម្រាប់ការប្រឡងយកសញ្ញាបត្រសិល្បៈសម្រាប់ឆ្នាំ២០១៥-២០១៦ នៅសាលាមធ្យមវិចិត្រសិល្បៈ
- បានធ្វើប្រកាសស្តីពីការបង្កើតគណៈកម្មការទទួលបន្ទុករួម និងគណៈកម្មការមេប្រយោគសម្រាប់ការប្រឡងសិស្សចូលរៀនសម្រាប់ឆ្នាំ២០១៦-២០១៧ នៅសាលាមធ្យមវិចិត្រសិល្បៈ
- បានបញ្ជាក់ស្នាតកបត្រសិល្បៈរបស់សាលាមធ្យមវិចិត្រសិល្បៈចំនួន០២សន្លឹក
- បានធ្វើឧទ្ទេសនាមសាស្ត្រាចារ្យបង្រៀនម៉ោងបន្ថែមចំនួន២៧១នាក់ នៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
- បានធ្វើប្រកាសស្តីពីសិស្សអាហារូបករណ៍ចំនួន២៨៩នាក់ របស់សាលាមធ្យមវិចិត្រសិល្បៈ
- បានបញ្ជូនមន្ត្រីចំនួន៣នាក់ ទៅប្រឡងវគ្គវិក្រឹត្យការជាន់ខ្ពស់នៅសាលាភូមិន្ទរដ្ឋបាល ដោយជាប់ជាស្ថាពរទាំង៣នាក់
- បានដាក់ឆ្លង និងទទួលបានគោលការណ៍ឯកភាពមកវិញ នូវគោលការណ៍ប្រឡងសញ្ញាបត្រសិល្បៈ ស្នាតកបត្រសិល្បៈ និងគោលការណ៍ប្រឡងជ្រើសរើសសិស្សចូលរៀនថ្នាក់ និងឆ្នាំទី១ របស់សាលាមធ្យមវិចិត្រសិល្បៈ

***<u>នាយកដ្ឋាននីតិកម្ម ៖</u>***

- បានចូលរួមប្រជុំសេចក្តីសម្រេចរួមលើផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦ របស់ក្រសួង នៅបន្ទប់លេខាធិការដ្ឋាន គ.ជ.អ.ប.
- បានចូលរួមប្រជុំ ស្តីពីការរៀបចំធ្វើរបាយការណ៍វឌ្ឍនភាពប្រចាំខែជូនទៅគណៈកម្មាធិការជាតិដើម្បីអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) នៅលេខាធិការដ្ឋាននៃ គ.ជ.អ.ប
- បានចូលរួមប្រជុំលើកទី១១ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នៅក្រសួងមហាផ្ទៃ
- បានចូលរួមប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីវិធានការហាមឃាត់ការជក់បារី និងការបង្ហុយផ្សែងផលិតផលថ្នាំជក់នៅកន្លែងធ្វើការ និងកន្លែងសាធារណៈ នៅក្រសួងសុខាភិបាល
- បានចូលរួមកិច្ចប្រជុំពិភាក្សាការងារពាក់ព័ន្ធនិងក្រុមការងារពាណិជ្ជកម្មទំនិញនៃភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់ (Regional Comprehensive Economic Partnership Working Group on Trade in Goods –RCEP-WGTIG) នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានចូលរួមក្នុងអង្គប្រជុំអន្តរក្រសួងដើម្បីពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងឧស្សាហកម្មភាពយន្ត នៅទីស្តីការគណៈរដ្ឋមន្ត្រី
- បានចូលរួមសិក្ខាសាលា ស្តីពីទំនាក់ទំនងរវាងកម្មសិទ្ធិបញ្ញា និងច្បាប់ប្រកួតប្រជែង នៅក្រសួងពាណិជ្ជកម្ម
- បានចូលរួមសិក្ខាសាលាស្តីពីសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម (Patent Cooperation Treaty) របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅរដ្ឋាករទឹកស្វយ័តភ្នំពេញ

- ចូលរួមកិច្ចប្រជុំដើម្បីត្រួតពិនិត្យ និងណែនាំលើការរៀបចំអនុវត្តផែនការសកម្មភាព និងថវិកា ឆ្នាំ២០១៦ របស់គណៈកម្មាធិការជាតិដើម្បីអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) នៅក្រសួងមហាផ្ទៃ
- ចូលរួមកិច្ចប្រជុំថ្នាក់ជំនាញក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីត្រួតពិនិត្យឡើងវិញអំពីការរៀបចំតារាងផ្តល់សេវាសាធារណៈលើវិស័យវប្បធម៌ និងវិចិត្រសិល្បៈ
- ចូលរួមប្រជុំអន្តរក្រសួងពិភាក្សាលើសេចក្តីព្រាងផែនការមេឆ្ពោះទៅធ្វើជាម្ចាស់ផ្ទះការប្រកួតកីឡា SEA Games លើកទី៣២ ឆ្នាំ២០២៣ (២០១៦-២០២៣)
- បានចូលរួមប្រជុំអន្តរក្រសួងដើម្បីពិភាក្សាលើសេចក្តីព្រាងច្បាប់ ស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក នៅទីស្តីការគណៈរដ្ឋមន្ត្រី
- បានចូលរួមប្រជុំត្រួតពិនិត្យចុងក្រោយប្រកាសរួមស្តីពី ការផ្តល់សេវាសាធារណៈលើវិស័យវប្បធម៌ នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានចូលរួមប្រជុំដើម្បីរៀបចំដាក់ឲ្យប្រើប្រាស់ការផ្តល់ព័ត៌មានសេវាសាធារណៈ (សេវាអាទិភាព) តាមបច្ចេកវិទ្យាទូរស័ព្ទស្មាតហ្វូន នៅក្រសួងមុខងារសាធារណៈ
- បានចូលរួមសិក្ខាសាលាស្តីពី ការផ្សព្វផ្សាយ កម្រងច្បាប់ខ្មែរពីបុរាណ នៅសណ្ឋាគារសូហ្វីតែល
- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងរបាយការណ៍បឋមស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ នៅសណ្ឋាគារភ្នំពេញ
- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពី គម្រោងកសាងសមត្ថភាពរៀបចំរបាយការណ៍លើការអនុវត្តអនុសញ្ញាឆ្នាំ២០០៥ ស្តីពីការការពារ និងការលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ នៅសណ្ឋាគារសាន់វេ
- បានចូលរួមប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសំណើសុំពិនិត្យសម្រេចលើការកែសម្រួលខណ្ឌរដ្ឋបាលព្រៃឈើ និងខណ្ឌរដ្ឋបាលជលផលទាំងអស់ទៅជាមន្ទីរជំនាញចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមបណ្តារាជធានី-ខេត្តនីមួយៗ នៅទីស្តីការគណៈរដ្ឋមន្ត្រី
- បានចូលរួមប្រជុំអន្តរក្រសួងដើម្បីពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីគុណភាពទឹក នៅទីស្តីការគណៈរដ្ឋមន្ត្រី
- បានរៀបចំសិក្ខាសាលា ស្តីពីការត្រួតពិនិត្យមុខងារឡើងវិញ ដែលជាគម្រោងការងារវិមជ្ឈការ និងវិសហមជ្ឈការក្រសួងសហការជាមួយគណៈកម្មាធិការជាតិដើម្បីអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នៅសណ្ឋាគារជលសារ ខេត្តព្រះសីហនុ

## ***<u>នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ៖</u>***

- បានធ្វើសំណុំលិខិតស្នើសុំថវិការដ្ឋសម្រាប់ប្រាក់បំណាច់ ប្រាក់បៀវត្សមន្ត្រីរាជការ និងសម្រាប់ឧបត្ថម្ភជីវភាពមរតកមនុស្សរស់១៦នាក់ ប្រចាំខែមករា កុម្ភៈ និងមីនា ឆ្នាំ២០១៦ និងនិវត្តន៍ជនចំនួន០៤នាក់ប្រចាំខែកុម្ភៈ និងមីនា ឆ្នាំ២០១៦
- បានស្នើសុំនិយ័តកម្មជំពូក៦៤ សម្រាប់បំពេញការខ្វះខាតប្រាក់បៀវត្សមន្ត្រីកិច្ចសន្យា ពលករអណ្តែតឆ្នាំ២០១៦ និងមន្ត្រីកិច្ចសន្យា ពលករអណ្តែតតាមមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី-ខេត្ត
- បានសុំគោលការណ៍ថវិកាសម្រាប់ជូនរង្វាន់ដល់អ្នកប្រគល់វត្ថុបុរាណនៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ស្ពឺ

- បានធ្វើរបាយការណ៍ និងសាលាកប័ត្របង្វែរចំណូល ៖
  - លក់សំបុត្រចូលទស្សនាសារមន្ទីរជាតិខែធ្នូ ឆ្នាំ២០១៥ និងខែមករា កុម្ភៈ ឆ្នាំ២០១៦
  - ត្រួតពិនិត្យវិស័យភាពយន្តខែធ្នូ ឆ្នាំ២០១៥ និងខែមករា កុម្ភៈ ឆ្នាំ២០១៦
  - ត្រួតពិនិត្យការនាំចេញ នាំចូលវត្ថុសិល្បៈខែធ្នូ ឆ្នាំ២០១៥ និងខែមករា កុម្ភៈ ឆ្នាំ២០១៦
  - ជួលមណ្ឌលរូបភាព (អាឡឺយ៉ង់) ខែធ្នូ ឆ្នាំ២០១៥ និងខែមករា កុម្ភៈ ឆ្នាំ២០១៦
  - រោងកុនលុច ខែធ្នូ ឆ្នាំ២០១៥ និងខែមករា ឆ្នាំ២០១៦
  - ទីតាំងមួយផ្នែកនៃនាយកដ្ឋានអភិវឌ្ឍវប្បធម៌ ប្រចាំត្រីមាសទី១ ឆ្នាំ២០១៦
  - ជួលទីតាំងមហោស្រពខេត្តកំពង់ចាម ឆ្នាំ២០១៥
- បានធ្វើសំណើសុំគោលការណ៍ចំណាយ ៖
  - រៀបចំសន្និបាតបូកសរុបការងារវប្បធម៌ និងវិចិត្រសិល្បៈឆ្នាំ២០១៥ និងលើកទិសដៅការងារឆ្នាំ២០១៦
  - រៀបចំទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១៨ ឆ្នាំ២០១៦
  - រៀបចំមហោស្រពសិល្បៈយុវជនទូទាំងប្រទេសឆ្នាំ២០១៦
  - បេសកកម្មនៅក្រៅប្រទេសនានា
  - ទិញសៀវភៅថ្មីៗតម្កល់នៅបណ្ណាល័យជាតិ ឆ្នាំ២០១៦
  - រៀបចំមហោស្រពសិល្បៈកំណាព្យ និងចម្រៀងខ្មែរជាសាកលលើកទី៤ ឆ្នាំ២០១៦
  - សិក្សាស្រាវជ្រាវចងក្រងឯកសារវត្ថុបុរាណ និងប្រមូលវត្ថុបុរាណក្នុងខេត្តព្រះវិហារ ដើម្បីចុះបញ្ជីសារពើភណ្ឌ
- បានធ្វើលិខិតស្នើសុំអាណត្តិចំណាយទូទាត់៖
  - ថ្លៃប្រើប្រាស់សេវាទូរស័ព្ទលើតុខែធ្នូ ឆ្នាំ២០១៥
  - ថ្លៃប្រើប្រាស់សេវាប្រមូល និងដឹកជញ្ជូនសម្រាប់ខែមករា ឆ្នាំ២០១៦
- បានធ្វើអាណត្តិចំណាយទូទាត់ ៖
  - ថ្លៃទូទាត់បេសកកម្មតាមបណ្តារាជធានី-ខេត្ត ឆ្នាំ២០១៥
  - ថ្លៃជួលរថយន្តក្រុមហ៊ុន លីម៉ូស៊ីន
  - បញ្ញើថ្លៃផ្ញើលិខិតផ្លូវការប្រចាំត្រីមាសទី៤ ឆ្នាំ២០១៥ ជូនប្រៃសណីយ៍កម្ពុជា។
  - ចំណាយបេសកកម្មនៅក្រៅប្រទេសនានា
  - ថ្លៃប្រើប្រាស់សេវាទូរស័ព្ទលើតុប្រចាំខែធ្នូ ឆ្នាំ២០១៥ និងខែមករា ឆ្នាំ២០១៦
  - ថ្លៃប្រើប្រាស់អ៊ីនធើណេតខែកុម្ភៈ ដល់ខែមេសា ឆ្នាំ២០១៦
  - ថ្លៃប្រមូល និងដឹកជញ្ជូនសម្រាមខែមករា ឆ្នាំ២០១៦
- បានធ្វើអាណត្តិសុំថវិការដ្ឋចំណាយបេសកកម្មនៅប្រទេសថៃ ឆ្នាំ២០១៥ និងចំណាយទូទាត់រដ្ឋទេយ្យជុំទី១ ឆ្នាំ២០១៦ និងជុំទី២ បន្ត
- ត្រួតពិនិត្យឯកសារអាណត្តិឆ្នាំ២០១៥-២០១៦
- ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជីបេឡាតាមទឹកប្រាក់ចំណាយរួច
- បានពិនិត្យប័ណ្ណចំណាយបញ្ជីបេឡា និងបញ្ចូលរបាយការណ៍ខែមករា ដល់ធ្នូ ឆ្នាំ២០១៥

***<u>នាយកដ្ឋានសម្ភារៈ និងបរិក្ខារ ៖</u>***

- បានធ្វើលិខិតបង្គាប់ការស្តីពីការបង្កើតគណៈកម្មការធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០១៥

- បានធ្វើតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង-ថយចុះក្នុងឆ្នាំ២០១៥ របស់ទីស្តីការក្រសួងវប្បធម៌ និងអង្គភាពក្រៅក្រសួង
- បានធ្វើលិខិតជម្រះម៉ូតូចំនួន០៤គ្រឿង របស់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តព្រៃវែង ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- បានធ្វើសំណើសុំធ្វើស្លាកលេខម៉ូតូរដ្ឋជូនមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកណ្តាល កំពង់ធំ និង ព្រៃវែង
- បានធ្វើស្លាកលេខឡានរដ្ឋជូននាយកដ្ឋានសិល្បៈទស្សនីយភាព
- បានចុះផ្ទៀងផ្ទាត់បញ្ជីសារពើភណ្ឌ និងធ្វើតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង-ថយចុះក្នុងឆ្នាំ២០១៥របស់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តតាកែវ កែប ព្រៃវែង ពោធិ៍សាត់ ព្រះសីហនុ កណ្តាល ស្វាយរៀង បាត់ដំបង និងប៉ៃលិន
- បានបន្តធ្វើការផ្គត់ផ្គង់សម្ភារៈការិយាល័យ និងជួសជុលសម្ភារៈការិយាល័យជូនគ្រប់បណ្តាអង្គភាព និងថ្នាក់ដឹកនាំ
- បានបញ្ចប់នីតិវិធីប្រគល់-ទទួលប្រេងឥន្ធនៈឆមាសទី១ ឆ្នាំ២០១៦ ព្រមទាំងបានបែងចែកជូនគ្រប់បណ្តាអង្គភាព និងថ្នាក់ដឹកនាំ សម្រាប់ខែមករា-មេសា
- បានលើកគម្រោង ៖
    - ជួសជុលកែលម្អបន្ទប់អានាម័យ និងប្រព័ន្ធលូសាលាមធ្យមវិចិត្រសិល្បៈ
    - ទិញសម្ភារៈប្រើប្រាស់ប្រចាំឆ្នាំ២០១៦
    - ទិញឧបករណ៍ភ្លេងបុរាណ
    - ជួសជុលរថយន្តប្រចាំឆ្នាំ២០១៦
    - ជួសជុលឧបករណ៍ការិយាល័យឆ្នាំ២០១៦
    - ជួសជុលកែលម្អសាលសម្តែងនាយកដ្ឋានសិល្បៈទស្សនីយភាព ជួសជុលកែលម្អរោងដាក់សម្ភារៈនាយកដ្ឋានអភិវឌ្ឍវប្បធម៌ និងរោងសៀក

### *ការងារអង្គភាពលទ្ធកម្ម*

- បានធ្វើសំណើសុំគោលការណ៍ស្តីពីការងារ ៖
    - ផ្គត់ផ្គង់ប្រេងឥន្ធនៈឆមាសទី១ ឆ្នាំ២០១៦
    - ផ្គត់ផ្គង់សម្ភារៈការិយាល័យ និងការបោះពុម្ពឆមាសទី១ ឆ្នាំ២០១៦
    - ផ្គត់ផ្គង់គ្រឿងសង្ហារិមប្រចាំឆ្នាំ២០១៦
    - ផ្គត់ផ្គង់សម្ភារៈបច្ចេកទេសប្រចាំឆ្នាំ២០១៦
    - ថែទាំ និងជួសជុលម៉ាស៊ីនត្រជាក់គ្រប់អង្គភាព និងតបណ្តាញអគ្គិសនីថ្មីនៅទីស្តីការក្រសួង
    - ផ្គត់ផ្គង់សម្លៀកបំពាក់សាលារបាំ សាលាល្ខោន សាលាសៀក និងរៀបចំតម្លើងស្នាដៃថ្មី ឆ្នាំ២០១៦
    - ផ្គត់ផ្គង់សម្ភារៈសម្រាប់ថែទាំសម្ភារៈឧបករណ៍រថយន្តឆ្នាំ២០១៦
    - ផ្គត់ផ្គង់ឯកសណ្ឋានឆ្មាំប្រាសាទប្រចាំឆ្នាំ២០១៦
    - ជួសជុលកែលម្អបន្ទប់អនាម័យ និងរៀបចំប្រព័ន្ធលូនៅសាលាមធ្យមវិចិត្រសិល្បៈ
    - ជួសជុលកែលម្អអាគារមហោស្រពនាយកដ្ឋានសិល្បៈទស្សនីយភាព និងរោងសៀកនៅនាយកដ្ឋានអភិវឌ្ឍវប្បធម៌

- ផ្គត់ផ្គង់ភេសជ្ជៈសម្រាប់ទទួលភ្ញៀវប្រចាំឆ្នាំ២០១៦
    - ធ្វើបង្គោលការពារស្ថានីយបុរាណនៅរាជធានី-ខេត្តចំនួន០៥ ក្នុងឆ្នាំ២០១៦
    - គាំពារ និងជួសជុលស្ពានទ័ព ខេត្តឧត្តរមានជ័យ ឆ្នាំ២០១៦
    - អភិរក្ស និងជួសជុលប្រាង្គកណ្តាលប្រាសាទបាសែត ខេត្តបាត់ដំបង ឆ្នាំ២០១៦
    - អភិរក្ស និងសង្គ្រោះបន្ទាន់ប្រាសាទបន្ទាយទ័ព ខេត្តបន្ទាយមានជ័យ ឆ្នាំ២០១៦
    - ជួសជុលសង្គ្រោះបន្ទាន់ក្លោងទ្វារខាងកើតនៃប្រាសាទនគរបាជ័យ ខេត្តកំពង់ចាម ឆ្នាំ២០១៦
    - ផ្គត់ផ្គង់សៀវភៅថ្មីៗ តម្កល់នៅបណ្ណាល័យជាតិ ឆ្នាំ២០១៦
    - គាំពារ និងជួសជុលប្រាសាទនាងខ្មៅ ខេត្តតាកែវ ក្នុងឆ្នាំ២០១៦
    - គាំពារ និងជួសជុលប្រាសាទភ្នំត្រប់ និងព្រះវិហារ វត្តមហាលាភ ខេត្តកំពង់ចាម ក្នុងឆ្នាំ២០១៦
    - ជួសជុលរថយន្តរដ្ឋឆ្នាំ២០១៦
    - ជួសជុលឧបករណ៍ការិយាល័យឆ្នាំ២០១៦
    - ផ្គត់ផ្គង់ឧបករណ៍ភ្លេងបុរាណឆ្នាំ២០១៦
    - ផ្គត់ផ្គង់សម្ភារៈប្រើប្រាស់ឆ្នាំ២០១៦
- បានធ្វើសំណើសុំគោលការណ៍អនុវត្តវិធីសាស្ត្រលទ្ធកម្មដោយឡែក ដោយចុះកិច្ចសន្យាផ្ទាល់ជាមួយគាំពារ និងអភិរក្សសំណង់បុរាណលើការងារ ៖
    - គាំពារ និងជួសជុលស្ពានទ័ព ខេត្តឧត្តរមានជ័យ
    - អភិរក្ស និងជួសជុលប្រាង្គកណ្តាលប្រាសាទបាសែត ខេត្តបាត់ដំបង
    - ជួសជុលសង្គ្រោះបន្ទាន់ក្លោងទ្វារខាងកើតនៃប្រាសាទនគរបាជ័យ ខេត្តកំពង់ចាម
    - គាំពារ និងជួសជុលប្រាសាទនាងខ្មៅ ខេត្តតាកែវ
    - គាំពារ និងជួសជុលប្រាសាទភ្នំត្រប់ និងព្រះវិហារ វត្តមហាលាភ ខេត្តកំពង់ចាម
- បានអនុវត្តការងារពិគ្រោះថ្លៃស្តីពីការងារ ៖
    - ផ្គត់ផ្គង់សម្ភារៈសម្រាប់ថែទាំឧបករណ៍រថយន្តឆ្នាំ២០១៦
    - ផ្គត់ផ្គង់ភេសជ្ជៈសម្រាប់ទទួលភ្ញៀវក្នុងឆ្នាំ២០១៦
    - ធ្វើបង្គោលការពារស្ថានីយបុរាណនៅរាជធានី -ខេត្តចំនួន៥ ក្នុងឆ្នាំ២០១៦
    - ផ្គត់ផ្គង់សម្ភារៈប្រើប្រាស់ឆ្នាំ២០១៦
    - ផ្គត់ផ្គង់ឧបករណ៍ភ្លេងបុរាណឆ្នាំ២០១៦
- បានអនុវត្តការងារដេញថ្លៃស្តីពីការងារ ៖
    - ផ្គត់ផ្គង់ប្រេងឥន្ធនៈឆមាសទី១ ឆ្នាំ២០១៦
    - ផ្គត់ផ្គង់សម្ភារៈការិយាល័យ និងការបោះពុម្ពឆមាសទី១ ឆ្នាំ២០១៦
- បានអនុវត្តការងារប្រគល់-ទទួលការងារ ៖
    - ផ្គត់ផ្គង់ប្រេងឥន្ធនៈឆមាសទី១ ឆ្នាំ២០១៦
    - ផ្គត់ផ្គង់សម្ភារៈការិយាល័យ និងបោះពុម្ពសម្រាប់ឆមាសទី១ ឆ្នាំ២០១៦
    - ផ្គត់ផ្គង់សម្ភារៈសម្រាប់ថែទាំឧបករណ៍រថយន្តឆ្នាំ២០១៦
    - ផ្គត់ផ្គង់ភេសជ្ជៈសម្រាប់ទទួលភ្ញៀវឆ្នាំ២០១៦
    - ធ្វើបង្គោលការពារស្ថានីយបុរាណនៅរាជធានី-ខេត្តចំនួន៥ ឆ្នាំ២០១៦

***នាយកដ្ឋានផែនការ ស្ថិតិ និងសរុប ៖***

- បានរៀបចំឯកសារសម្រាប់សន្និបាតបូកសរុបលទ្ធផលការងារវប្បធម៌ និងវិចិត្រសិល្បៈឆ្នាំ២០១៥ និងលើកទិសដៅការងារឆ្នាំ២០១៦
- បានរៀបចំធ្វើរបាយការណ៍ប្រចាំខែមករា ដល់ឆមាសទី១ និងបានផ្ញើគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ទៅតាមកាលកំណត់របស់រាជរដ្ឋាភិបាល
- បានបន្តរៀបចំតារាងតាមដានការអនុវត្តផែនការសកម្មភាពការងារវប្បធម៌ និងវិចិត្រសិល្បៈប្រចាំឆមាសទី១ ដើម្បីធានាប្រសិទ្ធិភាពក្នុងការអនុវត្តផែនការឆ្នាំ២០១៦។
- បានបន្ត និងបញ្ចប់ការកសាងកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល ២០១៧-២០១៩
- បានបន្តរៀបចំផែនការឆ្នាំ២០១៧
- បានបន្តរៀបចំប្រមូលទិន្នន័យស្ថិតិវប្បធម៌

***នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ៖***

- បានចូលរួមពិភាក្សាការងារក្រោមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន និងអនុក្រុមការងារវិធានដើមកំណើតនៃភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់ នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានចូលរួមប្រជុំកិច្ចព្រមព្រៀងក្របខ័ណ្ឌវិនិយោគ និងពាណិជ្ជកម្ម នៅក្រសួងពាណិជ្ជកម្ម
- បានចូលរួមប្រជុំអនុគណៈកម្មាធិការអភិវឌ្ឍពាណិជ្ជកម្ម និងវិនិយោគទាក់ទងនឹងពាណិជ្ជកម្ម SSC.TD.TRI លើកទី២៤ នៅក្រសួងពាណិជ្ជកម្ម
- បានចូលរួមសិក្ខាសាលាស្តីពីសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម (Patent Cooperation Treaty) របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅរដ្ឋាករទឹកស្វយ័តភ្នំពេញ
- បានប្រជុំកែសម្រួលប្រកាស ស្តីពីការបង្កើតអង្គភាពគ្រប់គ្រងសិទ្ធិរួម
- បានបកប្រែអត្ថបទ ស្តីពីអត្ថប្រយោជន៍របស់សន្ធិសញ្ញា Beijing
- បានបកប្រែសៀវភៅសិទ្ធិអ្នកនិពន្ធរបស់អង្គការកម្មសិទ្ធិបញ្ញាជាភាសាខ្មែរ និងកំពុងស្នើសុំបោះពុម្ពសៀវភៅពីអង្គការកម្មសិទ្ធិបញ្ញាពិភពលោក
- បានពិនិត្យឯកសារស្នើសុំសិទ្ធិគ្រប់គ្រងបទចម្រៀងដែលជាស្នាដៃលោក ស៊ិន ស៊ីសាមុត ចំនួន៨៣បទបន្ថែមទៀត
- បានផ្សព្វផ្សាយសេចក្តីជូនដំណឹង ស្តីពីការបញ្ឈប់ជាបន្ទាន់នូវរាល់សកម្មភាពរំលោភបំពានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល
- បានចេញសេចក្តីជូនដំណឹងដល់សាធារណៈជនដែលមានបំណងប្តឹងជំទាស់នឹងការស្នើសុំសិទ្ធិគ្រប់គ្រងមរតកសាសន៍បទចម្រៀងចំនួន៥៧បទដែលជាស្នាដៃលោក ស៊ិន ស៊ីសាមុត
- បានចុះបញ្ជីការពារស្នាដៃអក្សរសាស្ត្រចំនួន១១ស្នាដៃ បោះពុម្ពសៀវភៅចំនួន០៨ស្នាដៃ ចុះបញ្ជីប្តូរចំនួន០១ស្នាដៃ សុំសិទ្ធិធ្វើអាជីវកម្មលើស្នាដៃគ្មានមរតកសាសន៍ចំនួន២១បទ និងការចុះបញ្ជីការពារស្នាដៃតូរ្យតន្ត្រីចំនួន២អាល់ប៊ុម
- បានទទួលថវិកាចំនួន១.៤៩៥.០០០រៀល បង់ចូលថវិការដ្ឋ

***នាយកដ្ឋានសហប្រតិបត្តិការវប្បធម៌អន្តរជាតិ និងកិច្ចការអាស៊ាន ៖***

- បានសម្រួលបែបបទជូនថ្នាក់ដឹកនាំ មន្ត្រីជំនាញទៅចូលរួមប្រជុំ បំពេញបេសកកម្ម និងសម្តែងសិល្បៈបានចំនួន៣៨លើកៈ នៅប្រទេសថៃ វៀតណាម ឡាវ ហ្វីលីពីន ឥណ្ឌូណេស៊ី ម៉ាឡេស៊ី សិង្ហបុរី សាធារណរដ្ឋកូរ៉េ ជប៉ុន ចិន បារាំង ស្វីស សហរដ្ឋអាមេរិក រុស្ស៊ី និងណាមីប៊ី
- បានទទួលគណៈប្រតិភូសិល្បៈនៃក្រសួងវប្បធម៌ចិន ចំនួន៣២រូប ដឹកនាំដោយនាយកដ្ឋានសិល្បៈទីក្រុងធានជីង មកសម្តែងសិល្បៈរួមគ្នាជាមួយនាយកដ្ឋានសិល្បៈទស្សនីយភាព ក្រោមប្រធានបទ "ស្នាមញញឹមកម្ពុជា" និងដើម្បីអបអរពិធីបុណ្យចូលឆ្នាំចិន
- បានទទួលគណៈប្រតិភូសិល្បៈនៃក្រសួងវប្បធម៌ថៃ ចំនួន៨០រូប ដឹកនាំដោយឯកឧត្តមរដ្ឋមន្ត្រីក្រសួងវប្បធម៌ថៃ ដែលអញ្ជើញមកទស្សនកិច្ច និងប្រគំតន្ត្រីស ម្លេងស្រាល អបអរសាទរខួបលើក៦៥ ចំណង មិត្តភាពកម្ពុជា-ថៃ នៅព្រះរាជាណាចក្រកម្ពុជា
- បានទទួលគណៈប្រតិភូសិល្បៈនៃព្រះរាជាណាចក្រថៃចំនួន១០០រូបមកទស្សនកិច្ច នៅប្រាសាទបន្ទាយឆ្មារ និងប្រាសាទបន្ទាយទ័ព ខេត្តបន្ទាយមានជ័យ
- បានទទួលគណៈប្រតិភូសិល្បៈរបស់នាយកដ្ឋានវប្បធម៌ ខេត្ត Guangdong នៃសាធារណរដ្ឋប្រជាមានិតចិន មកសម្តែងក្នុងកម្មវិធី "China Guangdong Culture Silk Road Tour 2016" និង "China Today Arts Week in Cambodia 2016"
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានចុះកិច្ចព្រមព្រៀងជាមួយសាកលវិទ្យាល័យមីឈីហ្គេសហរដ្ឋអាមេរិក ក្រោមអធិបតីភាពឯកឧត្តម ជុច ភឿន រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ឯកឧត្តម ប្រាក់ សុណ្ណារ៉ា អគ្គនាយកបេតិកភណ្ឌ បានចុះអនុស្សារណៈនៃការយោគយល់គ្នាជាមួយ Julie Fleischman
- ឯកឧត្តម សំរាំង កំសាន្ត រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និង ឯកឧត្តម Felipe M. De Leon, JR. ប្រធាននៃគណៈកម្មាធិការជាតិ ដើម្បីវប្បធម៌ និងសិល្បៈ (ភាគីហ្វីលីពីន)បានចុះហត្ថលេខាលើ " Executive Program for Cultural Cooperationbetween the National Commission for Culture and the Arts of the Republic of the Philippines and the Ministry of Culture and Fine Arts of the Kingdom of Cambodia for the Years 2016-2019" នៅទីក្រុងម៉ានីល នៃសាធារណរដ្ឋហ្វីលីពីន
- នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៦ នៅទីស្តីការក្រសួង បានរៀបចំពិធីប្រគល់-ទទួលអំណោយរថយន្ត និងសម្ភារៈការិយាល័យរបស់ស្ថានទូតចិនប្រចាំប្រទេសកម្ពុជាជូនក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រោមអធិបតីភាព លោកជំទាវរដ្ឋមន្ត្រី និងលោកជំទាវឯកអគ្គរដ្ឋទូតចិន

***<u>សាលាបណ្តុះបណ្តាលក្របខ័ណ្ឌវប្បធម៌ ៖</u>***

- បានរៀបចំបើកវគ្គបណ្តុះបណ្តាលស្តីពីការងាររដ្ឋបាល និងបទពិសោធន៍ការងារសម្រាប់មន្ត្រីក្របខ័ណ្ឌឆ្នាំ២០១៤
- បានរៀបចំសំណុំឯកសារស្នើសុំគោលការណ៍បើកវគ្គបណ្តុះបណ្តាលមន្ត្រីរាជការចំនួន៣វគ្គ ៖
    - វគ្គបណ្តុះបណ្តាលកិច្ចការរដ្ឋបាល និងគ្រប់គ្រង
    - វគ្គបណ្តុះបណ្តាលការងារផ្តល់សេវាលើវិស័យវប្បធម៌
    - វគ្គបណ្តុះបណ្តាលការងាររដ្ឋបាល និងបទពិសោធន៍ការងារសម្រាប់មន្ត្រីក្របខ័ណ្ឌឆ្នាំ២០១៥។

## ២.៣.២. អគ្គនាយកដ្ឋានបេតិកភណ្ឌ៖

## *នាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណ ៖*

**ក.ការងារអភិរក្សដ្ឋានអង្គរ ៖**

- បានទទួលអ្នកស្រាវជ្រាវមកពីសាលាបារាំងចុងបូព៌ាប្រទេស និងមន្ត្រីមកពីសារមន្ទីរជាតិភ្នំពេញចូលផ្ទៀងផ្ទាត់វត្ថុសិល្បៈក្នុងឃ្លាំង
- បានចូលរួមត្រួតពិនិត្យវត្ថុសិល្បៈចំនួន៣៦ប្រភេទ ដែលសាលាប៉ាឡឺម៉ូទើបនឹងយកមកពីវត្តរាជបូព៌ ដើម្បីសម្អាត និងជួសជុល
- បានជ្រើសរើសវត្ថុសិល្បៈក្នុងអភិរក្សដ្ឋានអង្គរចំនួន២០រូប ដែលមានសភាពបែកបាក់ខ្លាំង ដើម្បីលើកគម្រោងជួសជុលក្នុងដំណាក់កាលទី២
- កំពុងរៀបចំស្លាកព័ត៌មានជាភាសាខ្មែរ និងអង់គ្លេស អំពីរចនាបថ ប្រភព និងកាលបរិច្ឆេទសម្រាប់ផ្តែរ និងសិលាចារិកក្នុងបរិវេណអភិរក្សដ្ឋានអង្គរ ដើម្បីសម្រួលដល់ការទស្សនារបស់ភ្ញៀវទេសចរណ៍
- បានបន្តស្កេនបញ្ជីសារពើភណ្ឌវត្ថុសិល្បៈសម័យបារាំង
- បានតាមដានការរៀបចំវត្ថុសិល្បៈក្នុងបរិវេណអភិរក្សដ្ឋានអង្គរ
- ចូលរួមក្នុងការថតភាពយន្តឯកសារអំពី "ប្រាសាទបុរាណនានានៅក្នុងតំបន់អង្គរ" ដោយសហការជាមួយស្ថានីយ៍ទូរទស្សន៍អាស៊ីអាគ្នេយ៍ នៅក្នុងបរិវេណអភិរក្សដ្ឋានអង្គរ ប្រាសាទព្រះខ័ន ប្រាសាទតុប ប្រាសាទបន្ទាយធំ ប្រាសាទបន្ទាយក្តី ប្រាសាទបាយ័ន ប្រាសាទទន្លេស្ងួត ប្រាសាទតាព្រហ្ម ភ្នំបាខែង ស្ពានកំពង់ក្តី ស្ពានថ្ម និងស្រះស្រង់
- បានស្រាវជ្រាវរកឯកសារអំពីបដិមាព្រះឥសូរ ដែលគេប្រកាសលក់នៅអាមេរិក ក្រែងមានក្នុងបញ្ជីសារពើភណ្ឌរូបក្នុងអភិរក្សអង្គរ ប៉ុន្តែពុំបានរកឃើញទេ
- បានរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋសម្រាប់ការិយាល័យអភិរក្សអង្គរ
- បានរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋក្នុងសាលប្រជុំ បន្ទប់ពិសោធន៍ និងឃ្លាំងធំ
- បានចូលរួមជាមួយសមាជិកគណៈកម្មការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ២០១៦ដោយចុះត្រួតពិនិត្យផ្ទៀងផ្ទាត់សម្បត្តិរដ្ឋតាមការិយាល័យនីមួយៗក្នុងនាយកដ្ឋាន
- បានសិក្សា និងប៉ាន់ស្មានតម្លៃដើម្បីលើកគម្រោងជួសជុលវត្ថុសិល្បៈប្រចាំឆ្នាំក្នុងអភិរក្សដ្ឋានអង្គរ
- បានចូលរួមស្រាវជ្រាវរកឯកសារអំពីចម្លាក់គោក្នុងបរិវេណអភិរក្សដ្ឋានអង្គរ ដើម្បីកំណត់រចនាបថ
- បានចូលរួមអនុវត្តគម្រោងថៃទាំ គាំពារស្ពានទ័ព ខេត្តឧត្តរមានជ័យ
- បានផ្ទៀងផ្ទាត់បញ្ជីសារពើភណ្ឌវត្ថុសិល្បៈសម័យបារាំងដែលស្កេនរួច ដើម្បីបោះពុម្ពជាសៀវភៅ
- បានចុះសិក្សាពីស្ថានភាពជាក់ស្តែងនៃក្បាលដីដែលពាក់ព័ន្ធនឹងបណ្តឹងទាមទាររបស់ប្រជាពលរដ្ឋ
- បានចូលរួមក្នុងការទទួលអ្នកស្រាវជ្រាវមកពីស្ថាប័នសាលាបារាំងចុងបូព៌ាប្រទេសនិងមន្ត្រីមកពីសារមន្ទីរជាតិភ្នំពេញចូលផ្ទៀងផ្ទាត់វត្ថុសិល្បៈក្នុងឃ្លាំង

**ខ.ការងារស្រាវជ្រាវ និងចងក្រងឯកសារប្រវត្តិសាស្ត្រក្នុងកិច្ចការពារតំបន់ប្រាសាទ៖**

- បានស្កេនកាតាឡុករូបថតចាស់ៗចំនួន១៤៩សន្លឹក ទុកជាឯកសារ
- បានជួបជាមួយអ្នកជំនាញកំព្យូទ័រពិភាក្សាអំពីការបង្កើត Software ដើម្បីរៀបចំគ្រប់គ្រងទិន្នន័យសម្រាប់មជ្ឈមណ្ឌលឯកសារបន្ទាយឆ្មារ

- បានរៀបចំឯកសារសម្រាប់ធ្វើបទបង្ហាញអំពីគម្រោងអភិរក្ស និងជួសជុលប្រាសាទនគរបាជ័យ ខេត្តកំពង់ចាម
- បានរៀបចំឯកសារស្តីពីប្រវត្តិអ្នកគ្រប់គ្រងអភិរក្សដ្ឋានអង្គរ សមិទ្ធិផលការងារនាពេលកន្លងមក និងការទទួលខុសត្រូវរបស់អភិរក្សដ្ឋានអង្គរ ជាភាសាអង់គ្លេស
- បានរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋសម្រាប់ការិយាល័យ
- បានចុះពិនិត្យស្ថានភាពខូចខាតស្ពានទ័ពដើម្បីកំណត់ទីតាំងដែលត្រូវធ្វើកំណាយ និងជួសជុល
- បានចុះពិនិត្យការជីកស្រះថ្មីមួយ ទំហំ៥០ម៉ែត្រ គុណ២០០ម៉ែត្រ នៅជ្រុងខាងត្បូងនៃទំនប់បុរាណរបស់ប្រាសាទបន្ទាយឆ្មារ
- បានសិក្សាលើកគម្រោងប្រាសាទស្នឹងខាងលិចដើម្បីដាក់ក្នុងផែនការជួសជុលឆ្នាំ២០១៧
- បានស្រាវជ្រាវឯកសារប្រាសាទមួយចំនួនពីគេហទំព័រអ៊ិនធើណេត និងបានចម្លងទុកជាឯកសារក្នុងកុំព្យូទ័រ
- បានចុះទៅពិនិត្យការដ្ឋានជួសជុលស្ពានទ័ព ខេត្តឧត្តរមានជ័យ និងប្រាសាទបាសែត ខេត្តបាត់ដំបង

**<u>គ.ការងារគ្រប់គ្រងរមណីយដ្ឋានវប្បធម៌ ៖</u>**

- មន្ត្រីកម្មសិក្សាបានគូសប្លង់វត្ថុសិល្បៈនៅក្នុងអាគារលេខ៧ បានរួចរាល់ និងបន្តគូសនៅអគារលេខ៤
- បានចុះទៅធ្វើសម្រង់ប្លង់នៅប្រាសាទនគរបាជ័យ ខេត្តកំពង់ចាម
- បានបកប្រែអត្ថបទ ស្តីអំពីទម្រង់ នៃការចុះបញ្ជីសារពើភណ្ឌនៃប្រាសាទ ពីភាសាបារាំងទៅជាភាសាខ្មែរ និងភាសាអង់គ្លេស
- បានរៀបចំចងក្រងរចនាសម្ព័ន្ធប្រព័ន្ធគ្រប់គ្រងទិន្នន័យ (DataBase Format)

**<u>ឃ.ការងារជួសជុលប្រាសាទ និងសំណង់បុរាណ ៖</u>**

- បានចុះទៅវាស់វែង និងពិនិត្យទីតាំងដែលត្រូវធ្វើការជួសជុលទល់ទ្រប្រាសាទបន្ទាយទ័ព ខេត្តបន្ទាយមានជ័យ និងស្ពានទ័ព ខេត្តឧត្តរមានជ័យ
- បានចុះត្រួតពិនិត្យរោងទងទី៣ នៃប្រាសាទបន្ទាយឆ្មារ ខេត្តបន្ទាយមានជ័យ ដើម្បីលើកគម្រោងរកការគាំទ្រពីមូលនិធិ Alphawood
- បានចុះពិនិត្យប្រាសាទបន្ទាយឆ្មារ និងស្ពានទ័ព ក្នុងនោះមានលោកស្រី Joyce Clark ក្រុមប្រឹក្សាអង្គការមិត្តសម្លាញ់វប្បធម៌ខ្មែរ លោក Colen Darill សាស្ត្រាចារ្យប្រវត្តិសាស្ត្រខ្មែរ និងលោក Jiseo Kim ប្រធានការដ្ឋានព្រះពិធូ
- បានទៅពិនិត្យស្ថានភាពទូទៅគោបុរៈខាងកើតប្រាសាទនគរបាជ័យខេត្តកំពង់ចាម និងយកសំណាកផ្ទាំងគំនូរបុរាណ (ពណ៌ខ្មៅ,ពណ៌ក្រហម,ពណ៌ខៀវ) និងសំណាកម្រ័ក្សនៅលើសសរដើម្បីយកទៅវិភាគសមាសធាតុផ្សំនៅប្រទេសកូរ៉េ
- បានចុះពិនិត្យការដ្ឋានជួសជុលប្រាសាទបាសែត ខេត្តបាត់ដំបង ដើម្បីវិភាគល ម្អិតរកឲ្យឃើញអំពីមូលហេតុនៃការខូចខាតរបស់ប្រាសាទ និងធ្វើផែនការជួសជុលប្រាសាទឡើងវិញតាមលក្ខណៈបុរាណ
- បានអនុវត្តគម្រោងជួសជុល ៖
    - ស្ពានទ័ព ខេត្តឧត្តរមានជ័យ

- o ប្រាសាទបាសែត ខេត្តបាត់ដំបង
- o គាំពារ និងអភិរក្សប្រាសាទនាងខ្មៅ ខេត្តតាកែវ
- o គាំពារ និងអភិរក្សប្រាសាទភ្នំគ្រប់ ខេត្តកណ្ដាល
- o គាំពារ និងអភិរក្សវត្តមហាលាភ ខេត្តកំពង់ចាម

**<u>ង.ការងារគ្រប់គ្រងសំណង់ប្រវត្តិសាស្ត្រ ៖</u>**

- បានចុះទៅអង្កេតការខូចខាត និងធ្វើការសម្អាតសាកល្បងសសរបិទមាសនៅវត្តមហាលាភ និង វត្តសំរោង ខេត្តកំពង់ចាម
- សហការជាមួយការិយាល័យអភិរក្សអង្គរសិក្សាអំពីផ្ទៃរកំណត់តាមអាយុកាល
- ថតចម្លងរូបថតចាស់ពីបណ្ណាល័យ EFEO : Khmer temple of Angkor បានចំនួន០២ថាស
- បានសិក្សាផែនការជួសជុលវត្ថុសិល្បៈនៅឃ្លាំងជាមួយការិយាល័យអភិរក្សអង្គរ
- បានចុះត្រួតពិនិត្យរោងទងទី៣ នៃប្រាសាទបន្ទាយឆ្មារ ខេត្តបន្ទាយមានជ័យ ដើម្បីលើកគម្រោង រកការគាំទ្រពីមូលនិធិ Alphawood
- បានចូលរួមការងារអនុវត្តគម្រោងអភិរក្ស និងជួសជុលស្ពានទ័ព ខេត្តឧត្តរមានជ័យ និង ប្រាសាទបាសែត ខេត្តបាត់ដំបង

**<u>ច.ការងារអភិរក្សតាមបណ្ដាខេត្ត៖</u>**

*អភិរក្សដ្ឋានកំពង់ធំ និង ព្រះវិហារ ៖*

- បន្តចូលរួមសហការជាមួយអង្គការ Waseda ចងក្រងឯកសារ និងជួសជុលប្រាសាទសំបូរ ព្រៃគុក នៅខេត្តកំពង់ធំ
- បានសហការជាមួយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ធំ លើកគម្រោងសង្គ្រោះបន្ទាន់ ប្រាសាទអណ្ដែត
- បានរើឈើចាស់ដែលទល់ទ្រប្រាសាទអណ្ដែតកាលពីឆ្នាំ២០០៩ចេញ រួចដាក់ជំនួសដោយដែក
- បានចុះពិនិត្យការដួលរលំថ្មនៅប្រាសាទព្រះស្ទឹង ខេត្តព្រះវិហារ
- មន្ត្រីជាប់កិច្ចសន្យាប្រចាំប្រាសាទសំបូរព្រៃគុក បានត្រួសត្រាយព្រៃចំនួន១០.០០០ម៉ែត្រការ៉េ

*អភិរក្សដ្ឋានបាត់ដំបង បន្ទាយមានជ័យ និង ឧត្តរមានជ័យ*

- បានចុះពិនិត្យមើលការសាងសង់សំណង់ នៅក្នុងតំបន់២នៃប្រាសាទបន្ទាយឆ្មារ ថតរូបទុកជា ឯកសារ
- បានចាក់ថ្នាំសម្លាប់កូនឈើតូចៗដែលដុះឬសញែកថ្មជញ្ជាំងប្រាសាទចំនួន២៣កន្លែង
- បានកាត់ដើមស្ពង់ដែលដុះតាមជញ្ជាំងថ្មបាយក្រៀម កំពែងទី២ មុខខាងជើង ផ្នែកខាងលិចនៃ ប្រាសាទបន្ទាយឆ្មារ
- ឆ្មាំការពារប្រាសាទបានធ្វើរបារការពារមិនឲ្យភ្ញៀវប៉ះពាល់ចម្លាក់ជញ្ជាំងរោងទងមុខខាងកើតផ្នែក ខាងត្បូងបានប្រវែង៥០ម៉ែត្រ
- បានធ្វើស្លាកសញ្ញាដាក់នៅផ្លូវចូលប្រាសាទតាព្រហ្មបានចំនួន០១ផ្ទាំង
- បានចុះពិនិត្យ និងថតទីតាំងដែលអាជ្ញាធរឃុំបន្ទាយឆ្មារចាក់ដីធ្វើផ្លូវ ចាក់ដីលំនៅដ្ឋាន ចាក់ដី លុបប្រឡាយទឹក និងបានស្នើទៅអភិបាលស្រុកថ្មពួកជួយអន្តរាគមន៍កុំឲ្យបន្តចាក់ដីលុបប្រឡាយ ទឹកតទៅទៀត ជាលទ្ធផលត្រូវបានផ្អាកជាបណ្ដោះអាសន្ន

- បានចុះពិនិត្យមើលការជីកស្រះរបស់កងវិស្វកម្មសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានសហការជាមួយឆ្មាំមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តបន្ទាយមានជ័យប្រចាំប្រាសាទបន្ទាយឆ្មារត្រួសត្រាយព្រៃដុះនៅតាមប្រាសាទរណបទាំង៨
- បានសហការជាមួយក្រុមហ៊ុន ខាំ សាម៉េត ជួសជុលផ្លូវចូលប្រាសាទតាអ៊ឹមបានប្រវែង១០០ម៉ែត្រ

**<u>ឆ.ការងារសហប្រតិបត្តិការជាមួយអន្តរជាតិ៖</u>**

- កិច្ចសហការជាមួយអង្គការ G.H.F និង SOAS, University of London បាននិងបន្តការងារអភិរក្ស និងជួសជុលប្រាសាទបន្ទាយឆ្មារ ខេត្តបន្ទាយមានជ័យ
- កិច្ចសហការជាមួយអង្គការ Waseda ជួសជុលប្រាសាទសំបូរព្រៃគុក ខេត្តកំពង់ធំ ៖ បាននិងកំពុងបន្តការងារជួសជុលប្រាសាទ N1

## ***<u>នាយកដ្ឋានសារមន្ទីរ ៖</u>***

**<u>ក.សារមន្ទីរជាតិភ្នំពេញ៖</u>**

- បានទទួលបំណែកបដិមា និងបំណែកជើងទម្របដិមានាងឧមារាំចំនួន១២ដុំ បានមកពីតំបន់ប្រាសាទកោះកេរ (ប្រាសាទចិន ប្រាសាទក្រហម) និងពីសារមន្ទីរព្រះនរោត្តមសីហនុ -អង្គរ "**បដិមាដង ខ្លួនព្រះរាម**" ចំនួន០១ អំពីថ្មភក់ ពីសារមន្ទីរ Denver Art Museum សហរដ្ឋអាមេរិក "**បំណែកថ្ង**" ចំនួន០១ អំពីប្រាក់ ពីលោក Romain Louvet នាំមកពីប្រទេសថៃ តាមរយៈ EFEO ប្រចាំកម្ពុជា មកប្រគល់ជូនសារមន្ទីរជាតិ "***ព្រះកេសទេវរូប***" ចំនួន០២ អំពីថ្ម ពីឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសបារាំង "***សសរព្រះវិហារ***" អំពីឈើ ចំនួន២ដើម ពីព្រះគ្រូវិស្សាល សៀ ភាភ៉ា វត្តឧណ្ណាលោម "***ទេវរូបភេទស្រី***" អំពីថ្មភក់ ចំនួន១ ពីប្រជាពលរដ្ឋនៅឃុំគោកគ្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល និង "***ព្រះកេសទេពប្រុស***" ចំនួន០១ អំពីថ្មភក់ ពីលោក ឡេង ប៊ុនដែន ជំនួយការអម គ.ជ.ប.អ
- បាន Back-up ទិន្នន័យនៅក្នុងប្រព័ន្ធ Data base
- បានសហការជាមួយលោកស្រី **ចាន់ ស្រី** នាយិកាប្រចាំតំបន់ក្រុមសិក្សាស្រាវជ្រាវគម្រោងពិដានជប៉ុននៃអង្គការគាំពារកុមារខ្មែរ បានរៀបចំពិព័រណ៍មិនអចិន្ត្រៃយ៍ ស្តីពី "**ហ្វាលពិដានខ្មែរ**" នៅសារមន្ទីរជាតិ ក្រោមអធិបតីភាព **ឯកឧត្តម ជុច ភឿន** រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និង ឯកឧត្តម **YUJI Kumamaru** ឯកអគ្គរាជទូតជប៉ុនប្រចាំនៅកម្ពុជា
- បានសហការជាមួយវិទ្យាស្ថានបុរាណវិទ្យាបង្ការ នៃប្រទេសបារាំង (INRAP) បានរៀបចំពិព័រណ៍មិនអចិន្ត្រៃយ៍ ស្តីពី **លទ្ធផលកំណាយបុរាណវិទ្យាបង្ការនៅអាកាសយានដ្ឋានអន្តរជាតិសៀមរាប** ក្រោមប្រធានបទ "**រស់នៅក្នុងសម័យអង្គរ**" នៅសារមន្ទីរជាតិ ក្រោមអធិបតីភាព **ឯកឧត្តម** សំរាំង កំសាន្ត រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- នាយកដ្ឋានសារមន្ទីរ បានសហការជាមួយអង្គការយូណេស្កូប្រចាំកម្ពុជា រៀបចំពិព័រណ៍មិនអចិន្ត្រៃយ៍ ស្តីពី "**កម្ពុជា និងសង្គ្រាមលោកលើកទី១-បេតិកភណ្ឌក្រោមទឹក**" នៅសារមន្ទីរជាតិក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់លោកជំទាវ **ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ឯកឧត្តម **Marc MICHIELSEN** ឯកអគ្គរាជទូតប្រទេសបែលហ្ស៊ិកប្រចាំប្រទេសថៃ កម្ពុជា ឡាវ និងភូមា និងលោកស្រី **Anne LEMAISTRE** តំណាងអង្គការយូណេស្កូ

ប្រចាំនៅកម្ពុជា ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ តំណាងអង្គទូត និងភ្ញៀវជាតិ-អន្តរជាតិ ប្រមាណ២០០នាក់

- បានជួសជុលរូបចម្លាក់បាន**១៣រូប**
- បានទទួលភ្ញៀវឲ្យចូលទស្សនាសារមន្ទីរជាតិភ្នំពេញសរុបចំនួន **១២៦.៨៣២នាក់** ក្នុងនោះមានភ្ញៀវជាតិចំនួន**១៦.៤៧៤នាក់**ទទួលបានចំណូលថវិកាចំនួន**៥.៧៦៥.៩០០រៀល** និងភ្ញៀវអន្តរជាតិចំនួន**៨៨.០៧៤នាក់** ទទួលបានចំណូលថវិកាចំនួន **៣០៨.២៥៩ដុល្លា** បង់ចូលថវិការដ្ឋ និងភ្ញៀវចូលឥតបង់ថ្លៃចំនួន **២២.២៨៤នាក់**

## ខ.សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង៖

- បានរៀបចំបើកសម្ពោធពិព័រណ៍មិនអចិន្ត្រៃយ៍ស្តីពី "ភាពសោកសៅ និងការតស៊ូរបស់ស្ត្រីក្រោយការរៀបការដោយបង្ខំក្នុងសម័យខ្មែរក្រហម" ក្រោមអធិបតីភាព លោកជំទាវរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានបើកវគ្គបណ្តុះបណ្តាលលើជំនាញសរសេរព័ត៌មានលើបណ្តាញសង្គម ដោយគ្រូជំនាញមកពីអង្គការ DWACADEMIE នៃប្រទេសអាឡឺម៉ង់
- ពិនិត្យនិងឆែកឯកសារមីក្រូហ្វីលចំនួនពីរដងក្នុងមួយខែ
- ស្កេនឯកសារចម្លើយសារភាពរបស់ជនរងគ្រោះចំនួន២៦ឯកសារ ស្មើនឹង៣.៩៥៨ទំព័រ
- ស្កេនឯកសារប្រវត្តិរូបជនរងគ្រោះ និងប្រវត្តិរូបខ្មែរក្រហមមានបិទរូបថតចំនួន១.១០៨ឯកសារ
- ចងក្រង និងស្រង់ខ្លឹមសារពីឯកសារចម្លើយសារភាពជនរងគ្រោះចំនួន៩៧៥ឯកសារ
- ស្កេនរូបថតចំនួន៨៨៨រូបថត
- ផ្តល់ឯកសារចម្លើយសារភាពជនរងគ្រោះជូនក្រុមអ្នកស្រាវជ្រាវមកពីអង្គការជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចំនួន៦.៦៩៥ឯកសារ និងស្កេនចំនួន២១ឯកសារ ស្មើនឹង២.៥៦៦ទំព័រ
- ចុះបញ្ជីសារពើភណ្ឌក្នុងឃ្លាំងបានចំនួន៩៨០វត្ថុ
- សិស្សសាលា German Cambodain Conservation School (GCCS)ចំនួន០៧នាក់បានមករៀនជួសជុលលោហៈ និងជួសជុលសារមន្ទីរទួលស្លែង
- បានចុះបង្រៀនដល់សាលារៀនសុវណ្ណភូមិ និង AIS អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងប្រវត្តិសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង
- បានទទួលភ្ញៀវជាតិ-អន្តរជាតិ ព្រះសង្ឃ សិស្ស និស្សិតចូលទស្សនាមានចំនួន**២៣៧.៣៤១នាក់** ក្នុងនោះភ្ញៀវអន្តរជាតិមានចំនួន**១៩៩.១៧៩នាក់**

## គ.មណ្ឌលវត្តភ្នំ៖

បានទទួលភ្ញៀវទេសចរណ៍ជាតិ-អន្តរជាតិចូលទស្សនាមានចំនួន**១១២.៦០១នាក់** ក្នុងនោះភ្ញៀវអន្តរជាតិមានចំនួន **៧៤.២៥១នាក់**។

## ឃ.មណ្ឌលជើងឯក៖

បានទទួលភ្ញៀវទេសចរណ៍ជាតិ-អន្តរជាតិចូលទស្សនាសរុបមានចំនួន**១៥៣.៨៩៣នាក់** ក្នុងនោះភ្ញៀវអន្តរជាតិមានចំនួន**១២៣.៨៤៤នាក់**។

## ***នាយកដ្ឋានបុរាណវត្ថុ៖***

- បានបន្តបញ្ចូលទិន្នន័យវត្ថុបុរាណនៅខេត្តសៀមរាប ព្រះវិហារ និងកំពង់ឆ្នាំងក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ (Database)
- បានចុះទៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តសៀមរាបដើម្បីជួយលើការងារពិនិត្យ និងវាយតម្លៃវត្ថុសិល្បៈ
- បានចុះសិក្សាស្រាវជ្រាវ និងធ្វើបញ្ជីសារពើភណ្ឌវត្ថុបុរាណតាមទីតាំងមួយចំនួនក្នុងខេត្តកំពង់ឆ្នាំង និងព្រះវិហារ
- បានរៀបចំរូបភាព និងខ្លឹមសារនៃបទបញ្ញត្តិដើម្បីធ្វើបដាផ្សព្វផ្សាយដាក់តាមកន្លែងសំខាន់ៗ និងត្រៀមផ្សព្វផ្សាយតាមបណ្តាញសង្គម Facebook
- បានបន្តរៀបចំគេហទំព័ររបស់នាយកដ្ឋានបុរាណវត្ថុ
- បានបន្តចុះសិក្សាស្វែងយល់បុរាណវត្ថុអំពីថ្ម នៅសារមន្ទីរជាតិ
- បានចុះទៅវាស់វែង គូរផែនទី និងកំណត់និយាមការស្ថានីយបុរាណវិទ្យា នៅស្រុកកណ្តាលស្ទឹង
- បានសិក្សាស្រាវជ្រាវ និងចូលរួមប្រជុំស្តីពីបដិមាខ្មែរចំនួន៥ ដែលកំពុងដាក់លក់នៅហាងលក់វត្ថុបុរាណ នៅប្រទេសអ៊ីតាលី
- បានទំនាក់ទំនងទៅមន្ទីរខេត្តកំពង់ឆ្នាំង និងព្រះវិហារ ដើម្បីប្រមូលទិន្នន័យបមពាក់ព័ន្ធទីតាំងវត្ថុបុរាណដែលស្ថិតនៅតាមវត្តអារាម ទីប្រាសាទ និងទីតាំងស្ថានីយបុរាណផ្សេងៗក្នុងខេត្តទាំងពីរ
- បានចូលរួមជួសជុលគំនូរបុរាណនៅតាមជញ្ជាំងថែវជុំវិញព្រះវិហារព្រះកែវមរកត ជាមួយក្រុមអ្នកបច្ចេកទេសប៉ូឡូញ (PPKZ)
- បានផ្តល់សេវាពិនិត្យវត្ថុសិល្បៈនាំចូល-នាំចេញបានចំនួនសរុប**២.៦៥០រូប** ទទួលបានថវិកាចំនួន **២៨.៩៧៧.០០០រៀល** បង់ចូលថវិការដ្ឋ

## ***<u>នាយកដ្ឋានបុរាណវិទ្យា និងបុរេប្រវត្តិវិទ្យា៖</u>***

- បានចុះទៅធ្វើការអភិរក្ស សិក្សាវិភាគ និងធ្វើបញ្ជីសារពើភណ្ឌកុលាលភាជន៍ ដែលបានមកពីស្ថានីយសំពៅលិចក្រោមទឹក នៅកោះស្តេច ខេត្តកោះកុង
- បានសហការធ្វើកំណាយស្រាវជ្រាវបន្តជាមួយសាកលវិទ្យាល័យអ៊ីលីណយ សហរដ្ឋអាមេរិក នៅតំបន់បាកាន (ប្រាសាទព្រះខ័នកំពង់ស្វាយ) ខេត្តព្រះវិហារ
- បានអមដំណើរឯកឧត្តមអគ្គនាយកបេតិកភណ្ឌ ចុះទៅផ្សព្វផ្សាយច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ និងកំណត់និយាមការដើម្បីបោះបង្គោលដែនការពារតំបន់ស្ថានីយបុរាណនៅស្រះសារពើយុត្ត និងរាជធានីវាំងចាស់ នៅស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ
- បានចុះផ្សព្វផ្សាយច្បាប់ ស្តីពីកិច្ចការពារបេតិកភណ្ឌជូនប្រជាពលរដ្ឋដែលរស់នៅតំបន់ជុំវិញទួលអំបែង ខេត្តព្រៃវែង
- បានចូលរួមធ្វើកំណាយស្រាវជ្រាវបុរេប្រវត្តិសាស្ត្រកម្ពុជា-បារាំង នៅស្ថានីយល្អាងស្ពាន ខេត្តបាត់ដំបង
- បានចូលរួមស្រាវជ្រាវនៅតំបន់ភ្នំដែក ខេត្តព្រះវិហារ
- បានចុះទៅកំណត់និយាមការ និងបោះបង្គោលការពារនៅស្ថានីយ ទួលអំបែង ខេត្តព្រៃវែង
- បានចុះទៅបោះបង្គោលការពារនៅស្ថានីយចំនួន០៧ ស្ថិតនៅក្នុងឃុំរការ និងឃុំជើងកើប ខេត្តកណ្តាល
- បានចុះទៅបោះបង្គោលដែនការពារនៅស្ថានីយទួលអ្នកតាព្រីងក្អែក នៅខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ
- បានចុះទៅបោះបង្គោលដែនការពារតំបន់រណបទី១ ភ្នំជីសូរ្យ ខេត្តតាកែវ

- បានចូលរួមជាមួយនាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណ ចុះទៅពិនិត្យការស្តាស្រះទឹកចំនួន៤ នៅជុំវិញព្រះវិហារ និងជួសជុលសាលាធម្មសភា០១ខ្នង ក្នុងវត្តពោធិ៍រុក្ខារាម ខេត្តកំពង់ឆ្នាំង
- បានចុះទៅពិនិត្យ និងដឹកជញ្ជូនអដ្ឋិធាតុជនរងគ្រោះពីមណ្ឌលឧក្រិដ្ឋកម្មក្រាំងតាចាន់ ខេត្តតាកែវ យកមកធ្វើការអភិរក្សនៅមជ្ឈមណ្ឌលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ជើងឯក រាជធានីភ្នំពេញ
- បានចូលរួមជាគ្រូឧទ្ទេសនាម និងបង្រៀនពីជំនាញបេតិកភណ្ឌនៅនាយកដ្ឋាននគរបាលការពារបេតិកភណ្ឌ នៃក្រសួងមហាផ្ទៃ
- បានចុះទៅធ្វើការអភិរក្សអដ្ឋិធាតុជនរងគ្រោះនៅមជ្ឈមណ្ឌលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ជើងឯក រាជធានីភ្នំពេញ
- បានចូលរួមធ្វើកំណាយស្រាវជ្រាវឡបុរាណមួយកន្លែង នៅស្ថានីយបុរាណភូមិមូលជើងឯក រាជធានីភ្នំពេញ ជាមួយរាជបណ្ឌិត្យសភាកម្ពុជា និងសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
- បានធ្វើកំណាយសង្គ្រោះនៅស្ថានីយទួលអំបែង ខេត្តព្រៃវែង

***<u>ការងារបេតិកភណ្ឌរូបីតាមមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី-ខេត្ត ៖</u>***

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានីភ្នំពេញ ៖</u>***

- បានបន្តរៀបចំថែរក្សាការពារសណ្តាប់ធ្នាប់ សោភ័ណភាព អនាម័យមណ្ឌលវត្តភ្នំបានល្អជាប្រចាំ
- បានចុះត្រួតពិនិត្យការឈូសឆាយក្នុងបរិវេណទីទួលបុរាណនៅភូមិមូលជើងឯក ខណ្ឌដង្កោ
- បានរៀបចំ ចងក្រងឯកសារ និងរូបភាពមួយចំនួនស្តីពីស្ថានីយបុរាណ ដែលក្នុងនោះមានវត្តបុរាណមួយចំនួនស្ថិតនៅខណ្ឌមានជ័យ
- បានចុះស្រង់ស្ថិតិស្ថានីយបុរាណដែលមានក្នុងរាជធានីភ្នំពេញ
- បានចុះធ្វើបច្ចុប្បន្នភាពស្ថានីយបុរាណនៅតាមសង្កាត់នីមួយៗ ក្នុងខណ្ឌចំនួន៩ រាជធានីភ្នំពេញ ដោយមានការបញ្ជាក់ពីលក្ខណៈ និងទីតាំងច្បាស់លាស់ពីចៅសង្កាត់នីមួយៗ
- បានចុះចងក្រងឯកសារពីស្ថានីយបុរាណ នៅក្នុងខណ្ឌចំនួន៦ នៅរាជធានីភ្នំពេញ
- បានចុះស្រាវជ្រាវរកទិន្នន័យបឋមនៅវត្តចាក់អង្រែក្រោម និងទួលអ្នកតាដើមពោធិ៍ នៅខណ្ឌមានជ័យ
- បានចុះបោះបង្គោលកំណត់ព្រំទួលអ្នកតាព្រីងក្អែក និងត្រពាំងស្វាយធំ នៅខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ដោយមានការចូលរួមពីប្រធាននាយកដ្ឋានបុរាណវិទ្យា និងបុរេប្រវត្តិវិទ្យា និងអាជ្ញាធរដែនដី
- បានចូលរួមសហការជាមួយវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ នៃរាជបណ្ឌិត្យសភាកម្ពុជា ធ្វើកំណាយស្រាវជ្រាវពីឡកុលាលភាជន៍ នៅស្ថានីយជើងឯក
- បានសហការជាមួយនាយកដ្ឋានបុរាណវិទ្យា និងបុរេប្រវត្តិវិទ្យា និងអាជ្ញាធរពាក់ព័ន្ធ ចុះតម្លើងស្លាកប៉ាណូលើទីតាំងស្ថានីយភូមិមូលជើងឯក ដើម្បីសម្គាល់លើទីតាំងបេតិកភណ្ឌ នៅខណ្ឌដង្កោ រាជធានីភ្នំពេញ

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកណ្តាល ៖</u>***

- បានសហការជាមួយមន្ត្រីជំនាញក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងអាជ្ញាធរស្រុកកៀនស្វាយ ចុះពិនិត្យ និងធ្វើបញ្ជីសារពើភណ្ឌវត្ថុបុរាណក្នុងសារមន្ទីរស្រែអំពិលមានចំនួន១២៨ដុំ-ផ្ទាំង

- ឆ្នាំភ្នំព្រះរាជទ្រព្យ បានពង្រឹងការងារតាមគោលដៅទាំង៨ នៅលើខ្នងភ្នំ និងទីតាំងខាងក្រោមព្រះសក្យមុនីចេតីយ
- បានសហការជាមួយមន្ត្រីជំនាញក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ លោកសាស្ត្រាចារ្យ សឺន ស៊ូប៊ែរ និងមន្ត្រីពាក់ព័ន្ធ បានចុះពិនិត្យ និងពិភាក្សាអំពីកិច្ចការពារសុវត្ថិភាពវត្ថុបុរាណនៅសារមន្ទីរស្រែអំពិល ស្រុកកៀនស្វាយ
- បានសហការជាមួយអាជ្ញាធរពាក់ព័ន្ធ បោះបង្គោលចំនួន៨ដើម និងធ្វើពិធីក្រុងពាលីចាប់ផ្តើមសាងសង់សាលាឆទាននៅទួលព្រះរាមព្រះល័ក្ខណ៍ នៅស្រុកពញាឮ ដោយប្រើប្រាស់ថវិការបស់សប្បុរសជន
- បានសហការជាមួយនាយកដ្ឋានបុរាណវិទ្យា និងបុរេប្រវត្តិវិទ្យា និស្សិតកម្មសិក្សា និងអាជ្ញាធរភូមិឃុំ ចុះពិនិត្យផលប៉ះពាល់ស្ថានីយបុរាណវិទ្យានៅភូមិឡឥដ្ឋ ឃុំព្រែកដំបង ស្រុកមុខកំពូល
- បានសហការជាមួយមន្ត្រីជំនាញក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អាជ្ញាធរឃុំ ស្រុកកណ្តាលស្ទឹង និងមន្ត្រីពាក់ព័ន្ធ ចុះប្រមូលទិន្នន័យធ្វើផែនទីកំណត់និយាមការស្ថានីយបុរាណ ដោយសម្រេចបាន៧ឃុំ លើ១៨ឃុំ ក្នុងស្រុកកណ្តាលស្ទឹង។ លទ្ធផលសម្រេចបាន៣៤ទួល  ក្នុងនោះទិន្នន័យចាស់មាន២១ទួល និងរកឃើញថ្មីមាន១៣ទួល
- បានសហការជាមួយនាយខណ្ឌរដ្ឋបាលព្រៃឈើខេត្តកណ្តាល និងក្រុមអភិរក្សសត្វព្រៃភ្នំតាម៉ៅ ចាប់សត្វស្វានៅភ្នំព្រះរាជទ្រព្យចំនួន២ក្បាល យកទៅចិញ្ចឹមនៅសួនសត្វភ្នំតាម៉ៅ
- បានចុះពិនិត្យមើលស្ថានភាពទួលអង្គ នៅស្រុកអង្គស្នួល ដោយពិនិត្យឃើញថាពុំមានការឈូសឆាយឡើយ
- បានសហការជាមួយក្រុមការងារនាយកដ្ឋានបុរាណវិទ្យា និងបុរេប្រវត្តិវិទ្យា អាជ្ញាធរស្រុកឃុំ ស្រុកកណ្តាលស្ទឹង និងមន្ត្រីពាក់ព័ន្ធ ចុះបោះបង្គោលកំណត់ដែនការពារស្ថានីយបុរាណវិទ្យានៅឃុំរកាចំនួន៥ស្ថានីយ ឃុំជើងកើបចំនួន២ស្ថានីយ
- សប្បុរសជនបានឧបត្ថម្ភកៅអីវែងថ្មចំនួន៧ សម្រាប់ភ្ញៀវអង្គុយលេងនៅលើភ្នំព្រះរាជទ្រព្យ ស្រុកពញាឮ
- ក្រុមការងារនាយកដ្ឋានបុរាណវិទ្យា និងបុរេប្រវត្តិវិទ្យា សហការជាមួយនគរបាលបេតិកភណ្ឌ ក្រសួងមហាផ្ទៃ និងព្រះគ្រូ សូត្រ ស្រេង វត្តព្រះនាគ ឃុំឆក់ឈើនាង ចុះពិនិត្យវត្ថុបុរាណតម្កល់ទុកក្នុងវត្តព្រះនាគ រួមមានថ្មសុះឱសថបុរាណ អង្ករកែនឱសថ ព្រួចថ្មដាវ ព្រុំមាសសាយកែ បំណាំ កចាន អំបែងក្រឡ ដុំឥដ្ឋ និងវត្ថុបុរាណមួយចំនួន និងបានប្រមូលទុករង់ចាំចំណាត់ការរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានសហការជាមួយក្រុមការងារនាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណ ចុះកាប់ឆ្ការព្រៃដែលដុះលើចេតិយព្រះអង្គច័ន្ទ នៅតំបន់ស្នួល ភ្នំព្រះរាជទ្រព្យ បានរួចរាល់ជាស្ថាពរ
- បានចុះពិនិត្យស្ថានីយបុរាណដែលកំពុងប្រឈមនឹងគ្រោះថ្នាក់ នៅស្រុកកណ្តាលស្ទឹង
- អាជ្ញាធរស្រុកអង្គស្នួល បានចុះពិនិត្យការសាងសង់រោងសក្ការៈនៅលើទួលអង្គស្រះ ស្ថិតនៅឃុំក្រាំងម្កាក់ ដែលប្រជាពលរដ្ឋបានសាងសង់ដើម្បីប្រយោជន៍រួម ក្រុមការងារបានសម្រេចផ្អាកបណ្តោះអាសន្ន រង់ចាំស្នើសុំសម្រេចពីសមត្ថកិច្ចពាក់ព័ន្ធ
- បានសហការជាមួយអាជ្ញាធរពាក់ព័ន្ធឃុំត្បែង ឃុំព្រែករកា និងឃុំជើងកើប ចុះពិនិត្យ និងចាត់វិធានការថែរក្សាស្ថានីយបុរាណដែលកំពុងប្រឈមនឹងគ្រោះថ្នាក់

- បានដឹកនាំក្រុមនិស្សិតផ្នែកបុរាណវិទ្យាចុះសិក្សាទួលបុរាណទាំង៥៨ ក្នុងស្រុកខ្សាច់កណ្តាល និងផ្តើមសិក្សានៅទួលកំពង់ ក្នុងរយៈពេល១ឆ្នាំ ដើម្បីសរសេរសារណាបញ្ចប់ការសិក្សាផ្នែកបុរាណវិទ្យា
- បានទទួលព្រះហស្តព្រះនារាយណ៍ពីការិយាល័យវប្បធម៌ស្រុកខ្សាច់កណ្តាលដែលបានរកឃើញនៅទួលតាឡឹក
- នគរបាលប៉ុស្តិ៍រដ្ឋបាលឃុំគោកត្រប បានប្រគល់វត្ថុបុរាណជាទេវរូបភេទស្រី កម្ពស់ ៥៥,៥ ស.ម. ទទឹង១២,៥ ស.ម. កម្រាស់៨,៥ ស.ម. កសាងអំពីថ្មភក់ ស.វ.ទី១១ ជូនសារមន្ទីរជាតិ។ វត្ថុបុរាណនេះ ពួកគាត់បានរកឃើញនៅពេលជីកស្តារអូរស្តុកទឹកសម្រាប់ប្រជាជនប្រើប្រាស់នៅឃុំគោកត្រប ស្រុកកណ្តាលស្ទឹង
- ក្រុមជាងរបស់ក្រុមហ៊ុន ផាន អ៊ីមុិច បានផ្អាកជួសជុលព្រះវិហារធំ ភ្នំព្រះរាជទ្រព្យ ស្រុកពញាឮ មួយរយៈ
- ទទួលប្រាក់ពីព្រះគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ដែលបានឧបត្ថម្ភថ្លៃភ្លើងចំនួន៦.៧១១.២០០រៀល សម្រាប់បំភ្លឺនៅព្រះសក្យមុនីចេតិយ និងឧបត្ថម្ភថវិកាដល់ឆ្នាំចំនួន១.០០០.០០០រៀល

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកែប ៖</u>***

- បានសហការជាមួយគណៈកម្មការវត្តបោសសម្អាត កាប់ឆ្ការព្រៃផ្លូវចូលរូង និងបរិវេណរមណីយដ្ឋានភ្នំសសៀរជាប្រចាំ
- បានចុះពិនិត្យទួលអង្គ "អង្គជំណាក់" (ស្រាវជ្រាវឃើញថ្មី) ទួលអង្គ "អតីតវត្តកែបចាស់"នៅក្រុងកែប និងទួលអង្គ "អង្គតាស៊ិន" នៅស្រុកដំណាក់ចង្អើរ
- បានចុះស្រាវជ្រាវសមុច្ច័យ និងវត្ថុសិល្បៈដើម្បីរៀបចំដាក់ឲ្យដំណើរការសារមន្ទីរខេត្ត
- បានចុះពិនិត្យព្រះវិហារវត្តចរិយាវង្ស នៅសង្កាត់អូរក្រសា ក្រុងកែប ដែលព្រះចៅអធិការវត្តមានគម្រោងរុះរើដើម្បីរៀបចំសាងសង់ព្រះវិហារថ្មី

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ចាម ៖</u>***

- បានចុះពិនិត្យ និងអភិរក្សនៅជុំវិញប្រាសាទនគរបាជ័យ និងវត្តភ្នំប្រុស ភ្នំស្រី ការពារក្រែងមានសំណង់អាណាធិបតេយ្យនៅក្នុងបរិវេណប្រាសាទបុរាណ នៅស្រុកកំពង់សៀម
- បានចុះពិនិត្យមើលប្រាសាទដែលមាននៅស្រុកបាធាយ និងស្រុកជើងព្រៃចំនួន៨លើក
- បានចូលរួមសហការជាមួយនាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណ ក្នុងការជួសជុលក្លោងទ្វារខាងកើត នៃប្រាសាទនគរបាជ័យ
- បានចុះផ្សព្វផ្សាយច្បាប់ការពារបេតិកភណ្ឌ និងបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងបេតិកភណ្ឌវប្បធម៌ នៅស្រុកស្រីសន្ធរ និងស្រុកកោះសូទិន

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ឆ្នាំង ៖</u>***

បានបន្តចុះត្រួតពិនិត្យ និងស្រង់ស្ថិតិប្រាសាទ ទួលប្រាសាទ គ្រឹះប្រាសាទ ស្ថានីយបុរេប្រវត្តិ និងរមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រ។

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ធំ ៖</u>***

- បានសហការជាមួយមន្ត្រីនគរបាលខេត្ត និងមន្ត្រីជំនាញសារមន្ទីរជាតិ ចុះធ្វើកោសល្យវិច្ឆ័យវត្ថុសិល្បៈចំនួន០៧រូប អំពីលោហៈដែលចាប់បានពីជនល្មើស
- បន្តជួសជុលវត្ថុសិល្បៈដែលតម្កល់នៅថែវក្នុងសារមន្ទីរខេត្ត
- បានចូលរួមផ្តាមសិលាចារឹកជាមួយមន្ត្រីជំនាញសារមន្ទីរជាតិ នៅសារមន្ទីរខេត្ត
- បានបណ្តុះបណ្តាលដល់សិស្សវិទ្យាល័យកំពង់ឈើទាល ផ្នែកស្រាវជ្រាវបុរាណវិទ្យា និងអំពី កិច្ចការពារបេតិកភណ្ឌវប្បធម៌ជាតិ
- បានចុះអប់រំផ្សព្វផ្សាយពីសារៈសំខាន់នៃស្រះបុរាណនៅបឹងធំ ក្នុងក្រុងស្ទឹងសែន ដែលអ្នកភូមិ និងអាជ្ញាធរមូលដ្ឋានមានបំណងចង់ស្តារបឹងនេះឡើងវិញ
- បានផ្សព្វផ្សាយច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌជាតិដល់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋនៅឃុំដូង ស្រុកប្រាសាទបល្ល័ង្គ និងឃុំសំបូរ ស្រុកប្រាសាទសំបូរ
- បានរកឃើញទួលប្រាសាទមួយកន្លែងដែលមានតួប៉មសង់ពីឥដ្ឋចំនួន០៥  ប៉ុន្តែបាក់បែកសល់តែគ្រឹះស្ថិតនៅឃុំប្រាសាទសំបូរ ស្រុកប្រាសាទសំបូរ
- បានធ្វើការបោសសម្អាត និងកាប់ឆ្ការល្បាស់នៅតាមប្រាសាទនានា
- បានត្រួសត្រាយផ្លូវចាប់ពីក្លោងទ្វារក្រោយប្រាសាទយាយព័ន្ធទៅលិចទៅដល់ប្រាសាទត្រពាំងល្ពាក់ខាងលិចដែលមានទទឹង៦ម៉ែត្រ និងបណ្តោយ៣៧៥ម៉ែត្រ
- បានចុះពិនិត្យមើលសន្លូងស្លដែកបុរាណ និងទប់ស្កាត់ក្រុមហ៊ុន ប៉ូ ខូច ដែលបានដុតព្រៃ និងឈូសលុបស្រះនៅឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ និងបានចុះសិក្សាដល់ទីតាំងជាមួយយុវជនជនជាតិដើមភាគតិចគួយ ដើម្បីសិក្សាអំពីការកំណត់តំបន់ការពារសន្លូងស្លដែកបុរាណ
- បានសហការជាមួយក្រុមការងារក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ចុះពិនិត្យមើលទីតាំងត្រូវដាក់ស្លាកសញ្ញា និងរនាំងបាំងផ្លូវមិនឲ្យរថយន្តធុនធ្ងន់ឆ្លងកាត់ចូលប្រាសាទសំបូរព្រៃគុក
- បានពិនិត្យវាយតម្លៃទួលបុរាណចំនួន១ទួល ដែលពាក់ព័ន្ធករណីឈូសបំផ្លាញទួលបុរាណ នៅក្រុងស្ទឹងសែន
- បានទទួលភ្ញៀវចូលទស្សនាសារមន្ទីរខេត្តចំនួន២៣៨នាក់ (អន្តរជាតិចំនួន១០៨នាក់) ប្រាសាទសំបូរព្រៃគុកចំនួន១០៦.១៣៧នាក់ (អន្តរជាតិចំនួន៧  .០២៧នាក់) រមណីយដ្ឋានភ្នំសន្ទុកចំនួន៣៩.៥០៩នាក់ (អន្តរជាតិចំនួន៥៦៧នាក់) និងវត្តប្រាសាទចំនួន៤៧៣នាក់ (អន្តរជាតិចំនួន២៨១នាក់)
- កិច្ចសហការជាមួយអង្គការ WASEDA ៖
    - បានបន្តជួសជុល សម្អាតស្មៅ និងយកល្បាស់នៅប្រាសាទ N1

## ***មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ស្ពឺ ៖***

- បានចុះពិនិត្យវត្ថុបុរាណនៅសារមន្ទីរនរៈបុរី
- បានទទួលភ្ញៀវចូលទស្សនាសារមន្ទីរនរៈបុរីសរុបចំនួន៣.៩១៨នាក់
- បានទទួលវត្ថុសិល្បៈ "ចាន" អំពីដីដុតចំនួន០៣ ពីប្រជាពលរដ្ឋ
- បានចុះពិនិត្យឆ្អឹងដំរីដែលបានរក្សាទុកនៅវត្តភ្នំបាត
- បានចុះពិនិត្យទួលអង្គមួយកន្លែង នៅសង្កាត់រការធំ ក្រុងច្បារមន

- បានសហការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រុមការងារជំនាញរបស់អាឡឺម៉ង់ចុះសិក្សាស្រាវជ្រាវល្អាងភ្នំរមណីយដ្ឋានបុរាណវិទ្យាភ្នំចាស់ និងល្អាងភ្នំព្រះ
- បានចុះពិនិត្យ ស្រាវជ្រាវផលប៉ះពាល់លើសម្បត្តិបេតិកភណ្ឌវប្បធម៌នៅស្រុកសំពោងទង ដែលស្ថិតក្នុងការសិក្សាគម្រោងផ្លូវថ្មីរបស់រាជរដ្ឋាភិបាល
- បានចូលរួមប្រជុំពិគ្រោះយោបល់ ស្តីពីការវាយតម្លៃហេតុផលការប៉ះពាល់បរិស្ថានសង្គមដំបូងរបស់ក្រុមហ៊ុនកិនថ្មភ្នំជាល
- បានសហការជាមួយអាជ្ញាធរពាក់ព័ន្ធ ចុះណែនាំប្រជាពលរដ្ឋឲ្យបញ្ឈប់ការឈូសឆាយដីព្រៃក្នុងតំបន់ដែនការពាររមណីយដ្ឋានភ្នំព្រះ

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពត ៖</u>***

- បានសហការជាមួយគ្រប់ការិយាល័យវប្បធម៌ស្រុក-ក្រុងក្នុងការការពារ និងថែរក្សាបុរាណស្ថាន និងបុរាណវត្ថុដែលត្រូវបានរក្សាទុកដោយសហគមន៍មូលដ្ឋាន និងវត្តអារាម
- បានចុះត្រួតពិនិត្យ និងធ្វើកំណត់ហេតុលើសកម្មភាពសាងសង់សំណង់នៅតំបន់ការពារប្រាសាទភ្នំឈ្ងោក នៅស្រុកទឹកឈូ និងការលួចជីកកកាយទួលអង្គរាំង នៅស្រុកជុំគីរី
- បានសហការជាមួយនាយកដ្ឋានបុរាណវិទ្យា និងបុរេប្រវត្តិវិទ្យា ចុះកំណត់បុរាណស្ថានដើម្បីកសាងផែនទីបុរាណវិទ្យារបស់ស្រុកឈូក
- បន្តត្រួតពិនិត្យ ចងក្រងឯកសារប្រវត្តិវត្ថុបុរាណក្នុងសារមន្ទីរ

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកោះកុង ៖</u>***

- បានថែរក្សា និងបោសសម្អាតកន្លែងព្រះអង្គគោកធ្លក ចេតិយយុន ឆាង ទីលានទាត់សី មឈូសបុរាណ និងអណ្តូងថ្ម ដោយបានសហការជាមួយក្រុមអភិរក្ស និងជួសជុលកុលាលភាជន៍នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានចាក់ដីនៅផ្លូវចូលចេតិយយុន ឆាង បានប្រវែង១.២០០ម៉ែត្រ
- បានចាក់បេតុងនៅកន្លែងចតឡានព្រះអង្គគោកធ្លក និងធ្វើស្លាកសញ្ញាបង្ហាញផ្លូវចូលព្រះអង្គគោកធ្លកចំនួន១ផ្ទាំង (ទំហំ២.៥ម៉ែត្រ គុណ២.៥ម៉ែត្រ)
- បានជួសជុលកុលាលភាជន៍មួយចំនួនធំដែលបាក់បែកនៅមន្ទីរ
- ទទួលភ្ញៀវទេសចរណ៍ចូលទស្សនាស្ថានីយពាងបុរាណ មឈូសបុរាណ ភ្នំពែល និងភ្នំអូរកីសរុបចំនួន៦៩៩នាក់

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តក្រចេះ ៖</u>***

- បានចុះទៅដឹកសិលាចារឹកចំនួន០១ដុំ ពីឃុំថ្មី ស្រុកចិត្របុរី ដើម្បីយកមករក្សាទុកនៅសារមន្ទីរខេត្ត
- បានបញ្ចូលវត្ថុបុរាណទុកក្នុងសារមន្ទីរចំនួន០៣ដុំ (យោនី ជើងទម្រយោនី និងសិលាចារឹក)
- បានទទួលភ្ញៀវចូលទស្សនាសារមន្ទីរខេត្តចំនួន១៩នាក់ និងអាគារបុរាណរកាកណ្តាលចំនួន២៨០នាក់ (អន្តរជាតិចំនួន១៥២នាក់)

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តតាកែវ ៖</u>***

- បានធ្វើសាលាកបត្រស្ថានីយបុរាណចំនួន២២៦សាលាកបត្រ ជូនទៅសាលាខេត្តដើម្បីទទួលស្គាល់ជាផ្លូវការ
- បានរៀបចំឯកសារកែតម្រូវស្ថានីយបុរាណនៅស្រុកព្រៃកប្បាស
- បានថែរក្សាវត្ថុបុរាណដែលមាននៅក្នុងសារមន្ទីរខេត្ត និងសារមន្ទីរស្រុកអង្គរបុរី
- បានសហការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ប្រជុំគណៈកម្មការមណ្ឌលឧក្រិដ្ឋកម្មនៅស្រុកត្រាំកក់ ដើម្បីអភិរក្សអដ្ឋិធាតុនៅទីនោះ
- បានសហការជាមួយនាយកដ្ឋានបុរាណវិទ្យា អាជ្ញាធរស្រុកត្រាំកក់ និងសាលាខេត្តតាកែវ បញ្ជូនអដ្ឋិធាតុនៅមណ្ឌលឧក្រិដ្ឋកម្មក្រាំងតាចាន់ ឃុំគុស ទៅធ្វើការអភិរក្សនៅមណ្ឌលឧក្រិដ្ឋកម្មជើងឯក ដែលមានលលាដ៍ក្បាលចំនួន១.៨០៨ និងបំណែកគ្រោងឆ្អឹងមួយចំនួនទៀត
- បានសហការជាមួយមន្ត្រីជំនាញក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងអាជ្ញាធរពាក់ព័ន្ធ ចុះបោះបង្គោលដែនការពារប្រាសាទភ្នំជីសូរ្យបានចំនួន១៨បង្គោល
- បានសហការជាមួយអាជ្ញាធរស្រុកសំរោងផ្សព្វផ្សាយច្បាប់ការពារបេតិកភណ្ឌនៅស្រុកសំរោងដែលមានប្រជាពលរដ្ឋចូលរួមចំនួន៥០នាក់
- បានសហការជាមួយនាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណ ជួសជុលប្រាសាទនាងខ្មៅនៅស្រុកសំរោង
- បានចុះពិនិត្យទួលរកា នៅស្រុកព្រៃកប្បាស ដែលប្រជាពលរដ្ឋបានសង់លំនៅដ្ឋានលើទីទួលបុរាណនោះ
- បានទទួលភ្ញៀវចូលទស្សនាសារមន្ទីរខេត្តចំនួន១១៧នាក់ (អន្តរជាតិចំនួន២៦នាក់) និងសារមន្ទីរស្រុកអង្គរបុរីចំនួន២.០៦៨នាក់ (អន្តរជាតិចំនួន១១៨នាក់)

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តត្បូងឃ្មុំ ៖</u>***

- មន្ត្រីកម្មសិក្សាចំនួន៨នាក់ បានចុះសិក្សាពិនិត្យស្ថានភាពនៅទួលប្រាសាទ ឬទួលព្រះធាតុ ស្រុកអូរាំងឪ (ក្នុងវិទ្យាល័យ ហេង សំរិន) ដែលទួលនេះទទួលរងការជីកកកាយ និងកាប់ព្រៃនៅតំបន់នោះ ដែលបច្ចុប្បន្នឃើញមានដាំដើមឈើឡើងវិញផងដែរ
- មន្ត្រីកម្មសិក្សាចំនួន០៣រូប បានប្រើប្រាស់ឧបករណ៍ GPS លើប៉ម ក្នុងស្រុកក្រូចឆ្មារដើម្បីកំណត់ច្បាស់លាស់
- មន្ត្រីកម្មសិក្សាចំនួន០៣រូប បានប្រើប្រាស់ឧបករណ៍ GPS លើប្រាសាទ និងទួលទំទាវ ទួលផ្ទះយាយផាន់ នៅស្រុកត្បូងឃ្មុំ ដើម្បីចុះក្នុងបញ្ជីសារពើភណ្ឌបេតិកភណ្ឌរបស់មន្ទីរ
- បានចែកជា២ក្រុមចុះវាស់វែង និងយកនិយាមការ ៖ ទួលព្រះធាតុ និងទួលអំបែងចេះ នៅស្រុកត្បូងឃ្មុំ ប្រាសាទព្រៃអង្គរក្នុង ប្រាសាទព្រះធាតុតូច ទួលដើមពោន ទួលត្រពាំងក្រវ៉ាន់ ទួលដូនទាវ
- មន្ត្រីកម្មសិក្សាចំនួន០៣រូប បាន ចុះវាស់វែងប៉ម នៅស្រុកក្រូចឆ្មារ ទួលកកោះ និង ទួលកំពង់ទឹកនៅស្រុកពញាក្រែក និងទួលទំទាវ ទីទួលបុរាណ និងអណ្តូង នៅស្រុកត្បូងឃ្មុំ
- មន្ត្រីកម្មសិក្សាចំនួន០៣រូប បានចុះយកនិយាមការស្ថានីយជាច្រើនកន្លែងដែល ស្ថិតនៅក្នុងស្រុកមេមត់ និងស្រុកអូរាំងឪ

- បានសហការជាមួយមន្ទីរធម្មការ និងសាសនាខេត្ត ចុះទៅត្រួតពិនិត្យ និងសម្របសម្រួលដីប្រាសាទព្រះធាតុបាស្រី ស្ថិតនៅឃុំព្រះធាតុ ស្រុកអូរាំងឪ ដែលប៉ះពាល់ក្បាលដីកម្មសិទ្ធិរបស់ប្រជាពលរដ្ឋ៨៧គ្រួសារ (ភូមិព្រះធាតុកណ្តាល៥០គ្រួសារ និងភូមិព្រះធាតុថ្មដា៣៧គ្រួសារ)
- បានចុះពិនិត្យស្ថានភាពសារមន្ទីរមេមត់ និងស្រង់ស្ថិតិវត្ថុសិល្បៈ ដែលកំពុងរក្សាទុកនៅសារមន្ទី

## *មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តបន្ទាយមានជ័យ ៖*

- បានចុះផ្សព្វផ្សាយទប់ស្កាត់សកម្មភាពបំផ្លាញស្ថានីយបុរាណនៅស្រុកអូរជ្រៅ
- បានរៀបចំស្លាកសញ្ញាបង្ហាញផ្លូវចូលទៅប្រាសាទតាព្រហ្មចំនួន១ផ្ទាំង និងសារមន្ទីរបុរាណវិទ្យាទេពកោសា-ស្នាយចំនួន១ផ្ទាំង
- បានរៀបចំដាក់បង្គោលភ្លើងនៅផ្លូវចូលប្រាសាទបន្ទាយឆ្មារ (ខាងកើត) ចំនួន៣បង្គោល
- បានសហការចុះវាស់វែងកំណត់ព្រំប្រាសាទធំ នៅឃុំតាគង់ ស្រុកម៉ាឡៃ
- បានចុះស្រង់បញ្ជីសារពើភណ្ឌរូបីនៅឃុំណាំតៅ
- បានរៀបចំដាក់នាំងឈើការពាររូបលោកេស្វារៈ នៅប្រាសាទបន្ទាយឆ្មារចំនួន៤០ម៉ែត្រ
- បានចុះត្រួតពិនិត្យ វាយតម្លៃ និងធ្វើកំណត់ហេតុវត្ថុបុរាណ ដែលរក្សាទុកដោយប្រជាពលរដ្ឋមួយគ្រួសារ
- បានទទួលវត្ថុបុរាណពីប្រជាពលរដ្ឋចំនួន៤០ដុំ និងបំណែកមួយចំនួនទៀត
- បានថែរក្សា និងត្រួសត្រាយព្រៃសម្អាតនៅប្រាសាទបន្ទាយឆ្មារ
- បានចុះណែនាំដល់ក្រុមហ៊ុនដឹកដីមិនឲ្យចាក់ដីលុបស្រះបុរាណ នៅស្រុកភ្នំស្រុក
- បានថែរក្សា និងត្រួសត្រាយព្រៃសម្អាតនៅប្រាសាទបន្ទាយឆ្មារបានចំនួន៦៣ .៧៩៥ម៉ែត្រការ៉េ និងនៅប្រាសាទបន្ទាយទ័ពចំនួន១១៧.២២៩ម៉ែត្រការ៉េ
- បានទទួលភ្ញៀវចូលទស្សនាសារមន្ទីរខេត្តសរុបចំនួន៨២៥នាក់(ភ្ញៀវអន្តរជាតិ២៥នាក់)ប្រាសាទបន្ទាយឆ្មារចំនួន៩៥.៨២៨នាក់ (ភ្ញៀវអន្តរជាតិ៨២៨នាក់) ប្រាសាទបន្ទាយទ័ពចំនួន១.៦៣៥នាក់ (ភ្ញៀវអន្តរជាតិ៨នាក់) និងចូលសារមន្ទីរបុរាណវិទ្យាទេពកោសា -ស្នាយចំនួន១៨៤នាក់ (ភ្ញៀវអន្តរជាតិ១២នាក់)

## *មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តបាត់ដំបង ៖*

- បានចុះទៅកំណត់ទួលបុរាណបានចំនួន៩ទួលគឺ ទួលអ្នកតាមួយ ទួលអ្នកតាពីរ ទួលចាស់ ទួលបឹងថ្ម ទួលបឹងក្រោល ទួលពោន ឬ ទួលពួន ទួលធាតុ ទួលព្រៃភូមិ ឬព្រៃវត្ត និងទួលព្រះអង្គកែវ
- បានរៀបចំត្រួតពិនិត្យលើសមុច្ច័យ និងបោះពុម្ពសាលាកបត្រសមុច្ច័យធ្វើពីថ្មចំនួន១០០សន្លឹក
- បានទទួលវត្ថុសិល្បៈចំនួន០១រូប គឺ "រូបដំរីស្ពាន់"
- បានទទួលវត្ថុបុរាណចំនួន៥គឺ "ដងខ្លួនទេវរូបភេទប្រុស" កំពស់៨០ស .ម បាក់ជាបួនបំណែក "ដងខ្លួនទេវរូបភេទប្រុស" កំពស់៣១ស .ម បាក់ជាពីរបំណែក "ដងខ្លួនទេវរូបភេទប្រុស" កំពស់១៥ស.មមួយកំណាត់ "ជើងទេវរូបភេទស្រី" កំពស់១៩ស .ម មួយកំណាត់ និង "ដងខ្លួនទេវរូបភេទប្រុសអង្គុយ" កំពស់២៣ស.ម បាក់ជាពីរបំណែក មកពីប្រាសាទបាសែត ដែលបានរកឃើញដោយក្រុមការងារជួសជុលប្រាសាទបាសែត នៃនាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណ និងបានចុះបញ្ជីសារពើភណ្ឌ
- បានចុះទៅស្រាវជ្រាវស្ថានីយបុរាណនៅភ្នំដូនមាយ ក្នុងស្រុករតនមណ្ឌល និងនៅភ្នំតាគ្រាម ក្នុងស្រុកបាណន់

- បានចុះទៅពិនិត្យថ្មបុរាណនៅស្រុកឯកភ្នំ និងស្រុកថ្មគោល
- បានចុះដោះស្រាយទំនាស់ដីនៅទួលអន្លក់ ស្ថិតនៅស្រុកបវេល
- បានចុះផ្ទៀងផ្ទាត់ប្លង់ទួលបុរាណចំនួន៧ នៅស្រុកបាណន់
- បានត្រួតពិនិត្យវត្ថុសិល្បៈឆ្លាក់ថ្មីចំនួន១៧រូប ក្នុងនោះធ្វើអំពីស្ពាន់ចំនួន០៦រូប និងអំពីឈើចំនួន១១រូប
- បានទទួលភ្ញៀវចូលទស្សនាសារមន្ទីរខេត្តសរុបចំនួន៦៣៦នាក់ (អន្តរជាតិចំនួន១៦៧នាក់)

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តពោធិ៍សាត់ ៖</u>***

- បានចុះពិនិត្យទីទួលគ្រឹះប្រាសាទ ស្ថិតនៅវត្តសុវណ្ណស្លាកែត
- បានចុះពង្រឹងឆ្មាំការពារទីតាំងធ្វើកំណាយនៅឃុំក្បាលត្រាច ស្រុកក្រគរ
- បានចុះពិនិត្យវត្ថុបុរាណចំនួន២ដុំ (ប្រនាល ឬយោនី) នៅភូមិកោះស្វាយ
- បានចុះដឹកថ្មសីមាបុរាណចំនួន៥ដុំ នៅទួលព្រះធាតុញីឈ្មោល ដែលត្រូវបានជនមិនស្គាលមុខជីកគាស់កាយ
- បានចុះពិនិត្យទីទួលបុរាណចំនួន២ទួល នៅក្រុងពោធិ៍សាត់ និងស្រុកកណ្ដៀង
- បានចុះពិនិត្យកុដិបុរាណ និងរូបគំនូរនៅព្រះវិហារវត្តសុរិយា នៅក្រុងពោធិ៍សាត់
- បានចុះទៅស្រាវជ្រាវរឿងដីធ្លីដែលប្រជាពលរដ្ឋនាំគ្នារុករានព្រៃយកដីនៅជុំវិញល្អាង១២ ស្ថិតនៅឃុំក្រពើពីរ ស្រុកវាលវែង
- បានចុះពិនិត្យបង្គោលព្រំខាងជើង និងខាងកើត នៅស្ថានីយថ្មបាយក្រៀមដែលត្រូវបានគ្រឿងចក្ររុញដីប៉ះបណ្ដាលឲ្យបាក់រលំ
- បានចុះទៅស្រាវជ្រាវរឿងដីធ្លីដែលប្រជាពលរដ្ឋនាំគ្នារុករានព្រៃយកដីនៅជុំវិញល្អាង១២ ស្ថិតនៅឃុំក្រពើពីរ ស្រុកវាលវែង
- បានចុះពិនិត្យបង្គោលព្រំខាងជើង និងខាងកើត នៅស្ថានីយថ្មបាយក្រៀមដែលត្រូវបានគ្រឿងចក្ររុញដីប៉ះបណ្ដាលឲ្យបាក់រលំ
- បានចុះសិក្សាស្រាវជ្រាវថ្មខ្មៅនៅកណ្ដាលបឹងទន្លេសាប ក្នុងស្រុកកំពង់សំណរ និងបានធ្វើការសន្និដ្ឋានថាជាថ្មបុរាណ
- បានចុះស្រាវជ្រាវរកឃើញបឹងថ្មគួត ទួលថ្មីគួត ទួលកោះ និងទួលបឹងកន្ទួត ដោយបានធ្វើការសម្ភាសលោកតាម្នាក់អំពីប្រវត្តិបឹង និងទួលទាំងនោះ នៅស្រុកកណ្ដៀង
- បានចុះពិនិត្យ និងសំណូមពរទៅអធិការវត្តហ្លួង រក្សាទុកវត្ថុបុរាណមួយចំនួនដូចជាផ្តិល ឆ្នាំងល្ងា ឆ្នាំងស្ពាន់រក្សាទុកចុះបញ្ជីជាសម្បត្តិក្រៅឃ្លាំងក្នុងវត្ត

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តព្រៃវែង ៖</u>***

- បានគូរគំនូរនៅអាស្រមលោកយាយទេព លោកយាយមៅ ដោយប្រើប្រាស់ថវិកាសប្បុរសជន
- បានរៀបចំឥដ្ឋកន្សែងពីផ្លូវអាស្រមលោកយាយ ទៅដល់អាស្រមលោកតាខ្លោងទ្វារចំនួន២៧០ម៉ែត្រការ៉េ ដោយប្រើប្រាស់ថវិកាសប្បុរសជន
- បានចាក់ដីចំនួន២៨០ម៉ែត្រគីប ធ្វើដំបូលសាលាឆាន់ចំនួន១៥៨ម៉ែត្រការ៉េ និងបាន បូមទឹកដាក់ក្នុងកសិណ នៅទួលបារាយណ៍អណ្ដែត ដោយប្រើប្រាស់ថវិកាសប្បុរសជន
- បានជួសជុលវិហារលោកតាសំរិត លោកតាសំពៅ ដោយប្រើប្រាស់ថវិកាសប្បុរសជន

- បានទទួលវត្ថុបុរាណ "លិង្គព្រះឥសូរ" អំពីថ្មក្រានីត ទទឹង០ .២០ស.ម និងបណ្តោយ០ .៧០ស.ម ពីស្រុកពារាំង យកមករក្សាទុកនៅក្នុងសារមន្ទីរខេត្ត
- បានចុះពិនិត្យវត្ថុបុរាណនៅវត្តពោធិទង នៅស្រុកកញ្ជៀច និងនៅសាលពិព័រណ៍ស្រុកបាភ្នំ
- បានចុះពិនិត្យទួលបុរាណនៅស្រុកបាភ្នំ ស្រុកពាមជរ និងស្រុកកំពង់ត្របែក
- បានចុះផ្សព្វផ្សាយច្បាប់ស្តីពីការការពារបេតិកភណ្ឌ នៅក្រុងព្រៃវែង
- បានសហការជាមួយនាយកដ្ឋានបុរាណវិទ្យា និងបុរេប្រវត្តិវិទ្យា ចុះបោះបង្គោលការពារនៅទួលអំបែង ក្រុងព្រៃវែងចំនួន១២បង្គោល និងនៅទួលព្រះអង្គពោធិ ស្រុកបាភ្នំ ចំនួន០៦បង្គោល
- បានទទួលភ្ញៀវចូលទស្សនាសារមន្ទីរខេត្តចំនួន៨៣នាក់

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តព្រះវិហារ ៖</u>***

- បានចុះទៅក្រុមហ៊ុន អេហ្វភី ម៉ាឡេស៊ី ដើម្បីធ្វើចំណាត់ថ្នាក់ដី និងវាស់វែង នៅស្រុកគូលែន
- បានចុះពិនិត្យទីតាំងប្រាសាទនៅឃុំម្លូព្រៃមួយ ស្រុកឆែប
- បានចុះទៅដោះស្រាយបញ្ហាដីនៅជុំវិញប្រាសាទដីខ្មៅ នៅស្រុកគូលែន
- បានសហការជាមួយក្រុមការងារក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ធ្វើការចុះបញ្ជីបុរាណវត្ថុ នៅប្រាសាទខ្នាសែនកែវ ស្រុកគូលែន នៅប្រាសាទខ្នា ស្រុកជាំក្សាន្ត និងចុះបញ្ជីវត្ថុបុរាណដែលរក្សាទុកក្នុងសាឡាំព្រៃអារក្សដេក នៅស្រុកជ័យសែន
- បានទទួលភ្ញៀវចូលទស្សនាតាមប្រាសាទនានាចំនួន៣.៦៨៤នាក់ (អន្តរជាតិចំនួន១៧១នាក់)
- បានត្រួសត្រាយព្រៃសម្អាតតាមប្រាសាទបុរាណចំនួន២៩៧.៧៥៥ម៉ែត្រការ៉េ

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តមណ្ឌលគិរី ៖</u>***

- បានទៅពិនិត្យកន្លែងដាក់កូនដំរីថ្ម០១គូរនៅផ្លូវចូលអាស្រមលោកតាខាងក្រោម ដែលសប្បុរសជននៅរាជធានីភ្នំពេញបានទិញដាក់នៅទីនោះ
- បានចុះប្រមូលទិន្នន័យ និងស្រង់ស្ថិតិបេតិកភណ្ឌវប្បធម៌ដែលមាននៅក្នុងខេត្ត
- បានទទួលធុងសម្រាមពីសាលាក្រុងសែនមនោរម្យចំនួន០៤ធុង សម្រាប់ដាក់នៅលើភ្នំដោះក្រមុំ
- ក្រុមហ៊ុនប្រេងឥន្ធនៈតេលា (TELA) បានជួយសង់ទ្វារដែកទំហំ០៥ម៉ែត្រការ៉េដាក់បិទមុខអាស្រមភ្នំលោកយាយផ្លំ

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តរតនគិរី ៖</u>***

- បានចុះពិនិត្យបង្គោលព្រំប្រាសាទយ៉ាក់ណាំង និងធ្វើការសម្អាតព្រៃនៅប្រាសាទយ៉ាកណាំង នៅស្រុកអូរយ៉ាដាវ
- បានចុះត្រួតពិនិត្យ និងដាក់ស្លាកសញ្ញាហាមឃាត់ការកាប់រានព្រៃឈើនៅតំបន់គ្រឹះប្រាសាទព្រះពុទ្ធ នៅស្រុករ៉ុនសៃ
- បានចុះពិនិត្យ និងធ្វើការហាមឃាត់ការកាប់រានដីព្រៃឈើរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់អភិរក្សភ្នំខ្វាញ់ ស្រុកអូរយ៉ាដាវ
- បានចុះត្រួតពិនិត្យ និងធ្វើការហាមឃាត់ប្រជាពលរដ្ឋ ចូលកាប់រានព្រៃឈើនៅតំបន់គ្រឹះប្រាសាទព្រះពុទ្ធ នៅស្រុករ៉ុនសៃ
- បានចុះត្រួតពិនិត្យការកាប់រានព្រៃនៅតំបន់អភិរក្សភ្នំយក្សពើង ស្រុកបរកែវ

- បានចុះបោះបង្គោលព្រំ និងដាក់ស្លាកសញ្ញាហាមឃាត់ការកាប់រានព្រៃឈើនៅតំបន់យក្សពើង ស្រុកបរកែវ

## *មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តសៀមរាប ៖*

- បានផ្សព្វផ្សាយសេចក្តីសម្រេចលេខ០១ស.រ ស្តីពីការកំណត់បរិវេណប្រាសាទ ទីទួល ស្រះ ត្រពាំង ស្ពានបុរាណ នៅក្រុងសៀមរាប ស្រុកស្រីស្នំ ស្រុកជីក្រែង ស្រុកអង្គរជុំ ស្រុកវ៉ារិន និង ស្រុកពួក
- បានចុះធ្វើការណែនាំដល់ប្រជាពលរដ្ឋចំនួន១៩គ្រួសារឲ្យបញ្ឈប់ការចាក់ដីរំលោភយកដីចំណីត្រពាំង នគរភា សស្ថិតនៅឃុំនគរភា សស្រុកអង្គរជុំ
- បានចុះពិនិត្យរូបចម្លាក់បដិមាថ្មនៅស្រុកសូទ្រនិគម
- បានចុះពិនិត្យមើលរូបដែលប្រជាពលរដ្ឋជីកដីធ្វើផ្ទះឃើញព្រះសិរៈចំនួន០១ព្រះអង្គ ធ្វើអំពីសំរិទ្ធ មានកំពស់០,៣១ម៉ែត្រ ទម្ងន់១,៧គីឡូក្រាម ស្ថិតនៅឃុំបាគង ស្រុកប្រាសាទបាគង និង បានយកមករក្សាទុកនៅមន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្ត
- បានសហការជាមួយអាជ្ញាធរមូលដ្ឋានស្រុក ចុះត្រួតពិនិត្យវត្ថុបុរាណទេវរូបស្រី០១ព្រះអង្គ ធ្វើពីថ្មភក់ មានតែខ្លួន អត់ព្រះកេស អត់ជើង មានកំពស់០,៣៣ម និងទទឹង០,១៤ម ដែលត្រូវបានប្រជាពលរដ្ឋប្រទះឃើញនៅបាតត្រពាំងបុរាណស្ថិតនៅឃុំក្តីរុន ស្រុកពួក បច្ចុប្បន្នអាជ្ញាធរអប្សរាបានយកទៅរក្សាទុកនៅសារមន្ទីរព្រះនរោត្តមសីហនុ អង្គរ
- បានសហការជាមួយក្រុមការងារចម្រុះសាលាស្រុកក្រឡាញ់ចុះទប់ស្កាត់ក្រុមហ៊ុនមួយជីកដីធ្វើប្រឡាយ ប៉ះពាល់ជើងប្រាសាទព្រៃល្វៀង ស្ថិតនៅឃុំស្នួល ស្រុកក្រឡាញ់ ជាលទ្ធផលខាងក្រុមហ៊ុនបានយល់ព្រមលុបប្រឡាយឲ្យដូចដើមវិញ
- បានសហការជាមួយអាជ្ញាធរស្រុកសូទ្រនិគមចុះត្រួតពិនិត្យនិងធ្វើកោសល្យវិច្ច័យវត្ថុបុរាណមួយដុំធ្វើអំពីថ្មភក់ មិនទាន់ឆ្លាក់រួចដែលមានកំពស់៨០ស.ម និងទទឹង៥៣ស.ម បានយកមករក្សាទុកនៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តជាបណ្តោះអាសន្ន
- បានសហការជាមួយអាជ្ញាធរជាតិអប្សរា និងអាជ្ញាធរស្រុកអង្គរធំចុះត្រួតពិនិត្យទូកឈើបុរាណចំនួន០១មានបណ្តោយ១២,៨៣ម៉ែត្រ ទទឹង០,៦៨ម៉ែត្រ ដែលអាជីវករបូមខ្សាច់ប្រទះឃើញក្នុងជម្រៅប្រមាណ៦ម៉ែត្រស្ថិតនៅតំបន់ស្ទឹងបុរាណ ឃុំលាងដៃ ស្រុកអង្គរធំ និងបានយកមករក្សាទុកនៅអាជ្ញាធរជាតិអប្សរា
- ទទួលឲ្យភ្ញៀវចូលទស្សនាសារមន្ទីរជាតិអង្គរសរុបមានចំនួន៨.២៣៩នាក់ (ភ្ញៀវអន្តរជាតិចំនួន ៧.៨៩៣នាក់) សារមន្ទីរព្រះនរោត្តមសីហនុចំនួន២.៣៧៥នាក់(ភ្ញៀវអន្តរជាតិចំនួន២.៣១៥នាក់) សារមន្ទីរវត្តរាជបូព៌ចំនួន២.០០០នាក់ (ភ្ញៀវអន្តរជាតិចំនួន១ .៨៤៨នាក់) និងមណ្ឌលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ចំនួន៣៧.៥៥២នាក់ (ភ្ញៀវអន្តរជាតិចំនួន៣៦.៦៤៧នាក់)

## *មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តស្ទឹងត្រែង ៖*

- បានធ្វើបញ្ជីសារពើភណ្ឌស្តីពីស្ថានីយបុរាណ និងទួលបុរាណដែលបានរកឃើញទាំងថ្មីទាំងចាស់ មានស្ថានីយចំនួន៦៩ស្ថានីយ

- បានចុះត្រួតពិនិត្យនៅទួលប្រាសាទគួរដែលត្រូវបានគេឈូសឆាយធ្វើផ្លូវចូល ឃើញថាពុំមានការប៉ះពាល់ដល់ទួលប្រាសាទឡើយ
- បានចុះពិនិត្យទួលប្រាសាទពង្រ នៅស្រុកសេសាន
- បានចុះពិនិត្យមើលទីតាំងដែលប្រជាពលរដ្ឋសុំសាងសង់សំណង់រឹងមួយកន្លែងចំងាយប្រហែល ២០០ម៉ែត្រពីប៉ែកខាងលិចប្រាសាទព្រះគោ នៅជិតទួលអង្គខ្មៅ ឃើញថាពុំមានប៉ះពាល់ស្ថានីយបុរាណទេ នៅស្រុកថាឡាបរិវ៉ាត់
- បានចុះត្រួតពិនិត្យការឈូសឆាយផ្លូវខាងលិចប្រាសាទព្រះគោ ឃើញថាពុំមានប៉ះពាល់ទួលប្រាសាទទេ នៅស្រុកថាឡាបរិវ៉ាត់
- បានចុះធ្វើការណែនាំដល់លោកគ្រូនៅអនុវិទ្យាល័យថាឡាបរិវ៉ាត់ពីបញ្ហាការឈូសឆាយដីពីព្រោះ នៅស្រុកថាឡាបរិវ៉ាត់សំបូរទៅដោយស្ថានីយបុរាណជាច្រើន និងមុនពេលធ្វើការឈូសឆាយ ឬសង់សំណង់អ្វីមួយត្រូវរាយការណ៍ជូនអាជ្ញាធរមូលដ្ឋាន និងមន្ទីរជំនាញ
- បានចុះទៅទួលប្រាសាទភ្នំធាតុ ដើម្បីធ្វើការបោសសម្អាត និងត្រួតពិនិត្យវត្ថុបុរាណដែលមានស្រាប់
- បានសហការជាមួយមន្ត្រីជំនាញក្រសួងវប្បធម៌ និងវិចិត្រសិល្បៈចំនួន០១នាក់ និងជនជាតិបរទេសចំនួន០៣នាក់ ចុះសិក្សាស្រាវជ្រាវរកឃើញភ្នំចំនួន៥ និងល្អាងចំនួន២៩ នៅស្រុកថាឡាបរិវ៉ាត់

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តស្វាយរៀង</u> ៖***

- បានចុះត្រួតពិនិត្យទួលបុរាណ និងប្រាសាទបុរាណចំនួន៥០លើក
- បានចុះស្រាវជ្រាវវត្ថុបុរាណ និងចងក្រងប្រវត្តិផ្សេងៗចំនួន០២អត្ថបទ
- បានចុះសហការជាមួយអាជ្ញាធរដែនដីធ្វើប្លង់ទួលបុរាណចំនួន២១ប្លង់
- បានផ្សព្វផ្សាយច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌចំនួន០៦លើក
- បានចុះត្រួតពិនិត្យវត្ថុបុរាណនៅតាមទីសាធារណៈ និងវត្តអារាមចំនួន០៧លើក

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តឧត្តរមានជ័យ</u> ៖***

- បានចុះហាមឃាត់ប្រជាពលរដ្ឋដែលមានដីក្បែរប្រាសាទកប់គង កុំឲ្យកាប់ព្រៃទន្ទ្រានដីចូល ក្នុងបរិវេណប្រាសាទ
- បានចុះពិនិត្យប្រាសាទទឹកខ្មៅ ប្រាសាទរលំឆ្កោ ប្រាសាទត្រពាំងបី ប្រាសាទទួលគ្រួស និងប្រាសាទទំនប់អភិវឌ្ឍថ្មី
- បានចុះទប់ស្កាត់ប្រជាពលរដ្ឋមួយគ្រួសារ ដែលបានជីក និងយកស្រះបុរាណធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួនសម្រាប់ចិញ្ចឹមត្រី នៅក្រុងសំរោង
- បានអមដំណើរមន្ត្រីនាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណ ដើម្បីចុះត្រួតពិនិត្យការបែកបាក់ នៃតួប៉មប្រាសាទត្រពាំងបី
- បានសហការជាមួយនាយកដ្ឋានបុរាណវត្ថុចុះបញ្ជីវត្ថុសិល្បៈចំនួន៧៥ដុំដែលស្ថិតនៅប្រាសាទទួលប្រាសាទ និងតាមវត្តអារាមនានាទូទាំងខេត្ត
- បានចុះបញ្ជីវត្ថុសិល្បៈចំនួន០៥ដុំ ដែលទទួលបានពីប្រជាពលរដ្ឋ ព្រះសង្ឃ និងអាចារ្យវត្ត នៅវត្តទំនប់អភិវឌ្ឍថ្មី ក្នុងភូមិអភិវឌ្ឍថ្មី

- បានចុះពិនិត្យប្រាសាទត្រពាំងប្រាសាទ ដែលកំពុងប្រឈមនឹងការបាក់រលំ
- បានចុះពិនិត្យ និងហាមឃាត់ប្រជាពលរដ្ឋដែលបានទន្ទ្រានយកដីលើទួលប្រាសាទតាចាន់មកធ្វើចំការដំឡូង នៅក្រុងសំរោង
- បានចុះកំណត់ព្រំ និងបោះបង្គោលទួលប្រាសាទតាចាន់ និងទួលប្រាសាទភ្នំដី នៅក្រុងសំរោង
- បានចុះត្រួតពិនិត្យ ស្រាវជ្រាវ និងរុករកការជីកកកាយលើទួលប្រាសាទបុរាណស្ថិតនៅស្រុកត្រពាំងប្រាសាទ
- បានចុះពិនិត្យប្រាសាទល្បើកដែលរងគ្រោះថ្នាក់ពីធម្មជាតិ ដើមឈើបាក់រលំ និង បានកាប់ឆ្ការព្រៃសម្អាត
- បានសហការជួសជុលស្ពានទ័ពជាមួយមន្ត្រីជំនាញរបស់នាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណ ។

### ២.៣.៣. អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ ៖

***<u>នាយកដ្ឋានអភិវឌ្ឍវប្បធម៌ ៖</u>***

- បានបន្តទំនាក់ទំនងជាមួយក្រសួងមហាផ្ទៃ ដើម្បីស្នើសុំស្ថិតិអង្គការ សមាគមក្រៅរដ្ឋាភិបាលប្រចាំឆ្នាំ២០១៤-២០១៦
- បានរៀបចំចងក្រងនូវអត្ថបទវប្បធម៌ស្តីពី "ពិធីខួបកំណើតខ្មែរ" និងកំពុងកែសម្រួលពាក្យពេចន៍ខ្លឹមសារដើម្បីដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងកែសម្រួល
- បានរៀបចំតុបតែងលម្អ តាំងពិព័រណ៍រូបថត ហ្វុង បដា សម្រាប់សន្និបាតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈឆ្នាំ២០១៥ មហោស្រពសិល្បៈយុវជនទូទាំងប្រទេសឆ្នាំ២០១៦ ទិវាវប្បធម៌ជាតិ ៣មីនា ឆ្នាំ២០១៦ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០១៦ នៅសាលសន្និសីទចតុមុខ និងនៅនាយកដ្ឋានសិល្បៈទស្សនីយភាព
- បានបន្តរៀបចំសារមន្ទីរខ្លែងខ្មែរ ដើម្បីបើកជូនមហាជនចូលទស្សនា និងសិក្សាស្រាវជ្រាវ

***<u>នាយកដ្ឋានសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ ៖</u>***

- ថតវីដេអូឯកសារពីសកម្មភាពថ្នាក់ដឹកនាំ និងការងារអង្គភាពចំណុះក្រសួង បាន៨១ចំណងជើង។
- បានតម្លើងវីដេអូឯកសារបានចំនួន១៧ចំណងជើង និងកំពុងបន្តតម្លើង
- បានតម្លើងចម្រៀងខារ៉ាអូខេចំនួន០៤ចំណងជើង សម្រាប់អបអរសាទរទិវាវប្បធម៌ជាតិ ០៣មីនា ឆ្នាំ២០១៦ និងចាក់ផ្សាយតាមស្ថានីយទូរទស្សន៍
- បានផលិតនាទីវប្បធម៌សម្រាប់ចាក់ផ្សាយ និងបន្តតម្លើងវីដេអូនាទីវប្បធម៌
- បាន Post នាទីវប្បធម៌ចូលទៅក្នុង YouTube
- បាន Post ចម្រៀងខារ៉ាអូខេ បណ្តាំឪពុក និង បណ្តាំម្តាយ ចូលក្នុង YouTube និង Facebook
- បានដាក់បញ្ចូលសារអប់រំប្រឆាំងគ្រឿងញៀន និងប្រឆាំងអំពើពុករលួយទៅក្នុងផលិតផលចម្រៀងកាយវិការ ខារ៉ាអូខេ
- បានទទួល និងផ្តល់ការអនុញ្ញាតទូរទស្សន៍បរទេសថតភាពយន្តឯកសារបាន១៧ចំណងជើង
- បានផ្តល់អាជ្ញាប័ណ្ណថ្មីធ្វើអាជីវកម្មភាពយន្ត-វីដេអូបាន២០ច្បាប់ និងអនុញ្ញាតបន្តបាន២២ច្បាប់
- បានចុះបញ្ជីសុំផលិតវីដេអូខារ៉ាអូខេខ្មែរបាន៥៨លេខ វីដេអូរឿងភាគខ្មែរបាន០៤ចំណងជើង វីដេអូរឿងខ្មែរ(១ដុំចប់)បាន១២ចំណងជើង
- បានអនុញ្ញាតច្បាប់ថតវីដេអូខារ៉ាអូខេខ្មែរបាន៣៧លេខ វីដេអូរឿងខ្មែរ(១ដុំចប់)បាន០២ចំណងជើង និងស្ប៉តខ្លីៗបាន០១ចំណងជើង

- បានផ្តល់ទិដ្ឋាការឲ្យធ្វើអាជីវកម្មដល់វីដេអូខាវ៉ាអូខេខ្មែរបាន៥៣លេខ វីដេអូខ្មែរ(០១ដុំចប់)បាន ២០ចំណងជើង
- បានផ្តល់ទិដ្ឋាការឲ្យធ្វើអាជីវកម្មដល់វីដេអូរឿងបរទេស (ភាយ) បាន១២២ ចំណងជើង វីដេអូរឿងភាគបរទេសបាន៦ចំណងជើង និងចុះបញ្ជីកាសែតនាំចូលពីបរទេសបាន១៩១ចំណងជើង
- បានទទួលចំណូលពីការផ្តល់សេវាកម្មភាពយន្ត-វីដេអូ សរុបចំនួន**៥៣.៩១៥.០០០រៀល** បង់ចូលថវិការដ្ឋ

***<u>នាយកដ្ឋានសិល្បៈទស្សនីយភាព៖</u>***

- បានប្រគំតន្ត្រី និងសម្តែងសិល្បៈទាំងមហាជន និងអាជីព សរុបចំនួន១.៦៧០លើក ក្នុងនោះនាយកដ្ឋានសិល្បៈសម្តែងក្នុងស្រុកបាន៧៣លើក និងនៅក្រៅប្រទេសបាន០៥លើក
- ក្រុមសិល្បៈបន្តហាត់សម និងតម្លើងស្នាដៃសិល្បៈសម្រាប់សម្តែងក្នុងស្រុក និងក្រៅប្រទេស
- លោកគ្រូ អ្នកគ្រូនៃនាយកដ្ឋានសិល្បៈទស្សនីយភាព បានបង្ហាត់ដល់សិល្បករ សិល្បការិនី ដែលមកចូលរួមក្នុងមហោស្រពសិល្បៈយុវជនទូទាំងប្រទេស

***<u>នាយកដ្ឋានសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម ៖</u>***

- បានជ្រើសរើសប្រធានបទសម្រាប់មហោស្រពសិល្បៈជាតិ គំនូរបុរាណ ឆ្នាំ២០១៦ ស្តីពី "ហនុមានចៃចង់នាងសុវណ្ណមច្ឆា"
- បានចូលរួមរៀបចំ Logo (គំនូរព្រាង) សម្រាប់មហោស្រពយុវជនកម្ពុជា
- បានចូលរួមរៀបចំគំនូរព្រាងក្បាច់ផ្កាសម្រាប់តុបតែងលម្អក្នុងពិធីអង្គរសង្ក្រាន្តឆ្នាំ២០១៦
- បានរៀបចំរូបថតស្តីពីសម្ភារៈសិប្បកម្ម និងកសិកម្មសម្រាប់ចូលរួមតាំងពិព័រណ៍អាស៊ាននៅប្រទេសមីយ៉ាន់ម៉ា
- បានចូលរួមសិក្ខាសាលា និងទទួលពានរង្វាន់ " The CLMTV Contemporary Arts Awards" នៅសាកលវិទ្យាល័យ MAHASARAKHAM ប្រទេសថៃ
- បានចូលរួមសិក្ខាសាលាស្តីពី ASEAN MOTIF នៅសាធារណរដ្ឋឥណ្ឌូនេស៊ី
- បានចូលរួមកម្មវិធី A GROUP EXHIBITION OF ASEAN CHINA ACADEMIES OF Fine Arts (GEACAFA) នៅសាធារណរដ្ឋប្រជាមានិតចិន
- បានរៀបចំសេចក្តីជូនដំណឹង និងគណៈកម្មការ អនុគណៈកម្មការរៀបចំ មហោស្រពសិល្បៈជាតិ គំនូរបុរាណ ឆ្នាំ២០១៦ ស្តីពី "ហនុមានចៃចង់នាងសុវណ្ណមច្ឆា"
- បានសហការជាមួយសហភាពសហព័ន្ធយុវជនកម្ពុជា កែសម្រួលក្បាច់រចនាក្លោងទ្វារសម្រាប់ព្រឹត្តិការណ៍អង្គរសង្ក្រាន្តឆ្នាំ២០១៦
- បានផ្សព្វផ្សាយនូវស្នាដៃផ្នែកចម្លាក់ស្ពាន់ របស់សិប្បករក្នុងខេត្តសៀមរាបតាមប្រព័ន្ធ Facebook
- បានរៀបចំក្បាច់រចនានិមិត្តរូបរបស់ខ្មែរសម្រាប់តុបតែងរចនាលើសម្លៀកបំពាក់ KIMONO របស់ប្រទេសជប៉ុន

***<u>នាយកដ្ឋានសៀវភៅ និងការអាន ៖</u>***

កំពុងបន្តនិពន្ធអត្ថបទទស្សនាវដ្តីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

***បណ្ណាល័យជាតិ ៖**

- បានទទួលភ្ញៀវជាតិ-អន្តរជាតិចូលអានមានចំនួន ៣.៧១០នាក់
- បានទទួលសៀវភៅពីស្ថាប័ននានា និងអង្គការក្រៅរដ្ឋាភិបាល (សៀវភៅគ្រប់ភាសា) ចំនួន ១.១៩៤ក្បាល
- អ្នកសិក្សាស្រាវជ្រាវបានខ្ចីសៀវភៅយកទៅអានមានចំនួន៣៨០ក្បាល
- បានទទួលទិនានុប្បវត្តិបាន៨២៦ច្បាប់ ទស្សនាវដ្ដីផ្សេងៗនិងព្រឹត្តិប័ត្របរទេសចំនួន១.០៩៤ក្បាល
- បានចែកលេខ ISBN ដល់អ្នកបោះពុម្ពចំនួន២៧៨លេខ
- បានដាក់ក្របសៀវភៅចាស់បាន៥៥៤ក្បាល បិទកូដសៀវភៅបាន៨៣២ក្បាល ស្កេនសៀវភៅ និងទស្សនាវដ្ដីបាន១៦៧ក្បាល និងតម្កល់សៀវភៅ និងទស្សនាវដ្ដីបាន១៨៨ចំណងជើង
- ធ្វើកាតាឡុកសៀវភៅគ្រប់ប្រភេទ និងទស្សនាវដ្ដីជាភាសាខ្មែរ-បរទេសបាន១.៣៩៨ក្បាល
- បញ្ចូលកាតាឡុកទស្សនាវដ្ដីបាន២២៧ក្បាល

***<u>ការងារបេតកភណ្ឌអរូបីតាមមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី-ខេត្ត ៖</u>***

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានីភ្នំពេញ ៖</u>***

- បានបើកវគ្គបណ្ដុះបណ្ដាលស្ដីពី "របៀបចងក្បិន និងស្លៀកសំឡុយក្នុងពិធីអាពាហ៍ពិពាហ៍" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ លោកជំទាវរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានរៀបចំប្រឡងមហោស្រពសិល្បៈយុវជនលើកទី២ ថ្នាក់រាជធានីភ្នំពេញ ក្រោមប្រធានបទ "វប្បធម៌ និងការអប់រំ យុវជនដើម្បីវប្បធម៌ជាតិ" ក្រោមអធិបតីភាព ឯកឧត្តម ប៊ុន សេរី អភិបាលរងរាជធានីភ្នំពេញ
- បានរៀបចំកម្មវិធីសម្ដែងសិល្បៈជូនប្រជាពលរដ្ឋទស្សនាកម្សាន្ត និងបំផុសប្រជាពលរដ្ឋក្នុងការលេងល្បែងប្រជាប្រិយនៅរមណីយដ្ឋានវត្តភ្នំ អបអរសាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ
- បានចុះស្រង់ស្ថិតិភ្លេងពិណពាទ្យនៅតាមវត្ត ក្នុងខណ្ឌទាំង១២ រាជធានីភ្នំពេញ
- បានត្រួតពិនិត្យកន្លែងលក់កាហ្វេបញ្ចាំងវីដេអូបាន៩៩ទីតាំង អាជីវកម្មអ៊ិនធើណេតបាន៥០ ទីតាំង ម៉ាស្សា-កោសជប់បាន១៩ទីតាំង សម្ភាងការបាន៦ទីតាំង ទីតាំងជួល-លក់ថាសបាន៨៣ ទីតាំង រោងភាពយន្តបាន៣ទីតាំង ខារ៉ាអូខេបាន០១ទីតាំង
- បានសហការជាមួយនាយកដ្ឋានសិល្បៈភាពយន្ត ចុះត្រួតពិនិត្យ អប់រំ ណែនាំដល់ម្ចាស់អាជីវកម្មកាត់ត តម្លើងរូបភាព និងហ្វីលខ្មែរដែលគ្មានច្បាប់អនុញ្ញាតឲ្យទៅសុំច្បាប់អនុញ្ញាតនៅនាយកដ្ឋានសិល្បៈភាពយន្តបានចំនួន០២កន្លែង
- បានអញ្ជើញម្ចាស់អាជីវកម្មអ៊ិនធើណេតចំនួន៣ទីតាំង ក្នុងខណ្ឌមានជ័យ ឲ្យបញ្ឈប់ និងរើទីតាំងចេញ ព្រោះធ្វើឲ្យមានប៉ះពាល់ និងរំខានដល់អ្នកជិតខាង
- បានសហការជាមួយគណៈកម្មការចម្រុះខណ្ឌ ក្នុងរាជធានីភ្នំពេញ ចុះចាប់អាជីវកម្មហ្គេមចំនួន ១៥ទីតាំង ដោយដកហូតទូហ្គេមចំនួន៩៥គ្រឿង និងសម្ភារៈមួយចំនួន
- បានសហការជាមួយគណៈបញ្ជាការឯកភាពខណ្ឌមានជ័យ រៀបចំពិធីវាយកម្ទេចទូហ្គេមបាញ់ត្រីចំនួន៨ទូ ដែលដកហូតបាន
- បានសហការជាមួយសាលាសង្កាត់បឹងសាឡាង ចុះធ្វើកំណត់ហេតុ ណែនាំម្ចាស់អាជីវកម្មឆ្លាក់ត្រា និងដាក់ស្លាកយីហោនៅលើចិញ្ចើមផ្លូវ
- បានចុះស្រង់ស្ថិតិអាជីវកម្មពាក់ព័ន្ធវិស័យវប្បធម៌ចំនួន១៩ទីតាំង ក្នុងខណ្ឌដង្កោ

- បានចុះត្រួតពិនិត្យ និងផ្សព្វផ្សាយតារាងសេវាកម្មច្រកចេញចូលតែមួយពីសេវាកម្មលើកស្លាក យីហោផ្សព្វផ្សាយពាណិជ្ជកម្មជាមួយមន្ត្រីច្រកចេញចូលតែមួយខណ្ឌទួលគោក
- បានចុះជម្រុញអាជីវករឲ្យមកធ្វើច្បាប់ពាក់ព័ន្ធវិស័យវប្បធម៌នៅការិយាល័យច្រកចេញចូលតែមួយ
- បានចុះកាត់ស្លាកស្លាកសញ្ញាដែលលើកតាំងខុសច្បាប់ចំនួន២១ផ្ទាំង

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកណ្ដាល ៖</u>***

- បានរៀបចំប្រារព្ធទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១ ៨ ឆ្នាំ២០១ ៦ ក្រោមប្រធានបទ "យុវជនដើម្បីវប្បធម៌ជាតិ" ក្រោមអធិបតីភាព ឯកឧត្តម ថៃ នរៈសត្យា រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានចុះបង្ហាត់ល្ខោននិយាយរឿង "លះបង់" របស់សិស្សវិទ្យាល័យ ហ៊ុន សែន សេរីភាព និងសហការជាមួយអ្នកគ្រូ សុភីលីន បង្ហាត់របាំក្បាច់បុរាណ "បណ្ដាំព្រះម៉ែអប្សរា"ដល់សិស្សវិទ្យាល័យ ហ៊ុន សែន តាខ្មៅ ដើម្បីចូលរួមមហោស្រពយុវជនត្រៀមថ្នាក់ខេត្ត និងមហោស្រពយុវជនថ្នាក់ជាតិ លើកទី២ ឆ្នាំ២០១៦
- បានសហការជាមួយនាយកដ្ឋានសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម មន្ទីរទេសចរណ៍ខេត្ត និងអាជ្ញាធរមូលដ្ឋាន បើកវគ្គបណ្ដុះបណ្ដាលក្បាច់ចម្លាក់ខ្មែរ ដល់សិប្បករចំនួន៥០នាក់ នៅស្រុកពញាឮ
- បានសហការជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្តកណ្ដាល និងវិទ្យាស្ថានសិល្បៈខ្មែរ រៀបចំមហោស្រពសិល្បៈយុវជនថ្នាក់ខេត្ត នៅរោងមហោស្រពសិល្បៈព្រឹទ្ធាចារ្យ ឆេង ផុន ក្រុងតាខ្មៅ ក្រោមអធិបតីភាព លោកជំទាវ សួស សារ៉ាម អភិបាលរងខេត្តកណ្ដាល
- បានសហការជាមួយអាជ្ញាធរឃុំ-ស្រុកខ្សាច់កណ្ដាល និងប្រជាពលរដ្ឋ រៀបចំកម្មវិធីលេងល្បែងប្រជាប្រិយ និងរាំកំសាន្ត រយៈពេល៣ថ្ងៃអបអរបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ នៅវត្តវិហារសួគ៌ ឃុំវិហារសួគ៌ និងវត្តស្វាយជ្រុំ ឃុំស្វាយជ្រុំ ស្រុកខ្សាច់កណ្ដាល
- បានសហការជាមួយគណៈកម្មការអន្តរក្រសួងបង្ក្រាបបទល្មើសភាពយន្ត-វីដេអូ ព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តកណ្ដាល និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំបារគូ ចុះបង្ក្រាបបទល្មើសថតចម្លងថាសខុសច្បាប់មួយកន្លែងក្នុងឃុំបារគូ ស្រុកកណ្ដាលស្ទឹង ដោយដកហូតបានម៉ាស៊ីនថតចម្លងថាសចំនួន១០គ្រឿង និងវីស៊ីឌីថតចម្លងខុសច្បាប់ចំនួន០៩កេសតូច យកមករក្សាទុកនៅអគ្គនាយកដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ
- បានសហការជាមួយអាជ្ញាធរឃុំវិហារលួង និងឃុំផ្សារដែក ចុះពិនិត្យអាជីវកម្មភាពយន្ត -វីដេអូចំនួន៦កន្លែង និងបានណែនាំអាជីវករឲ្យអនុវត្តតាមគោលការណ៍ និងស្នើសុំច្បាប់អនុញ្ញាតប្រកបអាជីវកម្មឲ្យបានត្រឹមត្រូវតាមប្រកាសអន្តរក្រសួង
- បានសហការជាមួយអាជ្ញាធរពាក់ព័ន្ធក្នុងការរៀបចំបុណ្យជាតិ រៀបចំតុបតែងវេទិកាកិត្តិយសជូនគណៈអធិបតី និងលើកទង់ជាតិ ចងបដា ក្នុងកម្មវិធីផ្សេងៗក្នុងខេត្ត
- ការិយាល័យច្រកចេញចូលតែមួយក្រុងតាខ្មៅ បានផ្ដល់ច្បាប់សេវាកម្មលើវិស័យវប្បធម៌ និងវិចិត្រសិល្បៈចំនួន៧២ច្បាប់

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកែប ៖</u>***

- បានរៀបចំប្រារព្ធទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១ ៨ ឆ្នាំ២០១៦ ក្រោមប្រធានបទ "យុវជន ដើម្បីវប្បធម៌ជាតិ" ក្រោមអធិបតីភាព ឯកឧត្តម ជុច គឿន រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានចុះហ្វឹកហាត់ល្ខោនអប់រំ០១ចំណងជើង នៅវិទ្យាល័យ ហ៊ុន សែន ចំការដូង ដើម្បី ចូលរួម មហោស្រពសិល្បៈយុវជនទូទាំងប្រទេសលើកទី២ អបអរទិវាវប្បធម៌ជាតិ ៣មីនា លើកទី១៨ ឆ្នាំ២០១៦
- បានតម្លើងស្នាដៃល្ខោនអប់រំបាន០១ស្នាដៃគឺរឿង "អ៊ុំចាស់ អ៊ុំដឹង"
- បានចុះបំផុស និងសហការលេងល្បែងប្រជាប្រិយខ្មែរនៅតាមវត្តអារាម និងតាមរមណីយដ្ឋាន នានាក្នុងពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ
- បានទទួលឯកសារវីដេអូភ្លេងអារក្សជាDVD ចំនួន០៣ដុំ ពីក្រុមការងារមជ្ឈមណ្ឌលស្រាវជ្រាវ នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ដែលចុះស្រាវជ្រាវនៅខេត្តកែបកន្លងមក ដើម្បីរក្សាទុកជាឯកសារ
- បានចុះត្រួតពិនិត្យ និងស្រង់ទិន្នន័យនៅស្ថានីយទូរទស្សន៍ខ្សែកាបក្រុងកែប
- បានចុះត្រួតពិនិត្យ ណែនាំការបញ្ចាំង និងកន្លែងជួល -លក់ថាស ឲ្យគោរពតាមគោលការណ៍ ណែនាំរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានចុះពិនិត្យ និងណែនាំដល់ម្ចាស់សិប្បកម្មចម្លាក់ពុម្ពស៊ីម៉ងត៍ចំនួន ០២កន្លែង និងសិប្បកម្មធ្វើ គ្រឿងសង្ហារិម០១កន្លែង នៅក្រុងកែប
- បានចុះស្រង់ទិន្នន័យ និងសម្ភាសអ្នកលក់វត្ថុអនុស្សាវរីយ៍អំពីសំបកខ្យង នៅក្រុងកែប
- បានសហការរៀបពិធីបង្ហើរខ្លែងខ្មែរ ដើម្បីអបអរសាទរ បុណ្យចូលឆ្នាំសកល ឆ្នាំ២០១៦ និងទិវា បុណ្យជាតិ ៧មករា ឆ្នាំ២០១៦ ដែលមានខ្លែងចូលរួមសរុបចំនួន២៣៦ ខ្លែង ក្នុងនោះខ្លែងឯក ចំនួន៨២ខ្លែង និងខ្លែងច្នៃប្រឌិតចំនួន១៩៤ខ្លែង
- បានចុះត្រួតពិនិត្យស្លាកយីហោ ស្លាកសញ្ញា និងផ្ទាំងផ្សាយពាណិជ្ជកម្មបានចំនួន០៤លើកនៅក្រុងកែប
- បានចុះផ្សព្វផ្សាយ និងណែនាំដល់ម្ចាស់ស្លាកយីហោ សម្ភាងការ អ៊ុតសក់ នៅក្រុងកែប
- បានផ្សព្វផ្សាយប្រកាសលេខ១៧២ និងសេចក្តីណែនាំលេខ០២ សណន ស្តីពីការគ្រប់គ្រងស្លាក យីហោ និងផ្ទាំងផ្សាយពាណិជ្ជកម្មផ្សេងៗ របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈចំនួន០២លើក

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ចាម ៖</u>***

- បានរៀបចំប្រារព្ធទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១ ៨ ឆ្នាំ២០១៦ ក្រោមប្រធានបទ "យុវជន ដើម្បីវប្បធម៌ជាតិ" ក្រោមអធិបតីភាព ឯកឧត្តម គង់ កន្ធារ៉ា អនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានចុះបំផុស និងសហការលេងល្បែងប្រជាប្រិយខ្មែរនៅតាមវត្តអារាមនៅស្រុកកំពង់សៀម ស្រុកជើងព្រៃ និងស្រុកបាធាយក្នុងពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ
- បានចុះពិនិត្យការបញ្ចាំងភាពយន្តតាមហាងកាហ្វេ នៅស្រុកបាធាយ
- បានចុះពិនិត្យការដាក់តាំងស្លាកយីហោ នៅស្រុកបាធាយ

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ឆ្នាំង ៖</u>***

- បានរៀបចំប្រារព្ធទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១ ៨ ឆ្នាំ២០១៦ ក្រោមប្រធានបទ "យុវជន ដើម្បីវប្បធម៌ជាតិ" ក្រោមអធិបតីភាព ឯកឧត្តម អ៊ុក សុជាតិ រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានបន្តចុះត្រួតពិនិត្យ និងស្រង់ស្ថិតិសិល្បៈទស្សនីយភាព សិល្បៈសូនរូប សិល្បៈភាពយន្ត និងអភិវឌ្ឍវប្បធម៌

***មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ធំ៖***

- បានរៀបចំប្រារព្ធទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១ ៨ ឆ្នាំ២០១៦ ក្រោមប្រធានបទ "យុវជនដើម្បីវប្បធម៌ជាតិ" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ លោកជំទាវរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានរៀបចំមហោស្រពសិល្បៈចម្រៀងបុរាណ-សម័យ ដើម្បីអបអរសាទរទិវាជ័យជំនះលើរបបប្រល័យពូជសាសន៍ រយៈពេល៣ថ្ងៃ នៅមន្ទីរវប្បធម៌ខេត្ត
- បានបង្ហាត់សិល្បៈដល់សិស្សថ្នាលរៀងរាល់ថ្ងៃអាទិត្យ
- បានតម្លើងបទភ្លេងរបាំ "សាឡុងជាន់ដែកតាឡែកកំពង់ធំ"
- បានសម្ភាសជាមួយទូរទស្សន៍ជាតិកម្ពុជា (ទទក) និងថតយកសកម្មភាពបង្ហាត់របាំដល់សិស្សថ្នាលដែលត្រៀមសម្តែងក្នុងកម្មវិធីសង្ក្រាន្តថ្មីសំបូរព្រៃគុក
- បានចុះផ្សព្វផ្សាយដល់អាជីវករឲ្យមកធ្វើច្បាប់អាជីវកម្មពាក់ព័ន្ធវិស័យវប្បធម៌ឆ្នាំ២០១៦ និងចែកឯកសារពាក់ព័ន្ធជូនមេឃុំចំនួន០៩ច្បាប់ នៅស្រុកប្រាសាទបល្ល័ង្គ
- បានចុះផ្សព្វផ្សាយសេចក្តីជូនដំណឹងពីការហាមផ្សាយ ជួល-លក់ខ្សែភាពយន្តរឿង "NOESCAPE 2015" ដល់អាជីវករស្រុកសន្ទុក និងស្រុកបារាយណ៍
- បានចុះត្រួតពិនិត្យអាជីវកម្មជួល-លក់ថាសនៅក្រុងស្ទឹងសែន ស្រុកកំពង់ស្វាយ និងស្រុកសន្ទុក និងអាជីវករបញ្ចូលបទភ្លេងចំនួន០៣កន្លែងនៅក្រុងស្ទឹងសែន
- បានជម្រុញដល់មន្ត្រីតាមបណ្តាស្រុកស្រង់ទិន្នន័យ សិល្បៈសូនរូប និងសិប្បកម្ម
- បានបន្តចុះស្រង់ស្ថិតិសេវាពាក់ព័ន្ធវិស័យវប្បធម៌តាមបណ្តាស្រុកសម្រាប់ឆ្នាំ២០១៦
- បានចុះផ្សព្វផ្សាយដល់អាជីវករកាត់សក់ អ៊ុតសក់ សម្អាងការ ថតរូប គ្រឿងបំពងសម្លេង និងផ្ទាំងផ្សាយពាណិជ្ជកម្មនៅស្រុកប្រាសាទបល្ល័ង្គ
- បានចុះផ្សព្វផ្សាយអនុក្រឹត្យលេខ៦៨ អនក្រ ប្រកាសអន្តរក្រសួងលេខ៣៨៥៦ ប្រក និងលេខ៩៨៧ សហវ ប្រក ដល់អាជីវករកាត់សក់ អ៊ុតសក់ សម្អាងការ ថតរូប គ្រឿងបំពងសម្លេង និងផ្ទាំងផ្សាយពាណិជ្ជកម្មតាមបណ្តាស្រុក
- បានពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពស្ថិតិជនជាតិដើមភាគតិច គួយ ដែលមាននៅស្រុកប្រាសាទបល្ល័ង្គ និងស្រុកសណ្តាន់
- បានសហការជាមួយក្រុងស្ទឹងសែន ចុះកែលម្អស្លាកយីហោស្រាបៀរអង្គរបានចំនួន៥ស្លាក
- បានចុះពិនិត្យពិធីឡើងអ្នកតានៅស្រុកប្រាសាទសំបូរ
- បានចុះស្រង់ទិន្នន័យបបមនៃមរតកវប្បធម៌អរូបីនៅក្រុងស្ទឹងសែន ស្រុកប្រាសាទ បល្ល័ង្គ និងស្រុកស្ទោង

***មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ស្ពឺ៖***

- បានរៀបចំប្រារព្ធទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១ ៨ ឆ្នាំ២០១៦ ក្រោមប្រធានបទ "យុវជនដើម្បីវប្បធម៌ជាតិ" ក្រោមអធិបតីភាព ឯកឧត្តម សំរ៉ាំង កំសាន្ត រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានសហការជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត បើកមហោស្រពសិល្បៈយុវជនឆ្នាំទី២ថ្នាក់មូលដ្ឋានខេត្តឆ្នាំ២០១៦ និងបំផុលចលនាតាមវិទ្យាល័យក្នុងខេត្ត បង្កើតក្រុមសិល្បៈយុវជនតាមវិទ្យាល័យដើម្បីចូលរួមប្រកួតប្រជែងក្នុងមហោស្រពសិល្បៈយុវជនថ្នាក់មូលដ្ឋានខេត្តឆ្នាំ២០១៦
- បានបន្តហ្វឹកហាត់សិល្បៈដល់សិស្សបន្តវេនរៀងរាល់ថ្ងៃសៅរ៍ និងអាទិត្យ
- បានរៀបចំកម្មវិធីបង្ហាត់ក្បាច់ហ្វ៊ុនផ្នែកល្ខោនបាសាក់ និងរំលឹកឡើងវិញនូវរបាំដែលបង្កើតរួចដល់មន្ត្រីក្របខ័ណ្ឌ និងមន្ត្រីកិច្ចសន្យា នៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត
- បានដឹកនាំសិល្បៈយុវជនមកពីវិទ្យាល័យចំនួន០២ក្រុមទៅចូលរួមប្រឡងក្នុងមហោស្រពសិល្បៈយុវជនទូទាំងប្រទេស ឆ្នាំ២០១៦ នៅរាជធានីភ្នំពេញ
- បានបញ្ជូនគ្រូជំនាញផ្នែករបាំទៅបណ្តុះបណ្តាលសិស្សនៅមណ្ឌលកុមារកំព្រាច្បារមន មណ្ឌលភូមិអរុណរៈខេត្តព្រះសីហនុ និងមណ្ឌលអង្គការក្តីសង្ឃឹមថ្មីនៃកុមារកម្ពុជា ផ្នែកភ្លេងប្រពៃណីចំនួន២៣នាក់ នៅស្រុកភ្នំស្រួច ស្រុកឧដុង្គ និងស្រុកថ្ពង និងបណ្តុះបណ្តាលពីទម្រង់កាត់សក់ក្នុងពិធីរៀបអាពាហ៍ពិពាហ៍ចំនួន១២នាក់ នៅស្រុកគងពិសី
- បានសហការជាមួយសហភាពសហព័ន្ធយុវជនកម្ពុជាខេត្តកំពង់ស្ពឺ រៀបចំបើកមហោស្រពសិល្បៈប្រឡងចម្រៀងសម័យថ្មី និងជំនាន់មុន និងលេងល្បែងប្រជាប្រិយខ្មែរ រយៈពេល៥ថ្ងៃ ដើម្បីអបអរសាទរពិធី បុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ
- បានបណ្តុះបណ្តាលដល់ក្រុមរបាំត្រុដិ របស់សិស្សមកពីវិទ្យាល័យទ័ពមានជ័យ និងវិទ្យាល័យកំពង់ស្ពឺ
- បានចុះត្រួតពិនិត្យការបញ្ចាំងភាពយន្តរបស់ក្រុមហ៊ុនយូនីលីវើ ស៊ីនី នៅស្រុកសំរោងទង និងការបញ្ចាំងភាពយន្ត-វីដេអូនៅស្រុកគងពិសី ស្រុកសំរោងទង ស្រុកភ្នំស្រួច ស្រុក និងស្រុកឧដុង្គ
- បានចុះពិនិត្យកន្លែងជួល-លក់ថាស និងបញ្ចាំងវីដេអូនៅស្រុកគងពិសី និងស្រុកភ្នំស្រួច
- បានស្រង់ទិន្នន័យ និងប្រមូលសេវាសាធារណៈលើវិស័យវប្បធម៌ និងវិចិត្រសិល្បៈតាមប្រតិភូកម្មដែលក្រសួងបានដាក់ចុះ នៅស្រុកឧដុង្គ និងស្រុកថ្ពង
- បានចុះពង្រឹង និងកែតម្រូវក្បួនខ្នាតចម្លាក់ខ្មែរនៅក្រុងច្បារមន និងស្រុកគងពិសី
- បានចុះពិនិត្យសិប្បកម្មអំពីចម្លាក់ពុម្ពស៊ីម៉ង់ត៍នៅផ្សារព្រៃផ្តៅ ស្រុកសំរោងទង និងផ្សារស្រង់ ស្រុកគងពិសី
- បានចុះសិក្សាស្រាវជ្រាវសិប្បកម្មដោយដៃ អំពីវល្លិ៍ និងស្លឹក នៅស្រុកសំរោងទង និងស្រុកឧដុង្គ
- បានចុះជម្រុញដល់អាជីវករពាក់ព័ន្ធវិស័យវប្បធម៌ ឲ្យមកសុំច្បាប់នៅការិយាល័យច្រកចេញចូលតែមួយ
- ការិយាល័យច្រកចេញចូលតែមួយក្រុងច្បារមន បានអនុញ្ញាតច្បាប់ប្រកបអាជីវកម្មលើវិស័យវប្បធម៌ និងវិចិត្រសិល្បៈចំនួន៤០ច្បាប់

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពត ៖</u>***

- បានរៀបចំប្រារព្ធទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១ ៨ ឆ្នាំ២០១ ៦ ក្រោមប្រធានបទ "យុវជនដើម្បីវប្បធម៌ជាតិ" ក្រោមអធិបតីភាព ឯកឧត្តម ផុច គឿន រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានសហការរៀបចំកម្មវិធីកំសាន្ត លេងល្បែងប្រជាប្រិយខ្មែរ ដើម្បីអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ
- បានចុះធ្វើបច្ចុប្បន្នភាពស្ថិតិក្រុមសិល្បៈមហាជននៅតាមបណ្តាស្រុក-ក្រុងទាំង៨
- បានសហការកសាងស្នាដៃសិល្បៈទស្សនីយភាពយីកេរឿង "កោះស្នេហាធីតាចិត្តស្មោះ"
- បានចុះត្រួតពិនិត្យកន្លែងលក់-ជួលថាសនៅក្រុងកំពត

- បានសហការជាមួយគ្រប់ការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈស្រុក-ក្រុង ចុះត្រួតពិនិត្យទិដ្ឋាការលើថាសគ្រប់ប្រភេទ
- បានសម្របសម្រួលសំណើសុំថតខ្សែភាពយន្តរបស់ក្រុមហ៊ុន CTV ក្នុងក្រុងកំពត
- ផ្សព្វផ្សាយសេចក្តីជូនដំណឹងលេខ១៧ សជណ ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៦ របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ឲ្យបញ្ឈប់ជាបន្ទាន់រាល់សកម្មភាពរំលោភបំពានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល លើស្នាដៃអក្សរសាស្ត្រ អក្សរសិល្ប៍ និងតន្ត្រី ដែលគ្មានអ្នកទទួលមរតកសាសន៍ ឬគ្មានមរតកសាសន៍
- បានចុះត្រួតពិនិត្យអាជីវកម្មសូនរូប និងសិប្បកម្ម នៅស្រុកបន្ទាយមាស
- បានសហការជាមួយគ្រប់ការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈស្រុក -ក្រុង ចុះផ្សព្វផ្សាយខ្នាតក្បាច់ចម្លាក់ខ្មែរដល់អាជីវកម្មសិល្បៈសូនរូប និងសិប្បកម្ម
- បានចុះត្រួតពិនិត្យ និងណែនាំការដាក់តាំង ស្លាកយីហោនិងផ្ទាំងផ្សាយពាណិជ្ជកម្ម នៅក្រុងកំពត
- បានសហការជាមួយការិយាល័យវប្បធម៌គ្រប់ស្រុក -ក្រុង ក្នុងការងារចងក្រងស្ថិតិបេតិកភណ្ឌវប្បធម៌អរូបី

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកោះកុង</u> ៖***

- បានរៀបចំបើកមហោស្រពសិល្បៈយុវជនថ្នាក់ខេត្ត ឆ្នាំ២០១៦
- បានចុះត្រួតពិនិត្យអាជីវកម្មជួល-លក់ឌីសនៅក្រុងខេមរភូមិន្ទ និងអ៊ិនធើណេត ហាងកាហ្វេនៅស្រុកមណ្ឌលសីមា
- បានចុះសិក្សាពីទំនៀមទម្លាប់ប្រពៃណីជនជាតិដើមជង ក្នុងពិធីបុណ្យបើកព្រះនេត្រ ស្ថិតនៅស្រុកថ្មបាំង
- បានចុះណែនាំដល់អាជីវករឲ្យមកសុំច្បាប់អនុញ្ញាតប្រកបអាជីវកម្មលើវិស័យវប្បធម៌នៅការិយាល័យច្រកចេញចូលតែមួយ
- បានចុះស្រង់ត្រួតពិនិត្យ ស្ថិតិសិល្បៈសូនរូប និងសិប្បកម្មនៅក្រុងខេមរភូមិន្ទ
- បានចុះណែនាំអាជីវករដែលលើកស្លាកយីហោថ្មីឲ្យមកច្បាប់អនុញ្ញាតបានចំនួន១០កន្លែង សម្អាងការចំនួន០៧កន្លែង និងអ៊ុតសក់ ធ្វើក្រចកចំនួន៥កន្លែង
- ការិយាល័យច្រកចេញចូលតែមួយ បានចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មលើវិស័យវប្បធម៌ និងវិចិត្រសិល្បៈបាន៤៦ច្បាប់

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តក្រចេះ</u> ៖***

- បានរៀបចំប្រារព្ធទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១ ៨ ឆ្នាំ២០១ ៦ ក្រោមប្រធានបទ "យុវជនដើម្បីវប្បធម៌ជាតិ" ក្រោមអធិបតីភាព ឯកឧត្តម ថៃ នរៈសត្យា រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានហ្វឹកហាត់របាំដើម្បីត្រៀមចូលរួមពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ និងបុណ្យផ្សេងៗ។
- បានចុះពិនិត្យអាជីវកម្មជួល-លក់ថាស និងហាងកាហ្វេបញ្ចាំងវីដេអូកំដរភ្ញៀវបានចំនួន៤៩កន្លែងនៅសង្កាត់អូរឬស្សី សង្កាត់ក្រចេះ សង្កាត់ក្រគរ និងសង្កាត់រកាកណ្តាល
- បានចុះពិនិត្យទីតាំងលក់វត្ថុអនុស្សាវរីយ៍ និងលក់សង្ហារិមនៅក្រុងក្រចេះ
- បានចុះស្រង់ស្ថិតិសិប្បកម្មចម្លាក់ និងបានណែនាំដល់ម្ចាស់សិប្បកម្មឲ្យរក្សានូវក្បាច់ចម្លាក់ខ្មែរឲ្យបានគង់វង្ស កុំចម្លងយកក្បាច់ចម្លាក់ពីបរទេស នៅសង្កាត់ក្រគរ
- បានចុះពិនិត្យការដាក់តាំងស្លាកសញ្ញាបានចំនួន១៥១ស្លាកនៅក្រុងក្រចេះ

- បានចុះពិនិត្យ និងផ្សព្វផ្សាយណែនាំដល់អាជីវករសម្អាងការ និងអ៊ុតសក់បានចំនួន៨៩កន្លែង នៅក្រុងក្រចេះ
- បានចុះស្រង់ស្ថិតិអាជីវកម្មពាក់ព័ន្ធវិស័យវប្បធម៌នៅស្រុកព្រែកប្រសព្វ និងស្រុកស្នួល
- ការិយាល័យច្រកចេញចូលតែមួយ បានចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មលើវិស័យវប្បធម៌ និងវិចិត្រសិល្បៈបាន៣៣ច្បាប់

## *មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តតាកែវ ៖*

- បានរៀបចំប្រារព្ធទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១៨ ឆ្នាំ២០១៦ ក្រោមប្រធានបទ "យុវជនដើម្បីវប្បធម៌ជាតិ" ក្រោមអធិបតីភាព ឯកឧត្តម ជុច ភឿន រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានសហការរៀបចំការប្រឡងតែងកំណាព្យ ស្មូតកំណាព្យ ពានរង្វាន់ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ដោយមានបេក្ខជនចូលរួមប្រឡងអត្ថបទកំណាព្យចំនួន១៣៧អត្ថបទ និងស្មូតកំណាព្យចំនួន២៦នាក់
- បានបញ្ជូនគ្រូសិល្បៈចុះទៅបង្រៀននៅវិទ្យាល័យសន្តប្រាង់ស្វរ នៅស្រុកត្រាំកក់ និងវិទ្យាល័យគិរីវង់ នៅស្រុកគិរីវង់
- បានសហការជាមួយគ្រូរបាំនៃនាយកដ្ឋានសិល្បៈទស្សនីយភាព តម្លើងរបាំ "បង្កើរខ្លែង" ដើម្បីចូលរួមមហោស្រពសិល្បៈយុវជនទូទាំងប្រទេស ឆ្នាំទី២ នៅរាជធានីភ្នំពេញ
- បានតម្លើងស្នាដៃល្ខោននិយាយចំនួន០២រឿងគឺ "យុវជន និងសង្គម" និង"នាងពៅទន្លេបាទី"
- បានចុះពិនិត្យកន្លែងជួល-លក់ថាសនៅស្រុកទ្រាំង ស្រុកព្រៃកប្បាស និងបានរកឃើញថាសគ្មានទិដ្ឋាការចំនួន៥.៧១៥បន្ទះ ព្រមទាំងបានណែនាំអាជីវករឲ្យមកសុំច្បាប់ពាក់ព័ន្ធវិស័យវប្បធម៌ពីមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត
- បានចុះពិនិត្យអាជីវកម្មផលិត និងលក់ចម្លាក់ថ្ម នៅស្រុកត្រាំកក់ និងស្រុកទ្រាំង
- បានចុះស្រង់ទិន្នន័យពាក់ព័ន្ធនឹងសិប្បកម្មតម្បាញសូត្រពីប្រជាពលរដ្ឋនៅស្រុកព្រៃកប្បាស និងតម្បាញឬស្សី ល្ពាក់ ធ្វើកន្ត្រក ធ្វើប្រអប់ដាក់ក្រដាស កន្តាំង កញ្ជើ នៅស្រុកត្រាំកក់
- បានចុះផ្សព្វផ្សាយអប់រំសីលធម៌សង្គមបានចំនួន០៧លើក

## *មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តត្បូងឃ្មុំ ៖*

- បានរៀបចំប្រារព្ធទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១៨ ឆ្នាំ២០១៦ ក្រោមប្រធានបទ "យុវជនដើម្បីវប្បធម៌ជាតិ" ក្រោមអធិបតីភាព ឯកឧត្តម ហាប់ ទូច អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានប្រារព្ធពិធីបុណ្យទន្លេស្ថិតនៅរមណីយដ្ឋានហ្លួងព្រះស្ដេចកនព្រៃអង្គរ ក្នុងឃុំដូនតី ស្រុកពញាក្រែក ដោយបានរៀបចំប្រគំតន្ត្រីសម័យ អាយ៉ៃរឿង "ប្រយ័ត្នគ្រោះថ្នាក់" ចាប៉ីដងវែង រឿង "ចៅគីង្គក់" និងល្ខោនបាសាក់រឿង "ទុំទាវ"
- បានបញ្ជូនគ្រូសិល្បៈទៅបង្ហាត់សិស្សនៅវិទ្យាលល័យ ហ៊ុន សែន ពញាក្រែក វិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន មេមត់ សាលាបឋមសិក្សា ហ៊ុន សែន តំបែរ និងសាលាបឋមសិក្សាក្រែក
- បានចុះតាមដានបទល្មើសថតចម្លងថាសខុសច្បាប់នៅស្រុកមេមត់
- បានចុះទៅពិនិត្យមើលសិប្បកម្មតម្បាញធ្វើអំពីឬស្សី ស្ថិតនៅក្រុងសួង
- បានចុះស្រង់ស្ថិតិចម្លាក់ពុម្ពចំនួន០៧កន្លែង ចម្លាក់ឈើចំនួន០១កន្លែងនៅស្រុកត្បូងឃ្មុំ

- បានចុះជួបសម្ភាសន៍ជាមួយម្ចាស់សិប្បកម្មតម្បាញប្រពៃណី ធ្វើអំពីឬស្សីដូចជាៈ កំជា ត្រក់ ក្តុះគ្រួស កញ្ជើ ល្អី ស្ថិតនៅស្រុកមេមត់
- បានចុះស្រង់ស្ថិតិសម្អាងការ អ៊ុតសក់ លម្អក្រចក កាត់សក់ បានចំនួន១៦កន្លែងនៅស្រុកត្បូងឃ្មុំ
- បានចុះស្រង់ស្ថិតិមរតកមនុស្សរស់នៅស្រុកពញាក្រែក
- បានចុះសិក្សាពីប្រវត្តិអ្នកតាបេង ស្ថិតនៅក្រុងសួង

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តបន្ទាយមានជ័យ ៖</u>***

- បានរៀបចំប្រារព្ធទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១ ៨ ឆ្នាំ២០១ ៦ ក្រោមប្រធានបទ "យុវជន ដើម្បីវប្បធម៌ជាតិ" ក្រោមអធិបតីភាព ឯកឧត្តម ឃឹម សារិទ្ធ រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានបណ្តុះបណ្តាលក្រុមសិល្បៈយុវជនខេត្ត ដើម្បីចូលរួមមហោស្រពសិល្បៈយុវជនទូទាំង ប្រទេសឆ្នាំ២០១៦ នៅរាជធានីភ្នំពេញ
- បានដឹកនាំក្រុមសិល្បៈយុវជនខេត្តទៅចូលរួមសម្តែងសិល្បៈនៅប្រទេសថៃចំនួន០២លើក
- បានចុះផ្សព្វផ្សាយការទប់ស្កាត់ខ្សែភាពយន្តរឿង No Escape នៅទូទាំងខេត្ត
- បានចុះត្រួតពិនិត្យកន្លែងជួល-លក់ថាសនៅក្រុងសិរីសោភ័ណ និងការលួចចម្លងស្នាដៃភាពយន្ត-វីដេអូនៅស្រុកពួក ដោយធ្វើការដកហូតម៉ាស៊ីន ថតចម្លងវីស៊ីឌីចំនួន០១គ្រឿង កំព្យូទ័រចំនួន០១ គ្រឿង និង Flash ចំនួន០១គ្រឿង
- បានចុះត្រួតពិនិត្យវត្ថុសិល្បៈចម្លាក់ថ្មចំនួន២៣រូប ដែលនាំចេញទៅរាជធានីភ្នំពេញ និងខេត្តសៀមរាប
- បានចុះស្រង់ស្ថិតិសិល្បៈសូនរូប និងសិប្បកម្មចំនួន១៨៨កន្លែង នៅស្រុកព្រះនេត្រព្រះ
- បានសហការជាមួយអាជ្ញាធរក្រុងសិរីសោភ័ណ ចុះត្រួតពិនិត្យទីតាំងលើកស្លាកយីហោបានចំនួន ០៣កន្លែង

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តបាត់ដំបង ៖</u>***

- បានរៀបចំប្រារព្ធទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១ ៨ ឆ្នាំ២០១ ៦ ក្រោមប្រធានបទ "យុវជន ដើម្បីវប្បធម៌ជាតិ" ក្រោមអធិបតីភាព ឯកឧត្តម ឃឹម សារិទ្ធ រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានដឹកនាំក្រុមសិល្បៈយុវជនទៅចូលរួមប្រឡងក្នុងមហោស្រពសិល្បៈយុវជនទូទាំងប្រទេស នៅរាជធានីភ្នំពេញ
- បានចុះពិនិត្យការចាក់បញ្ចាំងវីដេអូតាមហាងកាហ្វេ និងចុះផ្សព្វផ្សាយដល់អាជីវករឲ្យមកធ្វើច្បាប់ អាជីវកម្មបន្ត
- បានបន្តចុះពិនិត្យនៅតាមកន្លែងសិប្បកម្មចម្លាក់ និងបន្តធ្វើច្បាប់អាជីវកម្ម
- បានសហការជាមួយសាលាខេត្តបាត់ដំបង រៀបចំការតាំងពិព័រណ៍មុខម្ហូបខ្មែរ ដើម្បីអបអរពិធី បុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ
- បណ្ណាល័យខេត្ត បានបើកទ្វារជូនសាធារណជនចូលអានសៀវភៅរៀងរាល់ថ្ងៃ លើកលែងថ្ងៃ ឈប់សម្រាក
- បានចុះស្រង់ទិន្នន័យស្លាកយីហោនៅក្នុងតំបន់អភិរក្សខេត្តបាត់ដំបង

- បានចុះជម្រុញអាជីវករឲ្យមកធ្វើច្បាប់អាជីវកម្មលើវិស័យវប្បធម៌បន្តនៅច្រកចេញចូលតែមួយ ស្រុកបរវេល
- ការិយាល័យច្រកចេញចូលតែមួយក្រុងបាត់ដំបង បានចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មលើ វិស័យវប្បធម៌ និងវិចិត្រសិល្បៈបាន៧២ច្បាប់ និងនៅស្រុកបរវេល បានចំនួន១៦ច្បាប់

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តប៉ៃលិន ៖</u>***

- បានរៀបចំប្រារព្ធទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១ ៨ ឆ្នាំ២០១ ៦ ក្រោមប្រធានបទ "យុវជន ដើម្បីវប្បធម៌ជាតិ" ក្រោមអធិបតីភាព ឯកឧត្តម ឃឹម សារិទ្ធ រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានរៀបចំបើកមហោស្រពសិល្បៈរបាំ និងល្ខោនខ្លីសម្រាប់យុវជនថ្នាក់ខេត្ត លើកទី២ ឆ្នាំ២០១៦ ក្រោមអធិបតីភាព ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តប៉ៃលិន
- បានចុះបង្ហាត់របាំក្បាច់ប៉ៃលិនដល់បុគ្គលិកធនាគារអេស៊ីលីដារយៈពេល១៣សប្តាហ៍
- បានចុះបំផុសដល់យុវជន និងមហាជន ព្រមទាំងដឹកនាំលេងល្បែងប្រជាប្រិយខ្មែរ ដើម្បីអបអរ សាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ និងបានធ្វើការណែនាំដល់យុវជន មហាជនឲ្យចេះ ជួយថែរក្សាវប្បធម៌ប្រពៃណីជាតិខ្មែរឲ្យបានគង់វង្ស
- បានចុះត្រួតពិនិត្យ និងជម្រុញអាជីវករជួល -លក់ថាស ឲ្យមកធ្វើច្បាប់អាជីវកម្មនៅក្រុងប៉ៃលិន និងស្រុកសាលាក្រៅ
- បានចុះស្រង់ស្ថិតិ និងធ្វើច្បាប់អនុញ្ញាតប្រកបអាជីវកម្មសម្រាប់ឆ្នាំ២០១៦ ផ្នែកកាត់សក់ អ៊ុតសក់ បានចំនួន១០កន្លែង នៅស្រុកសាលាក្រៅ

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តពោធិ៍សាត់ ៖</u>***

- បានរៀបចំប្រារព្ធទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១ ៨ ឆ្នាំ២០១ ៦ ក្រោមប្រធានបទ "យុវជន ដើម្បីវប្បធម៌ជាតិ" ក្រោមអធិបតីភាព ឯកឧត្តម អ៊ុក សុជាតិ រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រុមសិល្បៈម្លប់រំដួលពោធិ៍សាត់ បានចុះបង្ហាត់របាំនៅសង្កាត់រលាប និងនៅសាលាបឋមសិក្សា ស្វាភី សង្កាត់លលកស ស្ថិតនៅក្រុងពោធិ៍សាត់
- បានចុះបង្ហាត់ និងកែលម្អស្នាដៃរបស់ក្រុមសិល្បៈមហាជនបានចំនួន៨ក្រុម
- បានចុះបង្ហាត់សិល្បៈដល់ក្រុមសិល្បៈសិស្សយុវជនស្រុកក្រគរ និងក្រុមសិល្បៈយុវជនអង្គការ ចេរភាពកម្ពុជាខេត្តពោធិ៍សាត់
- បានចុះត្រួតពិនិត្យកន្លែងជួល-លក់ថាសមិនទាន់មានច្បាប់នៅស្រុកក្រគរ និងស្រុកបាកាន
- បានចុះតាមដានការចាក់បញ្ចាំងវីដេអូរអាសអាភាសតាមហាងកាហ្វេ នៅក្រុងពោធិ៍សាត់
- បានចុះត្រួតពិនិត្យវត្ថុសិល្បៈចម្លាក់ នៅសង្កាត់បន្ទាយដី
- បានចុះពិនិត្យអាជីវកម្មចម្លាក់ នៅក្រុងពោធិ៍សាត់ ស្រុកក្រគរ និងស្រុកបាកាន

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តព្រៃវែង ៖</u>***

- បានរៀបចំប្រារព្ធទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១ ៨ ឆ្នាំ២០១ ៦ ក្រោមប្រធានបទ "យុវជនដើម្បីវប្បធម៌ជាតិ" ក្រោមអធិបតីភាព ឯកឧត្តម អ៊ុក សុជាតិ រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានរៀបចំមហោស្រពចម្រៀងខ្មែរជាសាកលនៅទូទាំងខេត្ត ឆ្នាំ២០១៦
- បានសហការជាមួយអាជ្ញាធរស្រុកបាភ្នំ រៀបចំប្រឡងចម្រៀងសម័យក្នុងពិធីបុណ្យឡើងអ្នកតាមេស ឆ្នាំ២០១៦
- បានរៀបចំពិធីបុណ្យចម្រើនបារមីព្រះអង្គបារាយណ៍អណ្តែតឆ្នាំ២០១៦
- បានចុះពិនិត្យក្រុមសិល្បៈយុវជនវិទ្យាល័យបាភ្នំ
- បានចុះពិនិត្យអាជីវកម្មជួល-លក់ថាសចំនួន០៦កន្លែង និងណែនាំអាជីវករឲ្យជួល-លក់ថាសណាដែលមានទិដ្ឋាការពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈនៅស្រុកពាមរក៍ ស្រុកពាមជរ ស្រុកពារាំង ស្រុកបាភ្នំ ស្រុកមេសាង និងស្រុកស៊ីធរកណ្តាល
- បានចុះពិនិត្យសិប្បកម្មតម្បាញ ហូលផាមួង នៅស្រុកពោធិរៀង
- បានចុះពិនិត្យសិប្បកម្មពុម្ពស៊ីម៉ងត៍ នៅស្រុកព្រះស្តេច ស្រុកពារាំង ស្រុកកំចាយមារ និងស្រុកកញ្ជៀច
- បានចុះពិនិត្យការដាក់តាំងស្លាកយីហោគ្រប់ប្រភេទនៅស្រុកកំពង់ត្របែក ស្រុកព្រះស្តេច ស្រុកស្រុកកំចាយមារ ស្រុកពាមជរ និងស្រុកពារាំង

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តព្រះវិហារ ៖</u>***

- បានរៀបចំប្រារព្ធទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១ ៨ ឆ្នាំ២០១ ៦ ក្រោមប្រធានបទ "យុវជនដើម្បីវប្បធម៌ជាតិ" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ លោកជំទាវរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានដឹកនាំក្រុមសិល្បៈសម្តែងរបាំក្នុងកម្មវិធីទិវាវប្បធម៌រួមគ្នា រវាងខេត្តព្រះវិហារ និងខេត្តចម្ប៉ាសាក់ ប្រទេសឡាវ ស្ថិតនៅស្រុកឆែប
- បានចុះណែនាំអាជីវករឲ្យមកធ្វើច្បាប់អាជីវកម្មខារ៉ាអូខេនៅស្រុកឆែប
- បានចុះត្រួតពិនិត្យនិងធ្វើច្បាប់អាជីវកម្មដល់អាជីវករជួល-លក់ថាសនៅស្រុកជ័យសែន និងស្រុកត្បែងមានជ័យ
- បានចុះស្រង់ស្ថិតិសិល្បៈសូនរូប និងសិប្បកម្មនៅស្រុកឆែប ស្រុកត្បែងមានជ័យនិងស្រុកគូលែន
- បានចុះស្រង់ស្ថិតិស្លាកយីហោនៅស្រុកជ័យសែន
- ការិយាល័យច្រកចេញចូលតែមួយក្រុងព្រះវិហារ បានចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មលើវិស័យវប្បធម៌ និងវិចិត្រសិល្បៈបាន១៥ច្បាប់

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តព្រះសីហនុ ៖</u>***

- បានរៀបចំប្រារព្ធទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១ ៨ ឆ្នាំ២០១ ៦ ក្រោមប្រធានបទ "យុវជនដើម្បីវប្បធម៌ជាតិ" ក្រោមអធិបតីភាព ឯកឧត្តម ចៀង វណ្ណដារ៉ុង អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានតម្លើងស្នាដៃរបាំ "ដូងប្រេង" ដើម្បីចូលរួមមហោស្រពសិល្បៈយុវជនទូទាំងប្រទេសឆ្នាំ២០១៦
- បានចុះបង្ហាត់បង្រៀនរបាំ "ដូងប្រេង" ដល់សិស្សនៃសាលាសុវណ្ណភូមិ

- បានសហការជាមួយរដ្ឋបាលខេត្តព្រះសីហនុ និងក្រុមហ៊ុនឯកជន ដឹកនាំក្រុមសិល្បៈចូលរួមសម្តែងក្នុងការប្រគំតន្ត្រី និងលេងល្បែងប្រជាប្រិយខ្មែរតាមទីវត្តអារាម និងតាមទីសាធារណៈ ដើម្បីអបអរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ
- បានចុះស្រង់ស្ថិតិ និងផ្សព្វផ្សាយសេចក្តីជូនដំណឹងលេខ៣៥៤ វវ .ខសន របស់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តព្រះសីហនុ ដល់អាជីវករជួល-លក់ថាសបានចំនួន១១កន្លែង
- បានចុះផ្សព្វផ្សាយសេចក្តីជូនដំណឹងលេខ០៩៤/១៦ វវ.ខសន ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ របស់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តព្រះសីហនុ ស្តីពីការគ្រប់គ្រងត្រួតពិនិត្យស្នាដៃសិល្បៈភាពយន្ត និងវីដេអូ ដើម្បីទប់ស្កាត់ការធ្វើអាជីវកម្មជួញដូរស្នាដៃភាពយន្ត និងវីដេអូគ្មានទិដ្ឋាការ ដល់អាជីវករក្នុងក្រុងព្រះសីហនុ
- បានចុះផ្សព្វផ្សាយសេចក្តីជូនដំណឹងលេខ១៧ សជណ របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈស្តីពីការឈប់ជាបន្ទាន់នូវរាល់សកម្មភាពរំលោភបំពានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលលើស្នាដៃអក្សរសាស្រ្តសិល្បៈ និងតូរ្យតន្ត្រី ដែលគ្មានអ្នកទទួលមរតក ឬគ្មានមរតកសាសន៍ដល់ក្រុមហ៊ុនខ្សែកាប និងអាជីវករជួល-លក់ថាសក្នុងក្រុងព្រះសីហនុបានចំនួន២២កន្លែង
- បានចុះផ្សព្វផ្សាយសេចក្តីជូនដំណឹងលេខ១៦២ វវ .ខសន ស្តីពីការគ្រប់គ្រងអាជីវកម្មថតចម្លងបានចំនួន០២កន្លែង នៅក្រុងព្រះសីហនុ
- បានចុះស្រង់ស្ថិតិក្រុមតន្ត្រី សម្ពាងការ មេក្រូ ធុងបាស អ៊ុតសក់ ហ្គេម និងចម្លាក់ពុម្ពថ្ម នៅស្រុកព្រៃនប់
- បានធ្វើការណែនាំដល់អាជីវករលើកតាំងស្លាកយីហោដែលខុសពីខ្លឹមសារលេខ១៧២ សជណ របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងណែនាំអំពីការសរសេរអក្សរលើស្លាកយីហោឲ្យបានត្រឹមត្រូវ នៅស្រុកព្រៃនប់
- ការិយាល័យច្រកចេញចូលតែមួយ បានចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មលើវិស័យវប្បធម៌ និងវិចិត្រសិល្បៈបាន៤៧ច្បាប់

## ***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តមណ្ឌលគីរី៖</u>***

- បានរៀបចំប្រារព្ធទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១ ៨ ឆ្នាំ២០១ ៦ ក្រោមប្រធានបទ "យុវជនដើម្បីវប្បធម៌ជាតិ" ក្រោមអធិបតីភាព ឯកឧត្តម សំរាំង កំសាន្ត រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានរៀបចំប្រគំតន្ត្រីបុរាណ និងលេងល្បែងប្រជាប្រិយខ្មែរកំសាន្ត ដើម្បីអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ
- បានដឹកនាំក្រុមសិល្បៈយុវជនសិស្សវិទ្យាល័យ ហ៊ុន សែន មណ្ឌលគីរី ចំនួន០២ក្រុម ចូលរួមមហោស្រពសិល្បៈយុវជនទូទាំងប្រទេស ឆ្នាំ២០១៦ នៅរាជធានីភ្នំពេញ
- បានបង្ហាត់បង្រៀនបទភ្លេងពិណពាទ្យដល់ប្រជាពលរដ្ឋ០១ក្រុមជាប្រចាំ
- បានសហការជួយធ្វើឧបករណ៍ភ្លេងរបាំថ្មីដែលច្នៃពីបំពង់ឬស្សីថ្មបានចំនួន០២គូរ
- បាននិពន្ធទំនុកច្រៀងរបាំប្រមូលផលផ្លែប័រ បាន០១អត្ថបទ
- បានបន្តយកសេចក្តីជូនដំណឹងលេខ១២៧ ស.ជ.ណា ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការហាមផ្សព្វផ្សាយ ជួល-លក់ ខ្សែភាពយន្តរឿង No Escape 2015 ដល់ក្រុមហ៊ុនទូរទស្សន៍ខ្សែកាប និងអាជីវករជួល-លក់ថាសគ្រប់ស្រុកទាំងអស់ក្នុងខេត្ត

- បានចុះត្រួតពិនិត្យកន្លែងជួល-លក់ថាសនៅក្រុងសែនមនោរម្យ
- ចុះត្រួតពិនិត្យ និងដកហូតថាសដែលគ្មានចុះទិដ្ឋាការរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានចំនួន១.៩០០បន្ទះ នៅក្រុងសែនមនោរម្យ និងបានយកមកដុតកម្ទេចចោល ក្នុងទិវាវប្បធម៌ជាតិ ០៣ មីនា ឆ្នាំ២០១៦
- បានរៀបចំឯកសារក្បាច់ចម្លាក់ រចនាបថខ្មែរដើម្បីផ្សព្វផ្សាយដល់ម្ចាស់សិប្បកម្ម និងជាងចម្លាក់
- បានបញ្ចប់ការសរសេរ និងចងក្រងប្រភេទមុខម្ហូបជនជាតិដើមភាគតិចព្នងបានចំនួន៨មុខម្ហូប
- បានចុះណែនាំដល់អាជីវករលើកស្លាកយីហោដែលសរសេរអក្សរបរទេសធំជាងអក្សរខ្មែរខុសពីសារាចរណែនាំរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នៅក្រុងសែនមនោរម្យ
- បានធ្វើខ្លែងឯកខ្មែរថ្មីបានចំនួន០១ និងបង្ហាត់បង្រៀនដល់យុវជនអំពីរបៀបធ្វើខ្លែងឯកខ្មែរ
- បានចុះពិនិត្យ និងថែរក្សាអាស្រមទាំងបីនៅលើ មជ្ឈមណ្ឌលវប្បធម៌ជនជាតិនៅភ្នំដោះក្រមុំសម្រាប់ភ្ញៀវទេសចរណ៍មកលេងកំសាន្ត
- បានរៀបចំ និងបោះពុម្ពឯកសារព្រាងលើមុខម្ហូបជនជាតិព្នងចំនួន៨មុខ ដើម្បីត្រៀមធ្វើសិក្ខាសាលាពិគ្រោះយោបល់
- បានបន្តស្រង់ទិន្នន័យមរតកវប្បធម៌អរូបីនៅក្រុងសែនមនោរម្យ និងស្រុកអូររាំង
- ការិយាល័យច្រកចេញចូលតែមួយក្រុងសែនមនោរម្យ បានចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មលើវិស័យវប្បធម៌ និងវិចិត្រសិល្បៈបាន១៥ច្បាប់

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តរតនគិរី ៖</u>***

- បានរៀបចំប្រារព្ធទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១ ៨ ឆ្នាំ២០១ ៦ ក្រោមប្រធានបទ "យុវជនដើម្បីវប្បធម៌ជាតិ" ក្រោមអធិបតីភាព ឯកឧត្តម សំរាំង កំសាន្ត រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានចុះត្រួតពិនិត្យការហ្វឹកហាត់របស់ក្រុមសិល្បៈយុវជន និងក្រុមសិល្បៈមហាជនភូមិតងណាងឡិះរៀងរាល់សប្តាហ៍
- បានបង្ហាត់របាំជូនពរ និងរបាំគោះត្រឡោកដល់សិស្សរៀងរាល់ម៉ោងធ្វើការ
- បានចុះត្រួតពិនិត្យកន្លែងជួល-លក់ថាសខុសច្បាប់នៅក្រុងបានលុង និងដកហូតបានថាសចំនួន១.៣០៥បន្ទះ
- បានចុះត្រួតពិនិត្យកន្លែងចាក់បញ្ចាំងទូរទស្សន៍ខ្សែកាប និងការចាក់បញ្ចាំងតាមហាងកាហ្វេនៅក្រុងបានលុង
- បានចុះត្រួតពិនិត្យការបញ្ចាំងខ្សែភាពយន្តខ្នាតធំ (ទង់ព្រលឹង) ចំនួន០១រឿង
- បានចុះត្រួតពិនិត្យ និងស្រង់ស្ថិតិកន្លែងលក់វត្ថុអនុស្សាវរីយ៍នៅក្រុងបានលុង និងស្រុកបរកែវ និងពង្រឹងសិប្បកម្មចម្លាក់នៅស្រុកកូនមុំ
- បានចុះត្រួតពិនិត្យសិប្បកម្មតម្បាញរបស់បងប្អូនជនជាតិនៅសង្កាត់យក្សឡោម
- បានចុះសិក្សាស្រាវជ្រាវមរតកវប្បធម៌មនុស្សរស់ជាក្រុមអំពីសិប្បកម្មតម្បាញ និងរបៀបធ្វើស្រាពាងលក្ខណៈធម្មជាតិ នៅស្រុកអូរជុំ
- បានចុះសិក្សាស្រាវជ្រាវវប្បធម៌ប្រពៃណីជនជាតិចារាយអំពីពិធីសែនភូមិ និងការរៀបអាពាហ៍ពិពាហ៍នៅស្រុកអូរយ៉ាដាវ

## *មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តសៀមរាប ៖*

- បានរៀបចំប្រារព្ធទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១៨ ឆ្នាំ២០១៦ ក្រោមប្រធានបទ "យុវជនដើម្បីវប្បធម៌ជាតិ" ក្រោមអធិបតីភាព ឯកឧត្តម សោម សុគន្ធ រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានផ្តល់លិខិតអនុញ្ញាតនាំចេញវត្ថុសិល្បៈទៅក្រៅប្រទេសចំនួន២៩រូប
- ក្រុមសិល្បៈរបាំ និងសិល្បៈមហាជនចំនួន២៦ក្រុមបានសម្តែងតាមរោងមហោស្រព សណ្ឋាគារ ភោជនីយដ្ឋាន និងផ្សាររាត្រីជូនភ្ញៀវជាតិ និងអន្តរជាតិទស្សនាជាប្រចាំ
- បានដឹកនាំក្រុមសិល្បៈទៅចូលរួមសម្តែងរបាំជាលក្ខណៈមិត្តភាព នៅខេត្តចំប៉ាសាក់ ប្រទេសឡាវ
- បានតម្លើងរបាំប្រពៃណីថ្មីបានចំនួន០៦របាំគឺ "របាំដំបែ", "របាំត្បាល់ក្តឿង", "របាំជូនពរ", "របាំផ្លិត" "របាំអប្សរា" , "របាំមនោសញ្ចេតនា"
- បានចូលរួមបង្ហាញ និងដឹកនាំល្បែងប្រជាប្រិយដល់យុវជន ដើម្បីចូលរួមអបអរសាទរ អង្គរសង្ក្រាន្ត ក្នុងពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ នៅប្រាសាទអង្គរវត្តនិងអង្គរធំ
- បានចុះត្រួតពិនិត្យបច្ចេកទេសរបស់ក្រុមសិល្បៈអង្គការកម្ពុជាអភិវឌ្ឍនៃក្តីសង្ឃឹម និងក្រុមសិល្បៈនានានៅក្រុងសៀមរាប
- បានចុះណែនាំ និងត្រួតពិនិត្យបទល្មើសភាពយន្ត -វីដេអូដល់អាជីវករភាពយន្ត-វីដេអូ (ការផលិត ការចាក់បញ្ចាំង ការជួល -លក់ថាសអាសអាភាស និងគ្មានទិដ្ឋាការ) ឱ្យចូលរួមអនុវត្តតាមលិខិតបទដ្ឋានច្បាប់ចំនួន៥១កន្លែង នៅក្រុងសៀមរាប ស្រុកបន្ទាយស្រី ស្រុកក្រឡាញ់ ស្រុកពួក ស្រុកអង្គរជុំ ស្រុកស្រីស្នំ និងស្រុកប្រាសាទបាគង
- បានចុះបង្រៀនចំណេះដឹងវប្បធម៌ដល់ស្រទាប់យុវវ័យ និងមហាជន នៅឃុំរុនតាឯក
- បានចុះត្រួតពិនិត្យ និងណែនាំកែលម្អអំពីការអនុវត្តច្បាប់របស់ជំនាញដល់អាជីវករ-សិប្បករ ដែលកំពុងបម្រើសេវាកម្មលក់ទងនិងជំនាញសិល្បៈសូនរូបនិងសិល្បៈសិប្បកម្មនៅក្រុងសៀមរាប ស្រុកប្រាសាទបាគង ស្រុកស្រីស្នំ ស្រុកបន្ទាយស្រី
- សហការជាមួយក្រុមការងារចម្រុះសាលាក្រុងសៀមរាប ចុះកាត់ស្លាកសញ្ញា ផ្ទាំងផ្សាយពាណិជ្ជកម្មដែលគ្មានលិខិតអនុញ្ញាត និងដាក់លើដីចំណីផ្លូវបានចំនួន១៦៥ស្លាក
- បានចុះត្រួតពិនិត្យទីតាំងដែលអាជីវករសុំលើកស្លាកយីហោ ផ្ទាំងផ្សាយពាណិជ្ជកម្ម សម្អាងការ និងបានឲ្យមកសុំច្បាប់អនុញ្ញាតពីសាលាក្រុងសៀមរាប
- បានចុះត្រួតពិនិត្យទីតាំងបង្រៀនក្បាច់គុនល្បុកតោ នៅសង្កាត់ក្របីរៀល ក្រុងសៀមរាប
- ការិយាល័យច្រកចេញចូលតែមួយក្រុងសៀមរាប បានផ្តល់ច្បាប់សេវាកម្មលើវិស័យវប្បធម៌ និងវិចិត្រសិល្បៈចំនួន៨១ច្បាប់

## *មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តស្ទឹងត្រែង ៖*

- បានរៀបចំប្រារព្ធទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១៨ ឆ្នាំ២០១៦ ក្រោមប្រធានបទ "យុវជនដើម្បីវប្បធម៌ជាតិ" ក្រោមអធិបតីភាព ឯកឧត្តម ថៃ នរៈសត្យា រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានបង្កើតស្នាដៃថ្មីចំនួន២ស្នាដៃគឺ របាំ "ភោគផលម្ចាស់ផ្អែម" និងល្ខោននិយាយ "ខ្ញុំយល់ហើយ"

- បានបង្ហាត់របាំ "ភោគផលម្ចាស់ផ្ទែម" និងល្ខោននិយាយ "ខ្ញុំយល់ហើយ" ដល់សិស្សវិទ្យាល័យព្រះរាជបូជនីយកិច្ច
- បានសហការជាមួយក្រុមសិល្បៈសិស្សវិទ្យាល័យព្រះរាជបូជនីយកិច្ច ហាត់របាំចំនួន៥របាំ ដើម្បីសម្តែងក្នុងពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ
- បានចុះណែនាំអាជីវករជួល-លក់ថាស និងបានឲ្យយកថាសដែលមានទិដ្ឋាការមកចុះបញ្ជីបាន ចំនួន៩កន្លែង នៅក្រុងស្ទឹងត្រែង
- បានចុះផ្សព្វផ្សាយអនុក្រឹត្យលេខ៦៣ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងត្រួតពិនិត្យវិស័យភាពយន្ត-វីដេអូដល់អាជីវករបានចំនួន២៥កន្លែង នៅសង្កាត់ស្ទឹងត្រែង
- បានចុះស្រង់ទិន្នន័យបឋមនៃមរតកវប្បធម៌អរូបីនៅស្រុកសៀមប៉ាងបានចំនួន២ទម្រង់
- បានចុះជម្រុញអាជីវករប្រកបអាជីវកម្មសេវាកម្មវប្បធម៌ឲ្យមកបំពេញបែបបទសម្រាប់ឆ្នាំ២០១៦ ចំនួន០៦កន្លែងនៅក្រុងស្ទឹងត្រែង
- ការិយាល័យច្រកចេញចូលតែមួយ បានផ្តល់ច្បាប់សេវាកម្មលើវិស័យវប្បធម៌ និងវិចិត្រសិល្បៈ ចំនួន២៦ច្បាប់

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តស្វាយរៀង ៖</u>***

- បានរៀបចំប្រារព្ធទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១ ៨ ឆ្នាំ២០១ ៦ ក្រោមប្រធានបទ "យុវជនដើម្បីវប្បធម៌ជាតិ" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ លោកជំទាវរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានចុះបង្ហាត់របាំ និងបំពាក់បំប៉នក្រុមសិល្បៈមហាជនចំនួន១២ក្រុម
- បានចុះត្រួតពិនិត្យអាជីវកម្មជួល-លក់ថាសចំនួន១៣លើក រកឃើញថាសគ្មានទិដ្ឋាការចំនួន៧០០បន្ទះ
- បានចុះផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធវិស័យភាពយន្ត-វីដេអូចំនួន០២លើក
- បានចុះត្រួតពិនិត្យអាជីវកម្មសូនរូប និងសិប្បកម្មចំនួន០៥លើក
- បានចុះត្រួតពិនិត្យការដាក់តាំងស្លាកយីហោ និងផ្ទាំងផ្សាយពាណិជ្ជកម្មចំនួន០៨លើក
- ការិយាល័យច្រកចេញចូលតែមួយ បានផ្តល់ច្បាប់សេវាកម្មលើវិស័យវប្បធម៌ និងវិចិត្រសិល្បៈ ចំនួន១២ច្បាប់

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តឧត្តរមានជ័យ ៖</u>***

- បានរៀបចំប្រារព្ធទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១ ៨ ឆ្នាំ២០១ ៦ ក្រោមប្រធានបទ "យុវជនដើម្បីវប្បធម៌ជាតិ" ក្រោមអធិបតីភាព ឯកឧត្តម គង់ កន្ធារ៉ា អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានហ្វឹកហាត់សិល្បៈដល់ក្រុមសិល្បៈសិស្សវិទ្យាល័យ ហ៊ុន សែន ឧត្តរមានជ័យ
- បានចុះពិនិត្យបញ្ចាំងភាពយន្ត-វីដេអូ ដែលគ្មានទិដ្ឋាការពីក្រសួងវប្បធម៌ និងបានធ្វើការណែនាំដល់អាជីវករជួលមេក្រូ ធុងបាស វីដេអូចល័ត អំពីកម្រិតសម្លេង នៅក្រុងសំរោង ស្រុកអន្លង់វែង ស្រុកចុងកាល់ និងស្រុកបន្ទាយអំពិល
- បានចុះផ្សព្វផ្សាយ អំពីក្បាច់ចម្លាក់បុរាណ ចាក់ពុម្ពស៊ីម៉ងត៍ នៅក្នុងស្រុកអន្លង់វែង

- បានចុះទៅធ្វើបទបង្ហាញអំពីក្បាច់ចម្លាក់បុរាណ ចាក់ពុម្ពស៊ីម៉ងត៍នៅស្រុកចុងកាល់
- បានចុះពិនិត្យសកម្មភាពសិប្បកម្មចម្លាក់ឈើ នៅក្រុងសំរោង និងស្រុកអន្លង់វែង និងស្រុកត្រពាំងប្រាសាទ
- បានចុះណែនាំជាងគំនូរអំពីរចនាបថក្បាច់បុរាណខ្មែរនៅក្រុងសំរោង ស្រុកអន្លង់វែង និងស្រុកត្រពាំងប្រាសាទ
- បានចុះពិនិត្យអាជីវកម្មអ៊ុតសក់ សម្អាងការ និងលម្អក្រចក និងចុះពិនិត្យការតាំងស្លាកយីហោផ្សាយពាណិជ្ជកម្មនៅក្រុងសំរោង ស្រុកចុងកាល់ ស្រុកបន្ទាយអំពិល និងស្រុកអន្លង់វែង
- បានចុះជម្រុញអាជីវករឲ្យមកធ្វើច្បាប់ប្រកបអាជីវកម្មលើវិស័យវប្បធម៌នៅក្រុងសំរោង
- បានចុះស្រាវជ្រាវអំពីតម្បាញកន្ទេល អំពីផ្តៅ ឬស្សី ល្ពាក់ ពិធីឡើងអ្នកតា និងពិធីជញ្ជាត់ព្រលឹងនៅក្នុងស្រុកអន្លង់វែង
- ការិយាល័យច្រកចេញចូលតែមួយក្រុងសំរោង បានផ្តល់ច្បាប់សេវាកម្មលើវិស័យវប្បធម៌ និងវិចិត្រសិល្បៈចំនួន២៣ច្បាប់។

## ២.៣.៤. សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

- បានបន្តអនុវត្តកម្មវិធីសិក្សាឆ្នាំសិក្សា២០១៥-២០១៦
- បានបើកការប្រឡងបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកតូរ្យតន្ត្រី
- បានបើកបាឋកថាស្តីពី "ទិដ្ឋភាព៣ នៃលោកតាឃ្លាំងមឿងនៅខេត្តពោធិសាត់" និង "ស្ថាបត្យកម្ម និងវិសាលភាព"
- បានបើកពិព័រណ៌ទេពកោសល្យ និងស្នាដៃ ក្រោមប្រធានបទ "មរតកផ្ទះខ្ញុំ" និង "មរតកផ្ទះខ្មែរ"
- និស្សិតមហាវិទ្យាល័យស្ថាបត្យកម្ម និងមហាវិទ្យាល័យសិល្បៈសូនរូប ចុះកម្មសិក្សាស្វែងយល់អំពីរចនាបថផ្ទះបុរាណខ្មែរ និងប្រាសាទនានាក្នុងខេត្តបាត់ដំបង និងខេត្តសៀមរាប
- និស្សិតដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋានចុះកម្មសិក្សានៅប្រាសាទភ្នំដា ខេត្តតាកែវ
- និស្សិតមហាវិទ្យាល័យសិល្បៈនាដសាស្ត្រចុះកម្មសិក្សានៅប្រាសាទព្រះវិហារ ខេត្តព្រះវិហារ
- និស្សិតមហាវិទ្យាល័យតូរ្យតន្ត្រី ចុះកម្មសិក្សាស្វែងយល់ពីសិល្បៈតន្ត្រីរបស់ជនជាតិភាគតិចខេត្តរតនៈគីរី
- និស្សិតមហាវិទ្យាល័យបុរាណវិទ្យា ចុះកម្មសិក្សានៅប្រាសាទនានាក្នុងខេត្តសៀមរាប
- មហាវិទ្យាល័យស្ថាបត្យកម្មបានធ្វើបទបង្ហាញស្តីពី "ការកត់សម្គាល់ខ្លះៗទៅលើការរៀបចំទីក្រុង និងកិច្ចការស្ថាបត្យកម្មតាមរយៈឧទាហរណ៍ជាអន្តរជាតិ និងនៅកម្ពុជា " "បទពិសោធន៍នៃការហាត់ក្នុងផ្នែកស្ថាបត្យកម្មនៅទីក្រុងសៀងហៃ ប្រទេសចិន" "សំណង់សុវត្ថិភាព" "អាជីពការងារ" និងបើកសិក្ខាសាលាអន្តរជាតិស្តីពី "ដំណើរវិវដ្តប្រែប្រួលនៃការកែលម្អក្រុងនៅកម្ពុជា"
- សាស្ត្រាចារ្យ និងនិស្សិតឆ្នាំទី៣ ទី៤ ចំនួន៦២នាក់ នៃមហាវិទ្យាល័យបុរាណវិទ្យា បានចុះកម្មសិក្សារយៈពេល៥ថ្ងៃ នៅខេត្តព្រះវិហារ

- សាស្ត្រាចារ្យ និងនិស្សិតឆ្នាំទី៤ ចំនួន១៤នាក់ នៃមហាវិទ្យាល័យបុរាណវិទ្យា បានចូលរួមធ្វើកំណាយស្រាវជ្រាវឡកុលាលភាជន៍ នៅស្ថានីយជើងឯក
- ថ្នាក់ដឹកនាំ សាស្ត្រាចារ្យ និងនិស្សិតឆ្នាំទី៤ ចំនួន១២នាក់ នៃមហាវិទ្យាល័យបុរាណវិទ្យា ចូលរួមហ្វឹកហាត់វគ្គបណ្តុះបណ្តាលផ្នែករៀបចំប្លង់ និងអភិរក្សប្រាសាទបាណន់ នៅខេត្តបាត់ដំបង ដោយមានកិច្ចសហការជាមួយសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងសាកលវិទ្យាល័យ TOULOUSE ប្រទេសបារាំង
- និស្សិតមហាវិទ្យាល័យស្ថាបត្យកម្ម៥០នាក់ ចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពី "វឌ្ឍនភាពវិស័យស្ថាបត្យកម្មសំណង់ និងក្របខណ្ឌនគរូបនីយកម្ម និងស្ថាបត្យកម្មនៅកម្ពុជា ដើម្បីការអភិវឌ្ឍន៍ប្រកបដោយចីភាព" នៅទីស្តីការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានប្រារព្ធពិធី និងការសម្តែងសិល្បៈក្នុងពិធី "ព្រះគុណគ្រូល្ខោនខោល" រៀបចំឡើងដោយមហាវិទ្យាល័យសិល្បៈនាដសាស្ត្រ នៅស.ភ.វ.ស
- និស្សិត៥០នាក់ចូលរួមសិក្ខាសាលា ក្រោមប្រធានបទ "វេទិកា ពិភាក្សាអំពីវិស័យពាណិជ្ជកម្ម និងអប់រំកម្ពុជាបច្ចុប្បន្ន» នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា
- និស្សិតមហាវិទ្យាល័យស្ថាបត្យកម្មឆ្នាំទី៤ ជំនាន់ទី២៤ ចំនួន៣នាក់ និងឆ្នាំទី៥ ជំនាន់ទី២៣ ចំនួន៥នាក់ បានចុះកម្មសិក្សានៅប្រទេសអាល្លឺម៉ង់រយៈពេល១២ថ្ងៃ ដែលឧបត្ថម្ភដោយ DAAD
- និស្សិតស.ភ.វ.ស បានចូលរួមកម្មវិធីអង្គរសង្ក្រាន្ត ឆ្នាំ២០១៦ នៅខេត្តសៀមរាប
- បានបញ្ជូនសាស្ត្រាចារ្យចំនួន៨រូប ទៅបង្រៀនអំពីវប្បធម៌ទូទៅដល់សិស្សនាយទាហានសកម្មនៃអគ្គបញ្ជាការដ្ឋានកងយុទ្ធពលខេមរភូមិន្ទ
- បានបញ្ជូននិស្សិតចំនួន០៨រូប ទៅចូលរួមកម្មវិធីផ្លាស់ប្តូរទំនាក់ទំនងយុវជនអាស៊ីបូព៌ានៅប្រទេសជប៉ុន
- បានចូលរួមកិច្ចប្រជុំត្រៀមលើកទី១នៃកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់(Senior Officials Meeting "SOM ")
- បានទៅចូលរួមសិក្ខាសាលាស្តីពី "សាសនា" នៅប្រទេសហ្វីលីពីន
- បានចូលរួមកិច្ចប្រជុំអាស៊ី-អឺរ៉ុប នៅទីក្រុង GWANGJU សាធារណរដ្ឋកូរ៉េ
- យុវជនកាកបាទក្រហមកម្ពុជា ស.ភ.វ.ស ទៅប្រឡងជ្រើសរើសដើម្បីចូលរួមបោះជំរំយុវជនអន្តរជាតិនៅប្រទេសហ្វីលីពីន
- លោកបណ្ឌិត គឹម ពីនន់ ដឹកនាំនិស្សិតចំនួន១៤នាក់ ចូលរួមកម្មវិធី ASEAN Plus Ramayana Under the ASEAN Curtural Expo 2016 នៅទីក្រុងបាងកក ប្រទេសថៃ
- បានចុះអនុស្សារៈនៃការយោគយល់គ្នារវាង AUF បារាំង និងសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
- បន្តការជួសជុលអគារបណ្ណាល័យ និងជួលជុលអគារE នៃមហាវិទ្យាល័យស្ថាបត្យកម្ម។

### ២.៣.៥. សាលាមធ្យមវិចិត្រសិល្បៈ

- គ្រូ និងសិស្សចំនួន៤០នាក់ ចូលរួមសិក្ខាសាលាស្តីពី "ល្បុកតោ" នៅពហុកីឡាដ្ឋានជាតិអូឡាំពិក
- សិល្បករ សិល្បការិនីចំនួន១៣០នាក់ ចូលរួមសម្តែងក្នុងព្រឹត្តិការណ៍អង្គរសង្ក្រាន្តឆ្នាំ២០១៦

- សិល្បករ សិល្បការិនីចំនួន៧០នាក់ ចូលរួមសម្តែងនៅមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក
- បានទទួលអំណោយជាគ្រឿងឧបភោគ សម្ភារៈ និងថវិកា ពីសប្បុរសជននៅស្រុកបារាំង និង លោកជំទាវឧកញ៉ា សៀង ចាន់ហេង អគ្គនាយក្រុមហ៊ុន ហេងអភិវឌ្ឍន៍ ជូនសាលាមធ្យមវិចិត្រសិល្បៈ
- បានទទួលអំណោយ និងថវិកា ពីលោកជំទាវឧកញ៉ា សៀង ចាន់ហេង អគ្គនាយកក្រុមហ៊ុន ហេងអភិវឌ្ឍន៍ និងព្រះតេជគុណ នៃវត្តសារវ័ន្ត ជូនមន្ត្រីរាជការសាលាមធ្យមវិចិត្រសិល្បៈ
- បានទទួលបដិសណ្ឋារកិច្ចគ្រូ និងសិស្សសាលាសិល្បៈសឹង្ហបុរីចំនួន២៤នាក់ មកផ្លាស់ប្តូរវប្បធម៌ សិល្បៈនៅសាលាមធ្យមវិចិត្រសិល្បៈ។

### ២.៣.៦. នាយកដ្ឋានសវនកម្មផ្ទៃក្នុង ៖

- បានរៀបចំសិក្ខាសាលាស្តីពីកិច្ចដំណើរការនៃការធ្វើសវនកម្ម នៅទីស្តីការក្រសួង
- បានចុះធ្វើសវនកម្មនៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកណ្តាល រតនគីរី ក្រចេះ ព្រះវិហារ ស្ទឹងត្រែង ឧត្តរមានជ័យ និងកំពង់ធំ។

### ២.៣.៧. អធិការដ្ឋាន

បានចុះធ្វើអធិការកិច្ចនៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តតាកែវ កំពង់ចាម ត្បូងឃ្មុំ និងមណ្ឌលគីរី។

លទ្ធផលការងារវប្បធម៌ និងវិចិត្រសិល្បៈក្នុងឆមាសទី១ ឆ្នាំ២០១៦នេះ ជារួមឃើញថា មានដំណើរការល្អអាស្រ័យដោយស្មារតីមោះមុត ពុះពារ និងការតាំងចិត្តខ្ពស់របស់ថ្នាក់ដឹកនាំ ទន្ទឹមនឹងការចូលរួមចំណែកយ៉ាងសកម្មពីមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលបានជួយគាំទ្រជម្រុញ និងបានជួយដោះស្រាយបញ្ហាប្រឈមចំពោះមុខមួយចំនួនដែលជាឧបសគ្គដល់ការអភិរក្ស និងអភិវឌ្ឍវប្បធម៌ជាតិទាំងរូបី និងអរូបី។ ជាក់ស្តែងផែនការសកម្មភាពការងារចាំបាច់ទាំងឡាយដែលបានរៀបចំសម្រាប់អនុវត្តក្នុងឆមាសទី១ ឆ្នាំ២០១៦ ហើយមានចែងក្នុងផ.យ.អ.ជ ២០១៤ -២០១៨ ស្តីពីវិស័យវប្បធម៌ ដែលក្រសួងសម្រេចបានគួរជាទីមោទនៈនោះគឺការងារជួសជុលគាំពារថែរក្សាសំណង់បុរាណដែលកំពុងប្រឈមនឹងគ្រោះថ្នាក់មានជាអាទិ ៖ ស្ពានបុរាណ ប្រាសាទបុរាណ ព្រះវិហារបុរាណ ផ្លូវបុរាណ និងការធ្វើកំណាយសង្គ្រោះបន្ទាន់ ព្រមទាំងការបោះបង្គោលកំណត់ទីតាំងទួលបុរាណដើម្បីឲ្យគេចផុតពីការរំលោភបំពានយកដីពីពួកឈ្មួញទុច្ចរិត។ក្រៅពីនេះក៏នៅមានការងារជួសជុលវត្ថុបុរាណដែលបានបាក់បែកឲ្យមានសភាពដូចដើមដើម្បីបង្កើនសមុច្ច័យវត្ថុបុរាណសម្រាប់ដាក់តាំងជូនភ្ញៀវជាតិ-អន្តរជាតិទស្សនា ព្រមទាំងការងារអភិរក្សទម្រង់សិល្បៈបុរាណ និងប្រពៃណីក្នុងគោលដៅផ្សព្វផ្សាយសិល្បៈវប្បធម៌ខ្មែរក្នុងក្របខ័ណ្ឌតំបន់ និងពិភពលោក ព្រមទាំងទាក់ទាញភ្ញៀវទេសចរណ៍គ្រប់ជាតិសាសន៍ឲ្យមកទស្សនាកម្ពុជាកាន់តែច្រើនឡើង ដើម្បីកំណើនសេដ្ឋកិច្ចជាតិ។

សូមគូសបញ្ជាក់បន្ថែមថាលទ្ធផលនេះគឺបានបើកឱកាសជម្រុញឱ្យមានការប្រើប្រាស់សក្តានុពលវប្បធម៌ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងជម្រុញឲ្យសម្រេចបាននូវទិសដៅដែលចង់បាន ពោលគឺប្រែក្លាយព្រះរាជាណាចក្រកម្ពុជាជាមជ្ឈមណ្ឌលផ្សព្វផ្សាយវប្បធម៌ជាតិ តាមទិសស្លោក "**កម្ពុជាៈ ព្រះរាជាណាចក្រនៃវប្បធម៌**" ដោយដើរតាមកម្មវិធីនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣នៃរាជរដ្ឋាភិបាល

នីតិកាលទី៥នៃរដ្ឋសភា និងនាំឲ្យឈានទៅសម្រេចបានតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ២០១៤-២០១៨ ក្នុងវិស័យវប្បធម៌ទៀតផង។ ទន្ទឹមនឹងលទ្ធផលការងារសម្រេចបានដូចគោរពជម្រាបជូនខាងលើ ក្រសួងក៏ពុំទាន់សម្រេចបាននូវសកម្មភាពវប្បធម៌មួយចំនួនដែលបានរៀបចំសម្រាប់អនុវត្តក្នុងឆមាសទី១ ឆ្នាំ២០១៦នេះផងដែរ ដោយ ទំហំការងារវប្បធម៌ទូទាំងប្រទេសទាំងផ្នែករូបី និងអរូបីមានវិសាលភាពធំធេង បើប្រៀបធៀបទៅនឹងសមត្ថភាព និងលទ្ធភាពជាក់ស្តែងនៃធនធានដែលមាន គឺជាកត្តានាំឲ្យមានការខ្វះចន្លោះក្នុងការគ្រប់គ្រង។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមបណ្ឌិតសភាចារ្យ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ ។

**រដ្ឋមន្ត្រី**

**ចម្លងជូន៖**

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គណៈកម្មការអប់រំ ធម្មការ វប្បធម៌ ទេសចរណ៍ ព្រឹទ្ធសភា
-គណៈកម្មការទី ៧ រដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី (នាយកដ្ឋានសរុប)
-ក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ)
-ក្រុមសង្កេតការសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ទីស្តីការគណៈរដ្ឋមន្ត្រី)
-ឯកសារ-កាលប្បវត្តិ